# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

## "នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ"

ការស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **គី សាំងហេង**

សាស្ត្រាចារ្យណែនាំ
**លោកស្រី ប៉ូលី បញ្ញា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២២

ឆ្នាំចូលរៀន ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

អាត្មាភាពព្រះនាម **គី សាំងហេង** ជានិស្សិតថ្នាក់បរិញ្ញាផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ ទី២២ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា២០១៨-២០២២ បាន សរសេរសារណា ដើម្បីបញ្ចប់ការសិក្សាក្រោមប្រធានបទស្តីពី "**នីតិវិធីនៃការដោះស្រាយ វិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ**" ។

ជាបឋមខ្ញុំព្រះករុណាអាត្មា សូមលំឱនកាយគោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ លោកឪពុក **គី វណ្ណា** និងអ្នកម្តាយ **កុល គុន្ធា** ដោយលោកអ្នកមានគុណទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅណែនាំផ្តល់ដំបូន្មាន ព្រមទាំងមានការទនុកបម្រុងដល់រូបកូនគ្រប់បែបយ៉ាងទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត។ ជាពិសេស តាំងពីកូនចាប់កំណើតមកដល់កូនធំពេញវ័យលោកឪពុក និងអ្នកម្តាយ តែងតែមានការជំរុញឱ្យខិតខំប្រឹងប្រែងសិក្សារៀនសូត្រឱ្យបានខ្ពង់ខ្ពស់រហូតបានបញ្ចប់បរិញ្ញាបត្រនេះ។ គុណូបការយ៉ាងធំអំណេកនេះរូបកូននឹងចងចាំជានិច្ច មិនអាចបំភ្លេចបានឡើយ។

ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងគណៈគ្រប់គ្រង សាស្ត្រាចារ្យទាំងអស់ ដែលបានជួយជំរុញផ្តល់ការលើក ទឹកចិត្ត ជាពិសេសគឺការផ្តល់នូវចំណេះដឹង បទពិសោធន៍ល្អៗយ៉ាងច្រើនក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ ដែលបានធ្វើឱ្យអាត្មាភាពក្លាយជានិស្សិតល្អ មិត្តល្អ និងជាពលរដ្ឋល្អនៅក្នុងសង្គមជាតិព្រមទាំងអាចធ្វើឱ្យចំណេះដឹងដែលអាត្មាភាពទទួលបានពី សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះយកទៅបម្រើក្នុងវិស័យពុទ្ធចក្រ និងវិស័យអាណាចក្រក្នុងប្រទេសកម្ពុជា។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែលចំពោះ លោកស្រីសាស្ត្រាចារ្យ **ម៉ូលី បញ្ញា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំសារណាមួយនេះ ដោយលោកបានផ្តល់នូវដំបូន្មាន និងចំណេះដឹងបន្ថែមប្រកបដោយបទពិសោធន៍ ព្រមទាំងផ្តល់ការកែសម្រួលលើប្រធានបទមួយនេះ យ៉ាងអស់ពីកម្លាំងកាយកម្លាំងចិត្ត ប្រាជ្ញាស្មារតី ក្នុងគោលបំណងដើម្បីឱ្យសារណាបញ្ចប់ការសិក្សាមួយនេះប្រកបដោយជោគជ័យ និងល្អប្រសើរសម្រាប់ជាប្រយោជន៍ដល់អ្នកអាន និងអ្នកសិក្សាជំនាន់ក្រោយបានស្វែងយល់ផងដែរ។

ជាទីបញ្ចាប់នេះ អាត្មាភាពសូមជូនពរដល់លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោក-លោកស្រីសាស្ត្រចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ឱ្យជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

បន្ទាប់ពីបានទទួលការសិក្សាអស់រយៈពេលជិត៤ឆ្នាំនៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** កន្លងមកនេះធ្វើឱ្យអាត្មាភាពទទួលបាននូវចំណេះដឹងយ៉ាងច្រើន ដែលមានសន្ទុះកើនឡើងគួរឱ្យចាប់អារម្មណ៍។ ក្នុងអំឡុងពេលកំពុងសិក្សានេះ ខ្ញុំព្រះករុណាអាត្មាភាពក៏សម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី "**នីតិវិធីនៃការដោះស្រាយវិវាទដីធ្លី ក្រៅប្រព័ន្ធតុលាការ**" ដែលមានការណែនាំពីលោកស្រីសាស្ត្រាចារ្យ **ម៉ូលី ចញ្ញា** ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំចងក្រងតាក់តែងជាឯកសារបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

ការសម្រេចចិត្តជ្រើសរើស ប្រធានបទខាងលើមកសិក្សាស្រាវជ្រាវជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះក៏ដោយសារតែអាត្មាភាពយល់ឃើញថា មានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋកម្ពុជាឱ្យមានការយល់ដឹងអំពីវិធីដោះស្រាយវិវាទដីធ្លីទៅតាមទំនៀមទម្លាប់ ប្រពៃណីខ្មែរ និងការដោះស្រាយក្រៅប្រព័ន្ធតុលាការ ព្រមទាំងឱ្យមានការយល់ដឹងអំពីការដោះទៅតាមផ្លូវតុលាការ ដូចបានចែងក្នុងច្បាប់ភូមិបាល ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ នីតិវិធីក្រមព្រហ្មទណ្ឌ។ ម្យ៉ាងវិញទៀតការស្រាវជ្រាវនេះបានទទួលការយល់ព្រមការឯកភាព និងការលើកទឹកចិត្តពីសាស្ត្រាចារ្យដឹកនាំសរសេរសារណាក្នុងការជំរុញឱ្យកិច្ចការនេះបានសម្រេចចេញជាលទ្ធផល។

ក្រោយពីស្រាវជ្រាវបានបញ្ចប់ អាត្មាភាពមានសេចក្តីសង្ឃឹមថាសារណានេះនឹងក្លាយជាអត្ថបទដែលមានសារៈប្រយោជន៍ សម្រាប់អ្នកសិក្សាស្រាវជ្រាវផ្នែកច្បាប់ទាំងអស់ជាពិសេសអ្នកអនុវត្តទៅលើការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការក្នុងប្រទេសកម្ពុជា។ ជាងនេះទៀតវានឹងក្លាយជាឯកសារមួយដែលបានចូលរួមចំណែកក្នុងការជំរុញដល់ការអនុវត្តច្បាប់ឱ្យកាន់តែមានប្រសិទ្ធិភាព ហើយជាផ្នែកមួយនៃការផ្សព្វផ្សាយច្បាប់ និងការស្រាវជ្រាវផ្នែកច្បាប់ឱ្យកាន់តែសម្បូរបែបផងដែរ។

បើទោះជាយ៉ាងណាក៏ដោយ ការត្រួតពិនិត្យក្នុងការរៀបរៀងចងក្រងនូវអត្ថបទ តែងតែមានកង្វះខាតនូវចំណុចជាច្រើន ដូចជា អក្ខរាវិរុទ្ធ ខ្វះខាតនូវឯកសារផ្សេងៗ សម្រាប់ជាជំនួយក្នុងការស្រាវជ្រាវរៀបរៀងនេះ និងដោយសារអាត្មាភាពដែលជាអ្នករៀបរៀងនូវអត្ថបទនេះ មានបទពិសោធន៍តិចតួចស្តួចស្តើង និងមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំបំពេញការងារឱ្យបានល្អមួយរយភាគរយនោះទេ។ ដូច្នេះអាត្មាភាពសូមខន្តីអភ័យទោសអំពីសំណាក់សាស្ត្រាចារ្យ និស្សិត និងសាធារណៈជនទាំងឡាយដែលបានពិនិត្យមើលនូវសារណានេះ។

# មាតិកា


**សេចក្តីផ្តើម** ........ 1

**ជំពូកទី១**

**សញ្ញាណទូទៅ និងប្រវត្តិនៃការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា (១៨៨៤ -១៩៩៣)** ..... 3

**ផ្នែកទី១៖ ការដោះស្រាយវិវាទដីធ្លីសម័យបុរាណ (មុន១៨៨៤)** ........ 4

កថាខណ្ឌទី១៖ របបគ្រប់គ្រងដីសម័យបុរាណ និងករណីវិវាទដីធ្លី........ 4

កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យបុរាណ........ 6

**ផ្នែកទី២៖ ការដោះស្រាយវិវាទដីធ្លីសម័យអាណានិគមនិយមបារាំង (១៨៨៤- ១៩៥៣)** ........ 7

កថាខណ្ឌទី១៖ របបគ្រប់គ្រងដីសម័យអាណានិគមនិយមបារាំង និងករណីវិវាទដីធ្លី ........ 7

កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យអាណានិគមនិយមបារាំង ........ 8

**ផ្នែកទី៣៖ ការដោះស្រាយវិវាទដីធ្លីសម័យសង្គមរាស្ត្រនិយម (១៩៥៣- ១៩៧០)** ........ 9

កថាខណ្ឌទី១៖ របបគ្រប់គ្រងដីធ្លីនូវសម័យសង្គមរាស្ត្រនិយម និងករណីវិវាទដីធ្លី ........ 9

កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យសង្គមរាស្ត្រនិយម ........ 11

**ផ្នែកទី៤៖ ការដោះស្រាយវិវាទដីធ្លីសម័យសាធារណៈរដ្ឋខ្មែរ (១៩៧០-១៩៧៥)** ... 12

កថាខណ្ឌទី១៖ របបគ្រប់គ្រងដីធ្លីនូវសម័យសាធារណៈរដ្ឋខ្មែរ និងករណីវិវាទដីធ្លី........ 12

កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យសាធារណៈរដ្ឋខ្មែរ........ 13

**ផ្នែកទី៥៖ ការដោះស្រាយវិវាទដីធ្លីសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)** ........ 14

កថាខណ្ឌទី១៖ របបគ្រប់គ្រងដីធ្លីនូវសម័យកម្ពុជាប្រជាធិបតេយ្យ និងករណីវិវាទដីធ្លី........ 14

កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យកម្ពុជាប្រជាធិបតេយ្យ........ 15

**ផ្នែកទី៦៖ ការដោះស្រាយវិវាទដីធ្លីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៨០-១៩៨៩)** ........ 15

កថាខណ្ឌទី១៖ របបគ្រប់គ្រងដីធ្លីនូវសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងករណីវិវាទដីធ្លី ...... 15

កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា........ 18

**ផ្នែកទី៧៖ ការដោះស្រាយវិវាទដីធ្លីសម័យរដ្ឋកម្ពុជា (១៩៨៩-១៩៩៣)** ........ 19

កថាខណ្ឌទី១៖ របបគ្រប់គ្រងដីធ្លីសម័យរដ្ឋកម្ពុជា និងករណីវិវាទ ............ 19

កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យរដ្ឋកម្ពុជា ............ 21

**ជំពូកទី២**

**នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យព្រះរាជាណាចក្រកម្ពុជា (១៩៩៣-បច្ចុប្បន្ន)** ............ 22

**ផ្នែកទី១៖សញ្ញាណទូទៅនៃវិវាទដីធ្លី និងរបបគ្រប់គ្រងដីសម័យព្រះរាជាណាចក្រកម្ពុជា** ............ 22

កថាខណ្ឌទី១៖ ករណីវិវាទដីធ្លី និងគុណសម្បត្តិនៃរបបចុះបញ្ជីដីធ្លី ............ 23

វាក្យខណ្ឌទី២៖ ករណីវិវាទដីធ្លី ............ 23

វាក្យខណ្ឌទី២៖ គុណសម្បត្តិនៃរបបចុះបញ្ជីដីធ្លី ............ 24

កថាខណ្ឌទី២៖ របបនៃការចុះបញ្ជីដីកម្មសិទ្ធិ ............ 25

កថាខណ្ឌទី៣៖ របបនៃការចុះបញ្ជីសិទ្ធិប្រត្យក្សផ្សេងទៀតទាក់ទងអចលនវត្ថុនៅក្នុងក្រមរដ្ឋប្បវេណី ............ 27

**ផ្នែកទី២៖ ប្រភេទនៃវិវាទដីធ្លី** ............ 28

កថាខណ្ឌទី១៖ ករណីវិវាទរវាងរូបវន្តបុគ្គលឯកជន និងរូបវន្តបុគ្គលឯកជន ............ 29

កថាខណ្ឌទី២៖ ករណីវិវាទរវាងរូបវន្តបុគ្គលឯកជន និងសមូហភាព ............ 30

កថាខណ្ឌទី៣៖ ករណីវិវាទរវាងនីតិបុគ្គលឯកជន និងនីតិបុគ្គលឯកជន ............ 32

កថាខណ្ឌទី៤៖ ករណីវិវាទរវាងបុគ្គលឯកជន និងបុគ្គលសាធារណៈ ............ 34

**ផ្នែកទី៣៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យព្រះរាជាណាចក្រកម្ពុជា** ............ 35

កថាខណ្ឌទី១៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីតាមប្រពៃណី ............ 35

វាក្យខណ្ឌទី១. ការចរចាទ្វេរភាគី ............ 36

វាក្យខណ្ឌទី២. ការផ្សះផ្សា និងការសម្រុះសម្រួលតាមរយៈអាជ្ញាធរដែនដី ............ 38

វាក្យខណ្ឌទី៣. ការដោះស្រាយវិវាទដោយពឹងផ្អែកលើជំនឿ និងវត្ថុស័ក្តិសិទ្ធិ ............ 39

វាក្យខណ្ឌទី៤. គុណសម្បត្តិ និងគុណវិបត្តិនៃការដោះស្រាយវិវាទដីធ្លីតាមប្រពៃណី ............ 39

កថាខណ្ឌទី២៖ ការដោះស្រាយវិវាទដីធ្លីតាមរយៈគណៈកម្មការសុរិយោដី ............ 40

វាក្យខណ្ឌទី១. គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ ............ 40

វាក្យខណ្ឌទី២. គណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្ត ............ 42

វាក្យខណ្ឌទី៣. គណៈកម្មការសុរិយោដីថ្នាក់ជាតិ ............ 44

កថាខណ្ឌទី៣៖ ការដោះស្រាយវិវាទតាមរយៈអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនៅកម្ពុជា...........45
កថាខណ្ឌទី៤៖  គុណសម្បត្តិ និងគុណវិបត្តិនៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ ............47
**សេចក្តីសន្និដ្ឋាន** ........................................................................................ 49
**អនុសាសន៍** .................................................................................................. 51
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ប្រទេសកម្ពុជារបស់យើងមានផ្ទៃដីសរុបចំនួន**១៨១,០៣៥**គីឡូម៉ែត្រក្រឡា និងប្រជាជនជាង១៥លាននាក់ ដោយការរស់នៅរបស់ប្រជាជនតាំងពីសម័យបូរាណតែងតែជួបនូវសង្គ្រាមផ្ទៃក្នុងព្រមវិបត្តិដីធ្លីកើតឡើងជាបន្តបន្ទាប់តាំងពីសម័យអាណានិគមនិយមបារាំង សម័យសង្គមរាស្ត្រនិយម សម័យសាធាណៈរដ្ឋខ្មែរ សម័យកម្ពុជាប្រជាធិបតេយ្យ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា សម័យរដ្ឋកម្ពុជា និងសម័យព្រះរាជាណាចក្រកម្ពុជា។ នាសម័យដ៏សែនកំសត់នោះ គឺរបបនៃការដឹកនាំរបស់ លោក ប៉ុល ពត ដែលមានវត្តមានរបស់កងទ័ពខ្មែរក្រហមបានបញ្ជាក់ថា រាល់សិទ្ធិទ្រព្យសម្បត្តិឯកជនក៏ត្រូវបានរលាយបាត់បង់។ ក្នុងរបបខ្មែរក្រហមជីវិតមនុស្សជាច្រើនត្រូវបានជម្លៀសចេញពីរាជធានីភ្នំពេញ ទៅតាមតំបន់ស្រុកស្រែធ្វើឱ្យស្រេកឃ្លានហេតដល់ស្លាប់ ឬត្រូវបានកាប់សម្លាប់ អាគាររាប់ខ្ទងត្រូវបានកម្ទេច ឬទុកចោលឯកសារជាប្រវត្តិសាស្ត្រជាច្រើនត្រូវបានដុតបំផ្លាញស្ទើរតែទាំងស្រុង ដោយរាប់បញ្ចូលទាំងឯកសារបញ្ជាក់ពីកម្មសិទ្ធិលើដីធ្លី។

បញ្ហាធំមួយដែលនាំឱ្យកើតមានវិវាទដីធ្លីតាមសម័យនីមួយៗ ដោយមានការរំលោភដីធ្លីរបស់ប្រជាកសិករពីសំណាក់ រូបវន្តបុគ្គលឯកជន និងរូបវន្តបុគ្គលឯកជន នីតិបុគ្គលឯកជន និងនីតិបុគ្គលឯកជន រូបវន្តបុគ្គលឯកជន និងសមូហភាព បុគ្គលឯកជន និងបុគ្គលសាធារណៈ។ ឆ្លើយតបនឹងវិបត្តិដីធ្លី រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មការជាតិដោះស្រាយបាតុភាពដីធ្លីនៅខែមីនា ឆ្នាំ១៩៩៩ គណៈកម្មការខេត្ត ក្រុងដោះស្រាយបាតុភាពដីធ្លី បានបង្កើតជាហូរហែនៅគ្រប់ខេត្តក្រុង។ ជាលទ្ធផលយោងតាមការសិក្សាបានបង្ហាញថា ដំណើរការនៃការដោះស្រាយជម្លោះរបស់គណៈកម្មការនោះហាក់ដូចជានៅមានកម្រិត។ ផ្អែកតាមប្រភពនានាបង្ហាថា វិវាទដីធ្លីរាប់រយករណីមិនទាន់ដោះស្រាយនៅឡើយ ទាំងការដោះស្រាយតាមប្រព័ន្ធតុលាការ និងតាមគណៈកម្មការដោះស្រាយបាតុភាពដីធ្លី។ មិនតែប៉ុណ្ណោះ កំណើនវិវាទដីធ្លីចេះតែកើនឡើងថែមទៀត ដែលនេះធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្រីក្រ អសន្តិសុខសង្គម និងលើសពីនេះ ទៀតក៏បណ្តាលឱ្យជនរងគ្រោះមួយចំនួនបានខកចិត្តយ៉ាងខ្លាំង និងអស់សង្ឃឹមក្នុងជីវិតសម្រេចចិត្តបោះបង់បណ្តឹងចោលលែងតវ៉ាដោយមូហេតុថា៖ "ប្តឹងទៅអ្នកណាក៏ដូចគ្នា ប្តឹងទៅណាក៏ជាគ្នាគេមិនបានផលអ្វីឡើយ"។

ការប៉ុនប៉ងជាច្រើនដើម្បីឆ្លើយតបបញ្ហាខាងលើ ពីសំណាក់ក្រុមអង្គការសង្គមស៊ីវិលសហគមន៍ផ្តល់ជំនួយអន្តរជាតិនានា និងរដ្ឋាភិបាល។ ជាក់ស្តែង នៅប៉ុន្មានឆ្នាំចុងក្រោយនេះរាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយ និងក្របខណ្ឌច្បាប់នានា ដូចជាច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រឹត្យមួយចំនួនដើម្បីដោះស្រាយបញ្ហាវិបត្តិខាងលើទាំងនេះ។ ក្រោយមកទៀតមានការបង្កើតគណៈកម្មការសុរិយោដីតាមរយៈ

អនុក្រឹត្យលេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោ។

ក្រោយមកទៀតរាជរដ្ឋាភិបាល បានជំរុញឱ្យមានការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋគ្រប់ទីកន្លែង ក្នុងគោលបំណងរបស់រាជរដ្ឋាភិបាលចង់ឱ្យប្រជាពលរដ្ឋមានការចុះបញ្ជីកម្មសិទ្ធិដីធ្លីដោយទទួលបាននូវគុណសម្បត្តិ ដូចជាមានសិទ្ធិចាត់ចែង ប្រើប្រាស់ និងអាស្រ័យផលលើដីធ្លីរបស់ខ្លួន។

# ជំពូកទី១

## សញ្ញាណទូទៅ និងប្រវត្តិនៃការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា (១៩៨៩-១៩៩៣)

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយស្ថិតនៅផ្នែកខាងត្បូងនៃឧបទ្វីបឥណ្ឌូចិន ក្នុងអនុតំបន់អាស៊ីអាគ្នេយ៍។ កម្ពុជាមានផ្ទៃក្រឡាសរុប **១៨១,០៣៥**[1] គីឡូម៉ែត្រក្រឡា លាតសន្ធឹងក្នុងរាងពហុកោណស្ទើរស្មើជ្រុង មានព្រំប្រទល់ជាប់ប្រទេសថៃនៅភាគខាងលិច និងពាយ័ព្យ ប្រទេសឡាវនៅភាគឦសាន្ត ប្រទេសវៀតណាមនៅភាគខាងកើត និងឈូងសមុទ្រថៃនៅភាគនិរតី។ ដោយមានប្រជាជនជាង ១៥លាននាក់ កម្ពុជាស្ថិតក្នុងលំដាប់ទី៧២ក្នុងពិភពលោក ទី២៧ក្នុងទ្វីបអាស៊ី និងទី៧ក្នុងអាស៊ីអាគ្នេយ៍នាពេលបច្ចុប្បន្នកាលនេះ។ កម្ពុជាមានផ្ទៃដីសរុប១៨១,០៣៥ គីឡូម៉ែត្រការ៉េ តែមានការផ្លាស់ប្តូរជាញឹកញាប់នូវក្របខ័ណ្ឌសិទ្ធិដីធ្លី ដែលពុំមានភាពមាំទាំនៅឡើយ ដោយសារតែមានអាណានិគម និងសង្គ្រាមដ៏ជូរចត់ ដែលបានកើតឡើងចាប់តាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ដែលបានបំផ្លាញចោលនូវប្រព័ន្ធកម្មសិទ្ធិដីធ្លីឯកជន និងឯកសារដីធ្លីនានា ដែលនេះបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិដីធ្លីកាន់តែធ្ងន់ធ្ងរឡើង។

ប្រទេសកម្ពុជា ជាប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្មជាចម្បង ហើយមានប្រជាជន៨០ភាគរយត្រូវការដីដើម្បីចិញ្ចឹមជីវិតរស់នៅ ព្រោះដីជាតម្រូវការចាំបាច់សម្រាប់ដាំដំណាំធ្វើស្រែចម្ការ និងចិញ្ចឹមសត្វជាដើម។ ដីមិនគ្រាន់តែមានសារៈសំខាន់បម្រើឱ្យការផ្គត់ផ្គង់លើការផលិតកសិកម្មប៉ុណ្ណោះទេ ថែមទាំងអាចប្រើប្រាស់សម្រាប់ជាទីលំនៅកន្លែងកំសាន្តទីក្រុងហើយថ្មីៗ នេះដីត្រូវបានបម្រើឱ្យវិស័យ អចលនវត្ថុដូចជា ការទិញ លក់ ដោះដូរជាដើម ជាពិសេសលើវិស័យវិនិយោគ និងពាណិជ្ជកម្ម ដូចជា ដីសម្រាប់សាងសង់រោងចក្រដីសម្រាប់អគារពាណិជ្ជកម្ម ដីសម្រាប់ដំណាំ កសិឧស្សាហកម្ម និងដីសម្រាប់គមនាគមន៍។ ពីមួយសម័យទៅមួយសម័យតម្រូវការបានកើនឡើងជាលំដាប់ស្របពេលទៅនឹងការវិវឌ្ឍនៈនៃសង្គម និងកំណើនប្រជាជនដែលធ្វើឱ្យដីសម្រាប់ផ្គត់ផ្គង់ថយចុះតែតម្រូវការដីចេះតែកើនឡើង។ នេះហើយនាំឱ្យដីមានតម្លៃនៅក្នុងទីផ្សារណាៗក៏ត្រូវការដីយកមកធ្វើជាកម្មសិទ្ធិ និងចង់ពង្រីកកម្មសិទ្ធិទាំងនោះដោយរំលោភបំពានលើសិទ្ធិអ្នកដទៃដែលជាហេតុនាំឱ្យកើតមានវិវាទ។

វិវាទដីធ្លី ជាបញ្ហាដ៏ក្តៅគគុកមួយនៅកម្ពុជានាពេលបច្ចុប្បន្ននេះ បញ្ហាទាំងនេះវិវឌ្ឍនៈកាន់តែរីកធំឡើងៗ និងមានលក្ខណៈស្មុគស្មាញនៅស្ទើរតែពាសពេញផ្ទៃប្រទេស ដែលបានបង្កជាក្តីកង្វល់ដល់សង្គមជាតិកាន់តែច្រើនឡើងៗ ស្របពេលជាមួយនឹងការបង្កើតនូវយន្តការជាច្រើនដើម្បីដោះស្រាយវិវាទដីធ្លីទាំង

[1] អត្ថបទគោលរបស់សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាសម្រាប់អធិប្បាយ ផ្តល់ការបំភ្លឺ ស្តីពីការងារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្ររវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម សម័យប្រជុំពេញអង្គរដ្ឋសភា ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១២ ទំព័រ ៦

នេះ។ ប៉ុន្តែ វិវាទដីធ្លីនៅតែជាជម្លោះដ៏ស្រួចស្រាវក្នុងសង្គមខ្មែរ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ទៅលើវិការវិវឌ្ឍនៈនៃការដោះស្រាយវិវាទដីធ្លី ចាប់តាំងពីសម័យមុនរហូតដល់បច្ចុប្បន្ននេះ និងមានការបកស្រាយពន្យល់អំពីប្រភេទវិវាទដីធ្លី និងបញ្ហាវិវាទតាមសម័យកាលនីមួយៗ។

ដើម្បីជាប្រយោជន៍ចំពោះការសិក្សាស្រាវជ្រាវ និងរួមចំណែកក្នុងការកាត់បន្ថយវិវាទដីធ្លី នៅក្នុងប្រទេសកម្ពុជា។

## ផ្នែកទី១៖ ការដោះស្រាយវិវាទដីធ្លីសម័យបុរាណ (មុន១៨៨៤)

### កថាខណ្ឌទី១៖ របបគ្រប់គ្រងដីសម័យបុរាណ និងករណីវិវាទដីធ្លី

មុនសម័យកាលឆ្នាំ១៨៦៣ របបនៃការគ្រប់គ្រងដីធ្លីទាំងអស់ជាទ្រព្យសម្បត្តិរបស់ព្រះមហាក្សត្រតែមួយគត់ដែលហៅថាព្រះរាជ្យទ្រព្យ[2]។ មានតែសម្តេចដែលមានកម្មសិទ្ធិលើដីធ្លីទាំងអស់ទោះបីជាយ៉ាងនេះក្តីប្រជារាស្ត្រក៏មានសិទ្ធិប្រកបរបរកសិកម្មនៅដីរបស់ខ្លួនដោយសេរី និងអាចកាន់កាប់ប្រើប្រាស់ដីទៅតាមលទ្ធភាពដែលខ្លួនអាចធ្វើទៅបាន។ សិទ្ធិភោគៈនេះត្រូវបានទទួលស្គាល់ និងការពារតាមច្បាប់របស់ខ្មែរពីសម័យមុនៗ[3]។ ប៉ុន្តែអ្នកដែលអាចមានសិទ្ធិស្របច្បាប់កាន់កាប់ដីធ្លី នៅកាលសម័យនោះបាន គឺជាសមាជិកនៃវណ្ណៈមួយចំនួននៅក្នុងសង្គម ដែលកាលនោះសង្គមខ្មែរត្រូវបានបែងចែកជាវណ្ណៈផ្សេងៗគ្នា។ ជាងនេះទៅទៀត ដើម្បីក្លាយទៅម្ចាស់សិទ្ធិលើដីភោគៈនាសម័យមុនមិនចាំបាច់ទាមទារឱ្យមានការដាក់ពាក្យ ឬធ្វើជាសេចក្តីប្រកាសទៅអាជ្ញាធរមូលដ្ឋានទេ គឺគ្រាន់តែត្រូវបង្កបង្កើនផលដីភោគៈនោះ ដូចជាការរុករានសង់ផ្ទះ ឬធ្វើរបង ដោយគ្មានការអាក់ខាន និងមានការដឹងឮជាសាធារណៈ ហើយត្រូវបង់ពន្ធថ្វាយព្រះមហាក្សត្រតាមរយៈអាជ្ញាហ្លួង។ ដោយសារសម័យនោះប្រជាជនមានចំនួនតិច និងពុំមានប្រព័ន្ធផ្លូវការនៃការចុះបញ្ជីលើសិទ្ធិភោគៈផង ដីភោគៈអាចត្រូវបានផ្ទេរតាមរយៈសន្តតិកម្ម ឬជាកម្មវត្ថុនៃការទិញ លក់ ខ្ចី ឬជួល តែសិទ្ធិនេះ នឹងបាត់ទៅវិញនៅពេលដែលដីនោះត្រូវបានគេបោះបង់ចោលក្នុងរយៈពេល៣ឆ្នាំ[4]។

ហេតុដូច្នេះហើយ យើងអាចយល់យ៉ាងច្បាស់លាស់ថា កាលសម័យមុនសិទ្ធិភោគៈត្រូវបានទទួលស្គាល់ និងការពារក្នុងគោលដៅដើម្បីប្រមូលយកពន្ធទៅលើផលិតផលណាដែលកើតចេញពីការប្រើប្រាស់ដីភោគៈនោះប៉ុណ្ណោះ[5]។ ប៉ុន្តែសិទ្ធិភោគៈនោះមិនមានការចុះបញ្ជីជាផ្លូវការនៅឡើយទេ ដែលជាហេតុនាំឱ្យ

---

[2] លឹម វ៉ាន់ ឯកសារស្រាវជ្រាវរបបដីធ្លីនៅកម្ពុជា ខែកក្កដា ឆ្នាំ២០០៦ ទំព័រ ២

[3] សៀវភៅសិក្សា និងស្រាវជ្រាវ ច្បាប់ភូមិបាលកម្ពុជា រៀបចំដោយគម្រោងអនុវត្តច្បាប់ភូមិបាលរបស់ធននាគារ អភិវឌ្ឍន៍អាស៊ី រាជធានីភ្នំពេញ ឆ្នាំ២០០៣ ទំព័រ ២២

[4] សៀវភៅសិក្សា និងស្រាវជ្រាវ ច្បាប់ភូមិបាលកម្ពុជា រៀបចំដោយគម្រោងអនុវត្តច្បាប់ភូមិបាលរបស់ធននាគារ អភិវឌ្ឍន៍អាស៊ី រាជធានីភ្នំពេញ ឆ្នាំ២០០៣ ទំព័រ ២៣

[5] រៀបរៀងដោយ សាស្ត្រាចារ្យ អ៊ិន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លី នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំសិក្សា ២០០៧-២០១១

មានការលំបាកក្នុងគ្រប់គ្រងរបបដីធ្លីដើម្បីប្រមូលយកពន្ធ និងបញ្ជាក់ថា តើអ្នកណាជាម្ចាស់សិទ្ធិពិតប្រាកដនោះ។ ម្យ៉ាងវិញទៀតនៅក្នុងប្រទេសកម្ពុជាមុនការកាន់កាប់ដីធ្លីមានលក្ខណៈ **"ចល័ត"**[6] ម្ចាស់ដីដែលកំពុងធ្វើកសិកម្មអាចចាកចោលពីតំបន់មួយទៅតំបន់មួយបាន។ ប្រព័ន្ធជាប្រពៃណីនៃការចល័តនេះ បានបន្តមត៌ករបស់ជាតិ តាមល័ក្ខខ័ណ្ឌនៃធនធានធម្មជាតិ ពីការធ្វើអាជីវកម្ម និងការប្រើប្រាស់ដីធ្លីនៅក្នុងសង្គមកសិកម្មខ្សត់ខ្សោយដ៏លើសលុបមួយពេលគឺ ភាពដែលអាចផ្លាស់ប្តូរតាមកាលៈទេសៈ និងគ្មានទម្រង់ការនៃកម្មសិទ្ធិបានអនុញ្ញាតឱ្យមនុស្សជាច្រើនធ្វើការលើដីធ្លី។ រហូតដល់ឆ្នាំ១៨៦៣ ទើបឃើញមានការរៀបចំជាបណ្តើរៗនូវការកសាងរបបដីធ្លី និងការផ្តល់កម្មសិទ្ធិដីធ្លី ដោយស្របច្បាប់ក្នុងសម័យកាលនៃការចាប់ផ្តើមរបបអាណានិគមបារាំងនៅប្រទេសកម្ពុជា[7]។

ករណីវិវាទដីធ្លីនូវសម័យបុរាណនោះ គឺកើតចេញពីស្តេចត្រាញ់ តួយ៉ាងដូចជា ស្តេច កន ដែលជាស្តេចដណ្តើមរាជ្យពីព្រះបាទសុគន្ធបទ នៅស្រុកស្រីសន្ធរ (ខេត្តកំពង់ចាមបច្ចុប្បន្ន)។ ទីបំផុត ស្តេច កន ក៏ដណ្តើមរាជ្យបានពីព្រះបាទស្រីសុគន្ធបទ ជាបងថ្លៃដោយប្រើល្បិចឱ្យដៃជើងរបស់ខ្លួនឈ្មោះ ឱកម៉ឺនសុរិន្ទកែវទៅបង្កប់ខ្លួននៅក្នុងព្រះរាជវាំង ហើយឆក់ឱកាសធ្វើគត់ស្តេចផែនដីតែម្តង។ ក្រោយមកស្តេចកន ក៏បានចាត់ឱ្យធ្វើព្រះខ័នថ្មី ហើយរៀបចំពិធីភិសេកឡើងសោយរាជ្យសម្បត្តិ ជាមួយនឹងព្រះខ័នក្លែងក្លាយនោះក្នុង គ.ស. ១៥១២ នៅរាជធានីទួលបាសាន។ ព្រះអង្គមានព្រះនាមថាព្រះបាទសម្តេចព្រះស្រីជេដ្ឋាធិរាជរាមាធិបតី[8]។ បានត្រឹមតែបី ឬបួនឆ្នាំប៉ុណ្ណោះ ក៏ត្រូវរងនឹងសង្គ្រាមស៊ីវិលមួយ ដែលអូសបន្លាយអស់រយៈពេលជិតដប់ឆ្នាំជាមួយនឹងព្រះច័ន្ទរាជា ដែលជាព្រះអនុជរបស់ព្រះបាទសុគន្ធបទ ដែលវិលត្រឡប់មកពីប្រទេសសៀម ដើម្បីច្បាំងដណ្តើមរាជ្យពីស្តេចកនវិញ។

នៅក្នុងសង្គ្រាមរវាងខ្មែរ និងខ្មែរនេះ ថ្វីត្បិតតែព្រះពញាច័ន្ទរាជា ត្រូវបានទទួលការគាំទ្រពីរាស្ត្រ និង មន្ត្រីជាច្រើនរូប ដូចជាតាពេជ្រ ឬឃ្លាំងមឿង និងកូនទាំង៤របស់គាត់ ជាដើមក៏ដោយ តែពីដំបូងទ័ពនេះត្រូវបានទ័ពព្រះស្រីជេដ្ឋាស្តេចកន ដ៏មានកម្លាំង វាយសន្ធាប់ ហើយព័ទ្ធជាប់ក្នុងបន្ទាយខេត្តពោធិ៍សាត់ អស់រយៈពេល១២ខែ។ គឺក្នុងស្ថានភាពនេះ ហើយដែលតាពេជ្រ ឬឃ្លាំងមឿង ត្រូវបានគេដំណាលថា បានធ្វើពលិកម្មបូជាជីវិត ធ្វើពិធីលោតចូលរណ្តៅចម្រូង ដើម្បីទៅកេណ្ឌទ័ពបិសាចមកជាទ័ពជំនួយ។ ហើយក្រោយមកទ័ពខាងព្រះច័ន្ទរាជា កាន់តែរីកចម្រើនហើយទទួលបានជោគជ័យច្រើនអន្លើ រំដោះទឹកដីខាងលិចនៃប្រទេសទាំងមូល ដែលធ្វើឱ្យដំណាក់កាលនេះប្រទេសខ្មែរត្រូវចែកជាពីរ គឺព្រះអង្គច័ន្ទ សោយរាជ្យ ឬគ្រប់គ្រងដីធ្លីត្រើយ

---

[6] ទ្រី ហ៊ាន និក្ខេបបទបណ្ឌិតនីតិសាស្ត្រ ឯកទេសៈ នីតិឯកជន វិវាទដីធ្លីនៅកម្ពុជា ២០០១-២០០៩ ទំព័រ ៣

[7] រៀបរៀងដោយសាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លី នៅព្រះរាជាណាក្រកម្ពុជា ឆ្នាំសិក្សា២០០៧-២០១១ ទំព័រ៥

[8] លោកសាស្ត្រាចារ្យ វង់ សុធារ៉ា និង ណុប សុខា នៃសាកលវិទ្យាល័យភ្នំពេញ

ខាងលិចឯព្រះស្រីជេដ្ឋាស្តេចកនសោយរាជ្យ ឬគ្រប់គ្រងដីធ្លីត្រើយខាងកើត។ ក្រោយមកក៏បានវាតទឹកដី ដើម្បីធ្វើស្រែកចំការ ដើម្បីចិញ្ចឹមជីវិតប្រចាំថ្ងៃទៅតាមតំបន់នីមួយៗទៅ។

## កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យបុរាណ

យុទ្ធសាស្ត្រនៃការដោះស្រាយវិវាទដីធ្លី គឺគេសំដៅលើយន្តការនានា ដែលភាគីវិវាទធ្វើការដោះស្រាយ ដោយមិនពឹងផ្អែកលើសវនាការរបស់តុលាការ។ យន្តការ និងទ្រឹស្តីនៃការដោះស្រាយក្រៅប្រព័ន្ធតុលាការ នេះ[9]។ យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ គេមានការប្រើប្រាស់សម្រាប់សម្រុះសម្រួល ផ្សះផ្សា និងចរចា ដើម្បីដោះស្រាយវិវាទដីធ្លី និងបញ្ហាផ្សេងៗទៀត ក្នុងសង្គមសម័យបុរាណ។ ប៉ុន្តែសម័យនោះ គឺជារបបនិយមដែលព្រះមហាក្សត្រក្តោបអំណាចទាំងអស់ដោយផ្ទាល់តែមួយអង្គឯង ជាពិសេសអំណាច នយោបាយ និងអំណាចរដ្ឋបាល។ ព្រះមហាក្សត្រមិនធ្វើច្បាប់ ដោយផ្ទាល់ព្រះអង្គទេ គឺទ្រង់យកច្បាប់ដែល ចេញពីគម្ពីរវេទ និងទំនៀមទម្លាប់មកប្រតិបត្តិតែម្តង។ ព្រះមហាក្សត្រចេញក្រឹត្យបញ្ញាតែក្នុងវិស័យរដ្ឋបាល និងក្នុងនីតិវិធីតុលាការខ្លះតែប៉ុណ្ណោះ។ ព្រះអង្គលោកទ្រង់ធ្វើសវនាការកិច្ចការរដ្ឋបាល និងវិវាទផ្សេងៗកាល សម័យយុគកណ្តាលពីរដងក្នុងមួយថ្ងៃ បើតាមកំណត់ហេតុចិនម្នាក់ឈ្មោះ ចូវតាកូន ក្នុងឆ្នាំ១២៩៦។ ព្រះអង្គ ក៏ជាចៅក្រមកាត់ក្តីផងដែរ។

កាលសម័យនោះ មហាក្សត្រត្រូវតែដឹកនាំដោយផ្ទាល់ទើបសមជាមហាក្សត្រ ពីព្រោះព្រះអង្គត្រូវ ធ្វើជាគំនូរដល់កូនចៅ និងមេបញ្ជាការកំពូល ហើយព្រះអង្គទ្រង់ជាអធិបតីនៃសេនាបតីសភា ដែលមាន សមាសភាពដូចទៅនេះ[10]៖

- សេនាបតី (ឧកញ៉ា ឬសម្តេច) **ចៅវាំ** ឥឡូវនេះយើងហៅថា នាយករដ្ឋមន្ត្រី
- សេនាបតី (ឧកញ៉ា) **យោមរាជ** ឥឡូវនេះយើងហៅថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- សេនាបតី (ឧកញ៉ា) **វាំង** ឥឡូវនេះយើងហៅថា រដ្ឋមន្ត្រីនៃព្រះបរមរាជវាំង និងហិរញ្ញវត្ថុ
- សេនាបតី (ឧកញ៉ា ឬសម្តេច) **ចក្រី** ឥឡូវនេះយើងហៅថា រដ្ឋមន្ត្រីខាងដឹកជញ្ជូនតាម ជើង គោក និង ខាងកងទ័ព។
- សេនាបតី (ឧកញ៉ា) **ក្រឡាហោម** ឥឡូវនេះយើងហៅថា រដ្ឋមន្ត្រីខាងដឹកជញ្ជូនតាម ជើងទឹក និង ខាងសមុទ្រ។

[9] ឯកឧត្តម លី តែសេង និង រៀបចំ កត់ត្រាដោយ វេជ្ជ ម៉ម ដាត្តារ៉ា ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣

[10] រៀបរៀងដោយ និង បង្រៀនដោយឯកឧត្តម សំ សារ៉ាក់ នីតិរដ្ឋបាល ស្តីពីចំណេះដឹង ការងាររដ្ឋបាល កិច្ចការលេខាធិការ និងបណ្ណសារដ្ឋាន ឆ្នាំ២០១១ ទំព័រ ២

អ្នកទាំងអស់នេះសុទ្ធតែមហាក្សត្រតែងតាំងដោយផ្ទាល់ទាំងអស់ ដើម្បីជាសេនាបតីសភាក្នុងការដោះស្រាយវិវាទផ្សេងៗ ដែលកើតមានឡើងក្នុងសម័យកាលនោះ។

## ផ្នែកទី២៖ ការដោះស្រាយវិវាទដីធ្លីសម័យអាណានិគមនិយមបារាំង (១៨៨៤-១៩៥៣)

### កថាខណ្ឌទី១៖ របបគ្រប់គ្រងដីសម័យអាណានិគមនិយមបារាំង និងករណីវិវាទដីធ្លី

ក្រោយពេលដែលបារាំងបានផ្តើមដាក់អាណាព្យាបាលលើប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៦៣ អាណានិគមបារាំង បានធ្វើការផ្លាស់ប្តូរនូវរបៀបរបបជាប្រពៃណី នៃការគ្រប់គ្រងប្រទេសទៅតាមបែបផែនបារាំង ជាពិសេសនៅលើរបបដីធ្លីនៅកម្ពុជា គឺព្រះមហាក្សត្រលែងមានសិទ្ធិធ្វើម្ចាស់លើដីធ្លី ដូចសម័យមុនៗទៀតហើយ។ នៅក្នុងសម័យនោះជារជ្ជកាលរបស់ព្រះបាទ នរោត្តម ព្រះអង្គបានប្រកាសរំលាយដីធ្លីព្រះរាជ្យទ្រព្យចែកជូនប្រជាពលរដ្ឋដូចមានបញ្ជាក់ក្នុងមាត្រា៩ នៃសេចក្តីសម្រេច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៨៨៤ ដីធ្លីនៃព្រះរាជាណាចក្រកម្ពុជាដែលមកទល់សព្វថ្ងៃនេះ កម្មសិទ្ធិផ្តាច់មុខរបស់រាជទ្រព្យ នឹងឈប់ជារបស់ដែលលក់ដូរមិនបានទៀតហើយ[11]។ លុះមកដល់រជ្ជកាលព្រះបាទ ស៊ីសុវត្ថិ ព្រះអង្គបានប្រកាសចំពោះប្រជាពលរដ្ឋថា ឥឡូវនេះយើងចង់ឱ្យមានសក្ខីភាពមួយដ៏ត្រចះត្រចង់ពីការខ្វល់ខ្វាយយ៉ាងខ្លាំងលើផលប្រយោជន៍រាជាណាចក្រ និងប្រជាពលរដ្ឋយើង។ យើងបានសម្រេចផ្តល់ដីគាស់រាន និងដីកំពុងដាំដុះជូនជាកម្មសិទ្ធិឯកជនដល់ប្រជាពលរដ្ឋដែលបានស្នើសុំ[12]។ ក្រោយពីការប្រកាសនេះរួចគេសង្កេតឃើញមានការបង្កើតស្ថានភាព និងវិធានច្បាប់មួយចំនួន ដើម្បីកសាងនូវប្រព័ន្ធចុះបញ្ជីសុរិយោដីមួយជាលើកដំបូងនៅកម្ពុជាណាចក្រកម្ពុជា[13]។ ជាក់ស្តែងឃុំត្រូវបានរៀបចំនិងបង្កើតឡើងតាមបញ្ញត្តិចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩០៨ ហើយត្រូវបានគេពង្រឹងជាបន្តបន្ទាប់ ដើម្បីផ្តល់នូវតួនាទីជាអាជ្ញាធរមូលដ្ឋានក្នុងការកសាងសៀវភៅដីដោយមានតួនាទីសំខាន់លើការគ្រប់គ្រងប្រជាពលរដ្ឋក្នុងឃុំ ជាមន្ត្រីអត្រានុកូលដ្ឋានលើការបញ្ជាក់ ជាមន្ត្រីបញ្ជាក់និងធ្វើអត្តសញ្ញាណក្បាលដី[14]។ ជាងនេះទៅទៀតក្នុងអំឡុងឆ្នាំ១៩២៥ រដ្ឋបានប្រកាសបើកសម័យទទួលចុះបណ្តឹងអចលនវត្ថុ ដែលមានរយៈពេលកំណត់ជាក់លាក់ទូទាំងព្រះរាជាណាចក្រកម្ពុជា។ ប្រកាសនេះបានធ្វើឡើងក្នុងគោលដៅតែមួយគត់គឺមាន **"សៀវភៅចុះបណ្តឹងអចលវត្ថុ"** ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង

---

[11] សៀក វណ្ណា និង សេក សេដ្ឋា របបកម្មសិទ្ធិដីធ្លីកម្ពុជា កម្មវិធីបណ្តុះបណ្តាលអំពីច្បាប់ភូមិបាលសម្រាប់និស្សិត ចៅក្រម និង ព្រះរាជាអាជ្ញា នៅរាជបណ្ឌិតសភាពវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៩

[12] សៀក វណ្ណា និង សេក សេដ្ឋា របបកម្មសិទ្ធិដីធ្លីកម្ពុជា កម្មវិធីបណ្តុះបណ្តាលអំពីច្បាប់ភូមិបាលសម្រាប់និស្សិត ចៅក្រម និង ព្រះរាជាអាជ្ញា នៅរាជបណ្ឌិតសភាពវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៩

[13] សៀក វណ្ណា និង សេក សេដ្ឋា របបកម្មសិទ្ធិដីធ្លីកម្ពុជា កម្មវិធីបណ្តុះបណ្តាលអំពីច្បាប់ភូមិបាលសម្រាប់និស្សិត ចៅក្រម និង ព្រះរាជាអាជ្ញា នៅរាជបណ្ឌិតសភាពវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៩ ទំព័រ ២៥

[14] ទ្រី ហ៊ន និក្ខេបបទបណ្ឌិតនីតិសាស្ត្រ ឯកទេសៈ នីតិឯកជន វិវាទដីធ្លីនៅកម្ពុជា ២០០១-២០០៩

និងការធ្វើផែនការអភិវឌ្ឍន៍ផ្សេងៗ និងការកសាងបញ្ជីពន្ធដីប្រកបទៅដោយភាពត្រឹមត្រូវ និងសមធម៌។ ជាពិសេសទៅទៀតក្រមរដ្ឋប្បវេណីខ្មែរត្រូវបានបង្កើត និងបានអនុម័តក្នុងឆ្នាំ១៩២០ បានចែងពីរបបអភិរក្សសុរិយោដីក្នុងមាត្រា៧២៤ ថាសិទ្ធិភោគៈអចលនវត្ថុ និងឡើងទៅជាកម្មសិទ្ធិក្រោយពេលដែលអចនលវត្ថុនោះបានចុះបញ្ជីកម្មសិទ្ធិរួចហើយ។ នៅក្នុងដំណាក់កាលនោះគេពុំសូវជួបបញ្ហាដីធ្លីប៉ុន្មានទេ ទោះបីជាមានទំនាស់ខ្លះៗក៏ដោយតែទំនាស់នោះ សុទ្ធតែបានដោះស្រាយរួចរាល់។ នេះក៏ដោយសារតែមូលហេតុ គឺដីនៅទំនេរច្រើន កសិករមួយចំនួនធំ ជាម្ចាស់កម្មសិទ្ធិដីធ្លី និងកម្មសិទ្ធិលើដីធំៗមានចំនួនតិច[15]។

ករណីវិវាទដីធ្លីនូវសម័យនោះ គឺកើតចេញពីបារាំងបានបញ្ចូលទឹកដីកម្ពុជាឱ្យក្លាយជាកម្មសិទ្ធិរបស់ខ្លួន។ ហើយព្រះរាជាមានសេចក្តីព្រួញបារម្ភយ៉ាងខ្លាំងចំពោះទឹកដីកម្ពុជា ដោយបានឃើញ ហេតុការណ៍ និងការអនុវត្តប្រចាំថ្ងៃរបស់បារាំង។ ជាពិសេសនោះ គឺលោក រ៉េស៊ីដង់ ដែលជាប្រធានក្នុងការគ្រប់គ្រងរដ្ឋបាលនៃប្រទេសម្ពុជា ហើយពេលនោះដែលបារាំងក៏ជួបនៅសង្គ្រាមដ៏សែនវេទនា លោក រ៉េស៊ីដង់ បានឱ្យប្រជាពលរដ្ឋខ្មែរ ដែលមានដីធ្លីធ្វើស្រែ និងគោល ក្របី ជ្រូក ត្រូវតែមានការបង់ពន្ធជូនរដ្ឋ[16]។ ជាក់ស្តែងនៅរឿងអក្សរសិល្ប៍ខ្មែរ ភូមិតិរច្ឆាន ដែលមានទីតាំងនៅភូមិក្រាំងលាវ ស្រុករលៀប្រៀរ ខេត្តកំពង់ឆ្នាំ ដែលត្រូវបានពួកអាណានិគមបារាំង ដែលដឹកនាំដោយ លោក រ៉េស៊ីដង់ បារាំងម្នាក់នេះ បានប្រើសកម្មភាពចាប់បង្ខិតបង្ខំឱ្យប្រជាពលរដ្ឋខ្មែរបង់ពន្ធដារឱ្យបានគ្រប់គ្នា។ ប៉ុន្តែក្នុងសម័យនោះប្រជារាស្ត្រខ្មែរមិនបានលុយទៅបង់ពន្ធ លោក រ៉េស៊ីដង ប្រើអំពើឃោរឃៅ និងនយោបាយដ៏ពិសពុល គាបសង្កត់គ្មានត្រាប្រណី។ ប្រជារាស្ត្រខ្មែរបានហូរភ្នែកដ៏សែនកំសត់ និងយំសោកដ៏ក្រៀមក្រំប្រកបដោយសេចក្តីជូរចត់ដែលពួកបារាំងមកត្រួតត្រាខ្មែរ។ ប្រជារាស្ត្រខ្មែរ បានដេញបាញ់ លោក រ៉េស៊ីដង និងសហការី របស់លោកបានស្លាប់ទៅជាច្រើននាក់ផងដែរ[17]។

### កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យអាណានិគមនិយមបារាំង

នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យអាណានិគមនិយមបារាំងនោះ ក៏មានច្បាប់រដ្ឋធម្មនុញ្ញជាបង្គោលក្នុងការដោះស្រាយវិវាទដីធ្លីដែរ[18]។ ប៉ុន្តែកាលនោះវិវាទលើដីធ្លីជាបញ្ហាធំណាស់ សម្តេចព្រះករុណាព្រះមហាវីរៈក្សត្រ នរោត្តម សីហនុ មានយុទ្ធសាស្ត្រក្នុងការទាមទារឯករាជ្យជាតិពីបារាំង។ នៅក្រោមអាណាព្យាបាលបារាំង ចាប់ថ្ងៃ០៨ ខែវិច្ឆិកា ឆ្នាំ១៨៦៣ រហូតដល់ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ទើបបារាំងព្រមប្រគល់ឯករាជ្យពេញលេញឱ្យព្រះរាជាណាចក្រកម្ពុជាយើង ក្រោមព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ។ សម្តេចព្រះ

[15] លឹម វ៉ាន់ ឯកសារស្រាវជ្រាវរបបដីធ្លីនៅកម្ពុជា ខែកក្កដា ឆ្នាំ២០០៦ ទំព័រ ៦

[16] សេចក្តីសង្ខេបមេរៀនប្រវត្តិសាស្ត្រខ្មែរ សម្រាប់ជំនួយស្មារតីដល់សិស្សថ្នាក់ទី១២ ឆ្នាំ២០១៧ ទំព័រ ៩

[17] រៀបរៀង និងចងក្រងដោយ គង់ សុខហេង សិក្សាអត្ថបទ អក្សរសិល្ប៍ខ្មែរ សម្រាប់ថ្នាក់មធ្យមសិក្សាថ្នាក់ទី៧-១២ ឆ្នាំ២០១១ ទំព័រ ១១១

[18] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៤៧

មហាវីរៈក្សត្រ នរោត្តម សីហនុ បានទាមទារឯករាជ្យពីប្រទេសបារាំងដោយបានចរចារផ្ទេរអធិបតេយ្យភាពមកឱ្យកម្ពុជា ជាបន្ទាប់ពីព្រះអង្គបានធ្វើយុទ្ធនាការតស៊ូជាច្រើនឆ្នាំ។ ជាពិសេស ក្នុងការទាមទារឯករាជ្យជាតិដោយពេញបរិបូរនោះ ព្រះមហាវីរៈក្សត្របានប្រើប្រាស់នូវនីតិវិធីពីរយ៉ាង[19]៖

**១. ការតស៊ូដោយអាវុធ** គឺការប្រើដោយប្រដាប់អាវុធដែលមានការដឹកនាំដោយខ្មែរឥស្សរៈ ដែលមាននិន្នាការសេរី និងកុម្មុយនីស្ត។ នៅឆ្នាំ១៩៤៩ កងទ័ពខ្មែរឥស្សរៈបានធ្វើសកម្មភាពយ៉ាងសកម្ម និងពង្រឹងការត្រួតត្រារបស់ខ្លួនលើផ្ទៃដី១/៣ នៃប្រទេសកម្ពុជា និងប្រជាជនប្រហែល១លាននាក់។ ព្រឹត្តិការណ៍នេះបានធ្វើឱ្យព្រះបាទ នរោត្តម សីហនុ មានការព្យាយាមចរចាជាមួយបារាំង ដើម្បីឯករាជ្យជាលទ្ធផលបារាំងបានផ្តល់ឱ្យព្រះរាជាណាចក្រកម្ពុជាជារដ្ឋឯករាជ្យមួយស្ថិតក្នុងសហព័ន្ធ ឥណ្ឌូចិន និងបារាំង។

**២. ការតស៊ូដោយសន្តិវិធី** ការតស៊ូនេះដឹកនាំដោយសម្តេច នរោត្តម សីហនុ នាថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៥៣ គឺព្រះមហាក្សត្រ បានយាងទៅកាន់ប្រទេសបារាំង។ ក្រោយពីបានផ្ញើសារលិខិតចំនួន ២ដងទៅកាន់ថ្នាក់ដឹកនាំបារាំងនៅថ្ងៃពុធ ទី២៥ ខែមីនា ឆ្នាំ១៩៥៣ លោក វ៉ាំងសង់ អូរីយ៉ូល ដែលជា ប្រធានាធិបតីបារាំងបានទទួលបដិសណ្ឋារកិច្ចក្នុងពិធីលៀងសាយភោជន៍នៅវិមានអេលីហ្សេ ប៉ុន្តែពុំបានអនុញ្ញាតឱ្យព្រះអង្គដែកបញ្ហានយោបាយកម្ពុជាទេ។

នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៥៣ ព្រះអង្គបានយាងទៅកាន់ប្រទេសកាណាដា និងបានចូលធ្វើសន្និសីទការសែតជាមួយវិទ្យុកាណាដា ដោយបញ្ជាក់ថា ការផ្សព្វផ្សាយរបស់ពួកឥស្សរៈ និងកុម្មុយនីសមានឥទ្ធិពលខ្លាំងក្នុងការទាក់ទាញប្រជាជន ដែលធ្វើឱ្យប៉ះពាល់ឯករាជ្យភាពនៃប្រទេសកម្ពុជា ការប្រកាសហើយលទ្ធផលនៅតែទទួលបានផលអវិជ្ជមានទៀត។

ព្រះមហាក្សត្រ បានពឹងពាក់សហរដ្ឋអាមេរិក នៅទីក្រុងញ៉ូវយ៉ក សម្តេច នរោត្តម សីហនុ បានផ្តល់បទសម្ភាសន៍ជាមួយភ្នាក់ងារការសែតញ៉ូវយ៉កថែម និងមានការផ្សព្វផ្សាយអំពីការទាមទារឯករាជ្យខ្មែរ។ ក្រោយមកបាន មានការចរចារវាងបារាំង និងខ្មែរ ជាបន្តបន្ទាប់ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ទើបបារាំង គឺលោកឧត្តមសេនីយ ដឺឡង់ក្លាដថ្វាយព្រះមហាក្សត្រខ្មែរដែលនិមិត្តរូបនៃឯករាជ្យជាតិពេញលេញរបស់កម្ពុជា។

## ផ្នែកទី៣៖ ការដោះស្រាយវិវាទដីធ្លីសម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០)

### កថាខណ្ឌទី១៖ របបគ្រប់គ្រងដីធ្លីនូវសម័យសង្គមរាស្ត្រនិយម និងករណីវិវាទដីធ្លី

បន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យពីបារាំងនៅថ្ងៃ៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ឥទ្ធិពលនៃប្រព័ន្ធច្បាប់Romano-Germanic[20] ដែលបានបន្សល់ទុកពីសម័យអាណានិគមបានចាក់ឫស និងបន្តអនុវត្តជា

[19] សេចក្តីសង្ខេបមេរៀនប្រវត្តិសាស្ត្រខ្មែរ សម្រាប់ជំនួយស្មារតីដល់សិស្សថ្នាក់ទី១២ ឆ្នាំ២០១៧ ទំព័រ ១៩

លំដាប់។ ម្លោះហើយបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិនៅតែយកមកប្រើប្រាស់។ ជាងនេះទៅទៀតប្រព័ន្ធកម្មសិទ្ធិដីធ្លីក៏មានបែបលោកខាងលិចនៅតែត្រូវ បានអនុវត្តជាបន្តទៀតដែលនាំឱ្យកំណើននៃការទិញលក់ដូរដីធ្លីក៏មានការកើនឡើងដែលនៅក្នុងអំឡុងពេលនោះ។ ម្យ៉ាងវិញទៀត ប្រជារាស្ត្រណាដែលមានលទ្ធភាពអាចកាប់ព្រៃនៅលើដីធ្លី ហើយមានសិទ្ធិប្រើប្រាស់ដីនោះ ពីព្រោះដីធ្លីនៅសម័យនោះព្រះរាជាចង់ឱ្យប្រជារាស្ត្រធ្វើស្រែចំការ ដើម្បីចិញ្ចឹមជីវិតប្រចាំថ្ងៃ។ ប៉ុន្តែប្រជាពលរដ្ឋសម័យនោះមានបញ្ហាជាច្រើននៅជនបទនៃប្រទេសកម្ពុជាមានកាន់តែធ្ងន់ធ្ងរឡើងៗ តាមរយៈចំនួនកំណើននៃកសិករដែលជាប់បំណុលគេ និងជាយថាហេតុនោះគឺគ្មានដីធ្លី។ ទោះជាយ៉ាងណាក៏វាមិនដូចពីមុនឡើង ព្រោះកសិករក្រីក្រត្រូវខ្ចីប្រាក់ទិញស្រូវក្នុងតម្លៃថ្លៃសម្រាប់សាបព្រួសលើដីស្រែរបស់ពួកគេ។ ជាពិសេសអ្នកក្រមិនអាចក្រទៅខ្ចី ប្រាក់ពីធនគារ ដើម្បីយកប្រាក់មកធ្វើស្រែចំការបានទេ។ បញ្ហាខាងហិរញ្ញវត្ថុ គឺកាន់តែធ្ងន់ធ្ងរឡើងៗ ពីព្រោះពួកគេត្រូវលក់ស្រូវទាំងអស់ទៅឱ្យអ្នកដែលគេឱ្យខ្ចីប្រាក់ដើម្បីសងបំណុលរបស់ខ្លួន[21]។

សម្ដេច នរោត្តម សីហនុ បានចាប់ផ្ដើមអនុវត្តព្រះរាជតម្រិះរបស់ព្រះអង្គស្ដីពី **"សង្គមនិយមតាមបែបព្រះពុទ្ធសាសនា"** ក្នុងន័យដើម្បីឆ្លើយតបទៅនឹងសត្រូវខាងសេដ្ឋកិច្ចទាំងនេះ។ ព្រះអង្គមានជំនឿផងដែលថាប្រជារាស្ត្រខ្មែរចូលចិត្តរស់នៅជាសមូហភាពដោយផ្អែកលើប្រព័ន្ធមួយនៃការជួយគ្នាទៅវិញទៅមក។ កាលដែលព្រះរាជតម្រិះជាលាយល័ក្ខណ៍អក្សរក្លាយទៅជាគោលការណ៍ នយោបាយជាក់ស្ដែងហើយ សម្ដេច ព្រះនរោត្ត សីហនុ បានបង្កើតចេញនូវ **"រាជសហករណ៍"** ដើម្បីជួយដល់ កសិករ និងបានធ្វើជាតួបនីយកម្មលើផ្នែកអាហារណ៍ និងនីហរណ៍នៅកម្ពុជា។

ប៉ុន្តែក្រោយមកសម្ដេច នរោត្តម សីហនុ បានបង្កើតនយោបាយអព្យាក្រឹត្យ[22] ប្រទេសជាតិមានការផ្លាស់ប្ដូរដោយសារតែនយោបាយរបស់ព្រះអង្គ។ ប្រជារាស្ត្រខ្លះត្រូវមិនមានដីធ្លីសម្រាប់ធ្វើស្រែចំការ ហើយមានអំណាចបានគាបសង្កត់ប្រជាពលរដ្ឋក្រីក្រមានអំពើពុករលួយ និងប្រទេសជាតិធ្លាក់ទៅរកភ្លើងសង្គ្រាមបន្តិចម្ដងៗដោយមិនដឹងខ្លួន[23]។

[20] សៀក វណ្ណា និង សេក សេដ្ឋា របបកម្មសិទ្ធិដីធ្លីកម្ពុជា កម្មវិធីបណ្ដុះបណ្ដាលអំពីច្បាប់ភូមិបាលសម្រាប់និស្សិត ចៅក្រម និងព្រះរាជាអាជ្ញានៅរាជបណ្ឌិតសភាពវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៩ ទំព័រ ២៥

[21] ទ្រី ហ៊ន និក្ខេបបទបណ្ឌិតនីតិសាស្ត្រ ឯកទេសៈ នីតិឯកជន វិវាទដីធ្លីនៅកម្ពុជា ២០០១-២០០៩ ទំព័រទី១៣

[22] សេចក្ដីសង្ខេបមេរៀនប្រវត្តិសាស្ត្រខ្មែរ សម្រាប់ជំនួយស្មារតីដល់សិស្សថ្នាក់ទី១២ ឆ្នាំ២០១៧ ទំព័រ ២៧

[23] រដ្ឋធម្មនុញ្ញ នៃរបបសង្គមរាស្ត្រនិយម ឆ្នាំ១៩៥៣

ការគ្រប់គ្រងដីធ្លីនូវសម័យនេះក៏ បានធ្លាក់ចុះយ៉ាងខ្លាំងដោយមានបញ្ហាខាងផ្នែកនយោបាយ និងវិបត្តិផ្ទៃក្នុងរវាងខ្មែរ និងខ្មែរ។ម្យ៉ាងវិញទៀតនោះ ក៏មានមនោគមវិជ្ជាជនបរទេសបានចូលមកក្នុងប្រទេសកម្ពុជាដើម្បីជ្រាសជ្រែកកិច្ចការងារផ្ទៃក្នុងធ្វើឱ្យមានវិបត្តិយ៉ាងធ្ងន់ធ្ងររហូតដល់មានសង្គ្រាម។

ករណីវិវាទដីធ្លីនូវសម័យសង្គមរាស្ត្រនិយមនេះ គឺកើតចេញពីកំណើននៃសេដ្ឋកិច្ចរបស់ជាតិ ពីព្រោះអ្នកមានអំណាចបានឃើញនូវហេតុការណ៍នេះហើយមានការរាតដីធ្លី ដើម្បីធ្វើកសិកម្ម និងស្រែកចំការ។ នយោបាយសេដ្ឋកិច្ចក្នុងសម័យសង្គមរាស្ត្រនិយមផ្តោតលើវិស័យចម្បង សេដ្ឋកិច្ចសម័យនោះ ផ្តោតខ្លាំងលើវិស័យកសិកម្មព្រោះលោកយល់ថាជិត៩០ភាគរយនៃប្រជាជនធ្វើកសិកម្ម[24]។ ប៉ុន្តែមានអំណាចធ្វើបាបប្រជាជនក្រីក្រ ដោយដីដែលពួកគាត់ខំប្រឹងរានព្រៃយកដី ដើម្បីធ្វើកសិកម្មបែបគ្រួសារ។ ប៉ុន្តែសកម្មភាពអ្នកមានអំណាចប្រើអំពើពុករលួយកើតមានស្ទើរពោសពេញផ្ទៃប្រទេស រាស្ត្រកាន់តែកើតទុកក្តីក្តៅក្រហាយមិនសប្បាយចិត្តចំពោះជនពុករលួយបក្សពួកគ្រួសារនិយម[25]។

**កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យសង្គមរាស្ត្រនិយម**

ការដោះស្រាយវិវាទដីធ្លីនៅសម័យនោះ មានលក្ខណៈងាយស្រួលណាស់ពីព្រោះប្រជាជនចូលចិត្តការប្រតិបត្តិតាមព្រះពុទ្ធសាសនាដែលអប់រំឱ្យស្រឡាញ់គ្នា។ យុវជនប្រុសៗធំដឹងក្តីនៅក្នុងភូមិត្រូវតែបួស។ បួសគឺជាការអប់រំចិត្តយើងឱ្យនៅក្នុងគន្លងព្រះពុទ្ធសាសនា ដូចនេះគេទទួលបានសីលធម៌ស្រឡាញ់គ្នានៅក្នុងសង្គម។ ទីវត្តអារាមជាថ្នាលសម្រាប់អប់រំកូនខ្មែរឱ្យក្លាយជាពលរដ្ឋល្អទាំងអស់។ ពេលមានទំនាស់ រឿងក្តីតូចធំក្នុងតំបន់នោះ អាជ្ញាធរតែងតែប្រើនៅវិធីសាស្ត្រដូចខាងក្រោម៖

**ក. ការចរចា**

ការចរចា គឺជានីតិវិធីដំបូងក្នុងការដោះស្រាយវិវាទមុនភាគីសម្រេចចិត្តជ្រើសរើសនូវការដោះស្រាយវិវាទតាមរយៈនីតិវិធីដទៃផ្សេងៗទៀត។ ការចរចាអាចធ្វើឡើងក្នុងគោលបំណងជួយដល់អ្នកទាំងឡាយដែលជាប់ពាក់ព័ន្ធក្នុងការចរចា ទោះបីការចរចាដើម្បីខ្លួនឯង ឬក្នុងនាមអ្នកដទៃក៏ដោយត្រូវមានតាំងចិត្ត និងស្មារតីឱ្យបានល្អប្រសើរក្នុងការស្វែងរកនូវដំណោះស្រាយរួមមួយដែលមានមូលហេតុសមស្របអាចទទួលយកបាន។ វិធីសាស្ត្រនៃការចរចា មានលក្ខណៈដូចខាងក្រោម៖

- បំបែកមនុស្សឱ្យចេញអំពីបញ្ហា
- ផ្តោតលើផលប្រយោជន៍រួម

[24] លោក បណ្ឌិត សាយ បូរី អតីតទីប្រឹក្សាផ្ទាល់របស់ព្រះមហាវីរក្សត្រព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

[25] រដ្ឋធម្មនុញ្ញនៃរបបសង្គមរាស្ត្រនិយម ឆ្នាំ១៩៥៣

- បង្កើតជំរើសសម្រាប់ផលចំណេញទាំងសងខាង
- មិនឱ្យមានភាពលំអៀង ទាំងសងខាង និង ដើម្បីឈានទៅរកលទ្ធផលល្អ។

**ខ. ការផ្សះផ្សា**

ការផ្សះផ្សា គឺជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលមានលក្ខណៈស្រដៀងនឹងសន្ធានកម្ម។ អ្នកផ្សះផ្សាមានភារៈណែនាំគូភាគី ដើម្បីរកដំណោះស្រាយវិវាទពាក់ព័ន្ធ និងព្យាយាមពន្យល់ឱ្យមានការព្រមព្រៀងពីភាគីក្នុងការដោះស្រាយជម្លោះ[26]។

**គ. ការសម្រុះសម្រួល**

ការសម្រុះសម្រួល គឺជាជម្រើសដ៏ល្អបំផុតសម្រាប់មនុស្សនៅសម័យសង្គមរាស្ត្រនិយម ពីព្រោះ មានការដោះស្រាយវិវាទដោយសន្តិវិធី និងអហិង្សាតាមរយៈយន្តការសម្រុះសម្រួល។ គោលដៅចម្បងរបស់មនុស្សធ្វើការលើកកម្ពស់ការសម្រុះសម្រួលវិវាទនៅកម្ពុជា តាមរយៈការកសាងសមត្ថភាពបច្ចេកទេស ដោះស្រាយវិវាទ ជំនាញសម្រុះសម្រួល និងអភិវឌ្ឍន៍ជំនាញសម្រុះសម្រួលវិវាទប្រកបដោយជំនាញវិជ្ជាជីវៈ នៅតាមសហគមន៍ អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ និងផ្តល់សេវាសម្រុះសម្រួលវិវាទ ជូនដល់សាធារណៈជនគ្រប់ស្រទាប់ ដើម្បីទទួលបាននូវដំណោះស្រាយសមស្របតាមតម្រូវការរបស់ភាគីដែលមានវិវាទដូចជា៖

- វិវាទគ្រួសារ
- វិវាទការងារ
- វិវាទដីធ្លី
- វិវាទពាណិជ្ជកម្មខ្នាតតូច និងមធ្យម
- វិវាទផលប្រយោជន៍ផ្សេងៗ។

## ផ្នែកទី៤៖ ការដោះស្រាយវិវាទដីធ្លីសម័យសាធារណៈរដ្ឋខ្មែរ (១៩៧០-១៩៧៥)

### កថាខណ្ឌទី១៖ របបគ្រប់គ្រងដីធ្លីនូវសម័យសាធារណៈរដ្ឋខ្មែរ និងករណីវិវាទដីធ្លី

សាធារណៈរដ្ឋខ្មែរត្រូវបានប្រកាសឡើងបន្ទាប់ពីសម្តេច នរោត្តម សីហនុ ត្រូវបានត្រូវគេទម្លាប់ពីតំណែងដោយរដ្ឋប្រហារយោធានៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧០[27]។ កម្មសិទ្ធិទ្រព្យសម្បត្តិឯកជនត្រូវបានទទួលស្គាល់

[26] ឯកសារស្រាវជ្រាវ គណៈកម្មការទី៦ ទទួលបន្ទុកនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទំព័រ ៣

[27] Ros Chantrabot’ La Republique Khmer, L’Harmattan, ប្រែសម្រួលដោយ ទីឃាយុ ទំព័រ ៥

ដោយសាធារណៈរដ្ឋខ្មែរ[28]។ កំឡុងពេលនៃប្រវត្តិសាស្ត្រកម្ពុជាពេលនោះបានក្លាយជាល្បីល្បាញថា ជាការទទួលការញាំញីយ៉ាងខ្លាំង ដោយអំពើពុករលួយដែលបានជ្រាបចូលគ្រប់ស្រទាបអាជ្ញាធររដ្ឋ និងរដ្ឋបាល។

នៅពេលនោះកម្ពុជាស្ថិតនៅក្រោមគោលនយោបាយនាយទុនបានជួបប្រទះនូវវិបត្តិខ្វះ ស្បៀងអាហារដោយសារតែតម្រូវការផ្គត់ផ្គង់អាហារច្រើននៅពេលដែលផលិតស្រូវថយចុះ។ ជាពិសេសនោះ ដីធ្លីគ្មានការចុះបញ្ជីកាច្បាស់លាស់ណាមួយទេ ពីព្រោះកាលនោះដោយមានរដ្ឋប្រហារ ដែលដឹកនាំដោយ **លោក លន់ នល់** គិតគូររកវិធីដោះស្រាយជាមួយវៀតណាម។ ដីធ្លីនៅសម័យនោះមានភាពលំបាកខ្លាំងដោយប្រជាពលរដ្ឋចំនួន២លាននាក់បោះបង់ចោលភូមិ និងដីស្រែរបស់ពួកគេស្វែករកការជ្រកកោណទីក្រុង។ ប្រជាពលរដ្ឋនៅភ្នំពេញកើនពី៥០០.០០០នាក់ នៅឆ្នាំ១៩៧០-១៩៧៥[29]។ គេជឿថា ចំនួនប្រជាពលរដ្ឋមានចំនួនជិត៣លាននាក់ ត្រូវបានភៀសខ្លួនទៅនៅតាមបណ្ដាលប្រទេសផ្សេងៗហេតុផលទាំងអស់នេះហើយ ដែលធ្វើឱ្យការគ្រប់គ្រងដីធ្លីគ្មានភាពច្បាប់ច្បាស់លាស់។

ករណីវិវាទដីធ្លីដីនៅសម័យសាធារណៈរដ្ឋខ្មែរ គឺមិនសូវមានទេនៅក្នុងប្រទេសនោះ ពីព្រោះប្រជាជនមានការព្រួយបារម្ភដោយលោក លន់ នល់ បានធ្វើឱ្យប្រជាពលរដ្ឋឃ្លាតពីភូមិស្រុកបាត់មុនរបបគ្មានការងារធ្វើព្រាត់ប្រាសគ្រួសារ។ ប្រទេសជាតិបានជួបសង្គ្រាម និងពោពេញដោយអំពើហិង្សា ព្រមទាំងមានយ៉ាងទុក្ខក្រៀមក្រំប្រជាពលរដ្ឋគ្មានកម្លាំងធ្វើស្រែកចំការ និងគ្រប់គ្រងលើដីធ្លីទេ ដោយមានបញ្ហានៃសង្គ្រាមរវៀងលោក លន់ នល់ និង លោក ប៉ុល ពត (សាឡុត ស)[30]។

## កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យសាធារណៈរដ្ឋខ្មែរ

វិធីនៃការដោះស្រាយវិវាទនៅសម័យនោះតែងតែមានការអនុវត្តទៅតាមរដ្ឋធម្មនុញ្ញ ដែលបានបង្កើតឡើងនូវគណៈកម្មការចម្រុះមួយ ទទួលរៀបចំនូវសេចក្ដីព្រាងច្បាប់នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋតាមក្រឹត្យលេខ ៤៦៨/៧១ បរ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧២ ដែលមានសមាសភាព ៣នាក់តំណាង ឱ្យអង្គការរដ្ឋនីមួយៗ និងសមាគមនីមួយៗ[31]។ ពេលនៅសម័យនោះឱ្យតែមានបញ្ហាអ្វីដែលទាក់ទង និងវិវាទដីធ្លីគ្រួសារកើតឡើងត្រូវធ្វើបណ្ដឹងទៅតុលាការដើម្បីឱ្យចៅក្រមកាត់ក្ដី។ ដោយឡែកនៅសម័យនោះមានតុលាការចំនួន២គឺ[32]៖

[28] រដ្ឋធម្មនុញ្ញ នៃរបបសាធារណៈរដ្ឋខ្មែរ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២ មាត្រា១៤

[29] ទ្រី ហ៊ាន និក្ខេបបទបណ្ឌិតនីតិសាស្ត្រ ឯកទេសៈ នីតិឯកជន វិវាទដីធ្លីនៅកម្ពុជា ២០០១-២០០៩ ទំព័រ ១៤

[30] សេចក្ដីសង្ខេបមេរៀនប្រវត្តិសាស្ត្រខ្មែរ សម្រាប់ជំនួយស្មារតីដល់សិស្សថ្នាក់ទី១២ ឆ្នាំ២០១៧

[31] រដ្ឋធម្មនុញ្ញ នៃរបបសាធារណៈរដ្ឋខ្មែរ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២

[32] រដ្ឋធម្មនុញ្ញកម្ពុជា ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ សម្ដេចព្រះ នរោត្ដម សីហនុ ក្នុងព្រះឋានៈជាព្រះមុខរដ្ឋ បានឡាយព្រះហត្ថលេខាប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ទំព័រ ៣២-៣៣

១. **តុលាការរដ្ឋធម្មនុញ្ញ** មានតួនាទីដោះស្រាយវិវាទខាងផ្នែកសេដ្ឋកិច្ច និងរដ្ឋបាលបញ្ហាការបោះឆ្នោត និងការបកស្រាយពន្យល់នូវបញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញ។

២. **តុលាការជាន់ខ្ពស់** មានភារកិច្ចក្នុងការជំនុំជំម្រះនៃបទល្មើសជាក់សម្តែង ដូចជា បទឧក្រិដ្ឋ បទមជ្ឈឹម និងបទលហុជាដើម។

ប៉ុន្តែការអនុវត្តនៃច្បាប់នូវក្នុងរបបសាធារណរដ្ឋខ្មែរមិនទាន់បានប៉ុន្មានឆ្នាំទេ ត្រូវបានដួលរលំទាំងស្រុងដោយមានការឡោមព័ន្ធពីកម្លាំងដ៏ខ្លាំងក្លារបស់ខ្មែរក្រហម[33]។

## ផ្នែកទី៥៖ ការដោះស្រាយវិវាទសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

### កថាខណ្ឌទី១៖ របបគ្រប់គ្រងដីធ្លីនូវសម័យកម្ពុជាប្រជាធិបតេយ្យ និងករណីវិវាទដីធ្លី

ក្នុងឆ្នាំ១៩៧៥ ក្រោយពីផ្តួលរំលំរបបសាធារណៈរដ្ឋខ្មែរ ពួកខ្មែរក្រហមបានប្រកាសផ្លាស់ប្តូររបបគ្រប់គ្រងប្រទេសមកជារបបកម្ពុជាប្រជាធិបតេយ្យ ហើយនឹងបានហៅខ្លួនឯងថាជា អង្គការបដិវត្តន៍។ របបគ្រប់គ្រងតាមបែបពួកខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត បានកម្ទេចចោលទាំងស្រុងនូវរចនាសម្ព័ន្ធរដ្ឋបាលក្នុងប្រទេស។ តួយ៉ាងលើវិស័យសុរិយោដី មានឯកសារសំខាន់ៗ ដូចជាច្បាប់ប្លង់សុរិយោដី សៀវភៅសម្ភារៈឧបករណ៍បច្ចេកទេសត្រូវខ្ទេចខ្ទីអស់[34]។ លើសពីនេះទៅទៀត មន្ត្រីបច្ចេកទេសសុរិយោដីដែលមុនឆ្នាំ១៩៧៥ មានចំនួនប្រហែល១.០០០នាក់ នៅសល់មិនដល់៥០នាក់ផងនាក្រោយថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៥[35]។ ប្រជាពលរដ្ឋត្រូវបានពួកខ្មែរក្រហម ជម្លៀសចេញទៅរស់នៅតាមភូមិក្នុងតំបន់ជនបទ។ ប្រជាជនក្នុងទីក្រុង និងទីប្រជុំជនត្រូវបានពួកខ្មែរក្រហម ជម្លៀសចេញពីកន្លែងដែលខ្លួនធ្លាប់រស់នៅដោយឱ្យទៅធ្វើការនៅតំបន់ជនបទដើម្បីរុករានដី និងធ្វើការចល័តប្រជាជនទាំងអស់ឱ្យបំពេញការងារបៀបនេះនៅកន្លែងផ្សេងៗ[36]។

ដីធ្លីនៅសម័យនោះ ត្រូវបានពួកខ្មែរក្រហមរឹបអូសប្រមូលដាក់ជាសម្បត្តិសមូហភាពក្រោម ការគ្រប់គ្រងប្រើប្រាស់ និងចាត់ចែងរបស់អង្គការ។ កម្មសិទ្ធិឯកជនលើដីធ្លីត្រូវបានបំបាត់ចោលនេះជាប្រវត្តិសាស្ត្រសម្រាប់កម្ពុជាដែលមិនមានច្បាប់ស្តីពីទ្រព្យសម្បត្តិ ហើយឯកសារនានាក៏ត្រូវបានបំផ្លិចបំផ្លាញចោលទាំងស្រុងទៀតផង[37]។ នៅសម័យកម្ពុជាប្រជាធិបតេយ្យនេះ របបដីធ្លីប្តូរយ៉ាងគំហុកដោយអំឡុង១៩៧៥-១៩៧៩ គេមិនឃើញមានច្បាប់ស្តីពីទ្រព្យសម្បត្តិទេ ដោយសារតែមានការបំផ្លិចបំផ្លាញឯកសារនានា សិទ្ធិកម្មសិទ្ធិត្រូវ

[33] រដ្ឋធម្មនុញ្ញ នៃរបបសាធារណៈរដ្ឋខ្មែរ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២

[34] រៀបរៀងដោយសាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាក្រកម្ពុជាឆ្នាំសិក្សា២០០៧-២០១១ ទំព័រ៥

[35] លឹម វ៉ាន់ ឯកសារស្រាវជ្រាវរបបដីធ្លីនៅកម្ពុជា ខែកក្កដា ឆ្នាំ២០០៦ ទំព័រ ៧

[36] រៀបរៀងដោយសាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាក្រកម្ពុជាឆ្នាំសិក្សា២០០៧-២០១១ ទំព័រ៨

[37] រដ្ឋធម្មនុញ្ញ នៃរបបប្រជាធិបតេយ្យ ឆ្នាំ១៩៧៥ មាត្រា២

បានលុបបំបាត់ចោល ហើយកម្មសិទ្ធិឯកជនលើដីធ្លីត្រូវបានហាមឃាត់។ អចលនវត្ថុ រួមមានមធ្យោបាយផលិតកម្មសំខាន់ៗទូទៅផ្សេងៗទៀត គឺជាទ្រព្យសម្បត្តិរបស់សមូហភាព[38]។

ករណីវិវាទដីធ្លីនូវសម័យកម្ពុជាប្រជាធិបតេយ្យ គឺមិនមានទេដោយហេតុថា សម័យនោះមានការទម្លាក់គ្រាប់បែកការបាញ់ផ្លោង ការបាញ់រះ ព្រមទាំងមានការជម្លៀសប្រជាជនឱ្យទៅកាន់ទីក្រុង និងឱ្យឃ្លាតពីស្រុកស្រែចំការ ព្រាត់ប្រាស់គ្រួសារ ធ្វើឱ្យប្រជាពលរដ្ឋរងរបួសជាច្រើនលាននាក់ ដោយសារតែមានសង្គ្រាមប្រជាជនមានទុក្ខលំបាកវេទនាដ៏សែនកំសត់ ទុរគតដោយសារតែភាពខ្វះស្បៀង[39]។

**កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យកម្ពុជាប្រជាធិបតេយ្យ**

នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យកម្ពុជាប្រជាធិបតេយ្យនោះ គឺមានរដ្ឋធម្មនុញ្ញជាច្បាប់កំពូលសម្រាប់ឱ្យប្រជាជនអនុវត្តន៍ និងប្រតិបត្តិតាមឱ្យដើម្បីមានសុខសន្តិភាពក្នុងសង្គម និងប្រទេសជាតិ។ ដែលបានអនុម័តនូវក្នុងមហាសន្និបាតជាតិលើទី៣ នាថ្ងៃ១៤ ខែធ្នូ ឆ្នាំ១៩៧៥ និងប្រកាសឱ្យប្រើក្នុងប្រទេសជាផ្លូវការនាថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦[40]។ ប៉ុន្តែជាអកុសលណាស់ អ្នកដឹកនាំនៅសម័យនោះមិនសូវយកច្បាប់រដ្ឋធម្មនុញ្ញមកអនុវត្តន៍ទេ គឺចូលចិត្តការគាំទ្របក្សពួកស្តាំនិយម និងឆ្វេងនិយម[41]។ ជាពិសេសបង្កើតនៅឡើងសង្គ្រាមដ៏សែនវេទនាគ្មានដោះស្រាយណាមួយដើម្បីជួយដល់ប្រជាពលរដ្ឋនោះទេ តែមានការបង្កើតនៅហិង្សាថែមទៀត។ ម្យ៉ាងវិញទៀត ដីធ្លីរបស់ប្រជាពលរដ្ឋនោះត្រូវចូលជាសមូហភាព គ្មានកម្មសិទ្ធិឯកជនទេ ចំណែកឯមន្ត្រីសុីវិលយោធី ស្ទើរតែទាំងអស់ត្រូវបានកាប់សម្លាប់[42]។

## ផ្នែកទី៦៖ ការដោះស្រាយវិវាទសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៨០-១៩៨៩)

**កថាខណ្ឌទី១៖ របបគ្រប់គ្រងដីធ្លីនូវសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងករណីវិវាទដីធ្លី**

ក្រោយថ្ងៃរំដោះ៧មករាឆ្នាំ១៩៧៩ ប្រជាពលរដ្ឋកម្ពុជាដែលនៅរស់រានមានជីវិតបានវិលត្រឡប់មករស់នៅក្នុងស្រុកភូមិដើមរបស់ខ្លួនវិញ តែអ្នកខ្លះទៀតបានទៅតាំងទីលំនៅថ្មីហើយបានកាន់កាប់លំនៅដ្ឋានរបស់ម្ចាស់ផ្សេងៗទៀត ដោយសារម្ចាស់នោះអាចស្លាប់ ឬក៏ទៅរស់នៅជាយដែន ឬតំបន់ផ្សេងៗទៀត។ នៅទីប្រជុំជនមួយចំនួន ពិសេសនៅទីក្រុងភ្នំពេញ ក្រៅពីអគាររដ្ឋបាល និងផ្ទះសម្បែងដែលបែងចែកជូនមន្ត្រីរដ្ឋាភិបាល ប្រជាពលរដ្ឋដែលបានចូលមកមុនគេបានទៅកាន់កាប់និង រស់នៅក្នុងផ្ទះនោះតាមការ

[38] ច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ទំព័រ ២៥

[39] សេចក្តីសង្ខេបមេរៀនប្រវត្តិសាស្ត្រខ្មែរ សម្រាប់ជំនួយស្មារតីដល់សិស្សថ្នាក់ទី១២ ឆ្នាំ២០១៧ ទំព័រ ៣៦

[40] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥

[41] សេចក្តីសង្ខេបមេរៀនប្រវត្តិសាស្ត្រខ្មែរ សម្រាប់ជំនួយស្មារតីដល់សិស្សថ្នាក់ទី១២ ឆ្នាំ២០១៧

[42] ហាប់ ផល្លី ការវិវត្តនៃប្រព័ន្ធគ្រប់គ្រងដីធ្លីនៅកម្ពុជា ខែកញ្ញា ឆ្នាំ២០០៩

ចង់បានរបស់ខ្លួន ហើយក្រោយមកទើបផ្តល់ព័ត៌មានដល់អាជ្ញាធរ ភូមិ និងស្ថាប័នជំនាញដែលគ្រប់គ្រងទ្រព្យសម្បត្តិទាំងនោះ ព្រោះកម្មសិទ្ធិទាំងអស់រាប់ទាំងផ្ទះ ដែលខ្លួនកំពុងរស់នៅបានដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ។ ម្យ៉ាងក្នុងស្ថានភាពនោះមានបញ្ហាចោទឡើងខ្លាំងជាច្រើន គឺការខ្វះខាតកម្លាំងពលកម្ម កម្លាំងអូសទាញ ឧបករណ៍ផលិតកម្ម ការបាត់បង់សមាជិក គ្រួសារនៅសេសសល់ស្ត្រីមេម៉ាយ ចាស់ជរា និងការប្រឈមនឹងជំងឺរ៉ាំរ៉ៃជា ដើមបានជំរុញឱ្យរដ្ឋបង្កើតឡើងនូវនាយកដ្ឋានមួយចំណុះឱ្យក្រសួងកសិកម្ម ដែលមានឈ្មោះថា "**នាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម**" ដែលមានតួនាទីរៀបចំចងក្រង និងដឹកនាំក្រុមសាមគ្គីបង្កបង្កើនផលក្នុងន័យជួយគ្នាទៅវិញទៅមក[43]។

ក្រោយមកក្នុងអំឡុងឆ្នាំ១៩៨៧ ដោយយល់ឃើញថាក្រុមសាមគ្គីបង្កបង្កើនផលលែងមានដំណើរការ រដ្ឋបានធ្វើការកែលម្អនយោបាយសេដ្ឋកិច្ចពីសេដ្ឋកិច្ចប្រមូលផ្តុំមកសេដ្ឋកិច្ចទីផ្សារសេរី។ ដើម្បីអនុវត្តសេដ្ឋកិច្ចទីផ្សារសេរីបានជាបឋមរដ្ឋត្រូវបង្កើតឱ្យមានកម្មសិទ្ធិឯកជន។ ម្លោះហើយនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩ រដ្ឋបានចេញនូវអនុក្រឹត្យលេខ២៥ ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើផ្ទះសម្បែងជូនប្រជាជន។ តាមរយៈអនុក្រឹត្យនេះ បានកំណត់ភាពដាច់ស្រឡះពីគ្នារវាងប្រភេទនៃកម្មសិទ្ធិសមូហភាពលើដីសម្រាប់លំនៅដ្ឋាន និងផ្តល់ប័ណ្ណកម្មសិទ្ធិលើផ្ទះសម្បែងជូនបុគ្គលម្នាក់ៗ។ ក្រោយមកទៀត តាមរយៈសន្និបាតតំណាងកម្មាភិបាលទូទាំងប្រទេសលើកទី២ នាខែមេសា ឆ្នាំ១៩៨៩ រដ្ឋបានដាក់ចេញនូវសេចក្តីសម្រេចចិត្តស្តីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ ដីធ្លីដើម្បីទទួលស្គាល់សិទ្ធិជាឯកជនលើដីធ្លី និងបែងចែកដីជូនប្រជាពលរដ្ឋខ្មែរដែលបានតស៊ូកាន់កាប់ជាប់រហូតយ៉ាងតិច១ឆ្នាំ មុនថ្ងៃកំណត់នេះតាមរយៈ[44]៖

- សិទ្ធិជាភោគៈ លើដីស្រែចម្ការដែលមានទំហំមិនលើសពី៥ហិកតា ដែលនឹងសម្រេចដោយអភិបាលស្រុក-ខណ្ឌ។
- សិទ្ធិជាកម្មសិទ្ធិលើដីលំនៅដ្ឋានដែលមានទំហំលើសពី ២.០០០ម៉ែត្រ ដែលនឹងត្រូវសម្រេចដោយអភិបាលខេត្ត-ក្រុង។
- សិទ្ធិជាសម្បទានលើដីដែលមានទំហំលើសពី ៥ហិកតា ដែលត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម។

យោងតាមសេចក្តីសម្រេចនេះហើយ រដ្ឋក៏បានបង្កើតសេចក្តីណែនាំលេខ០៣ សណន ចុះថ្ងៃ ទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ ស្តីពីការអនុវត្តគោលនយោបាយប្រើប្រាស់ និងគ្រប់គ្រងដីធ្លីដោយបានទទួលស្គាល់

[43] លឹម វ៉ាន់ ឯកសារស្រាវជ្រាវ ច្បាប់ភូមិបាលរបបដីធ្លីនៅកម្ពុជា ខែកក្កដា ឆ្នាំ២០០៦ ទំព័រ ៨

[44] លឹម វ៉ាន់: ឯកសារស្រាវជ្រាវរបបដីធ្លីនៅកម្ពុជា ខែកក្កដា ឆ្នាំ២០០៦ ទំព័រ ៩

សិទ្ធិកម្មសិទ្ធិលើដីលំនៅដ្ឋាន ប៉ុន្តែលក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់សិទ្ធិកម្មសិទ្ធិមិនមានចែងនៅក្នុងសេចក្តីណែនាំនេះទេ[45]។ នៅពេលនោះផងដែរ នាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្មបានត្រូវផ្ទេរមកជានាយកដ្ឋានសុរិយោដី តាមអនុក្រឹត្យ លេខ៣១ អនក្រ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៩។ នាយកដ្ឋាននេះទទួលបន្ទុកធ្ងន់ធ្ងរហួសហេតុដោយមិនមានសុំប័ណ្ណកម្មសិទ្ធិ ចំនួន៤.៥លាន នៅក្នុងអំឡុងពេលពីរឆ្នាំនៃការចាប់ផ្តើមបើកសម័យទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី ហើយបានធ្លាប់ក្នុងស្ថានភាពជាប់គាំងជាប្រចាំយ៉ាងឆាប់រហ័ស។ ភាគច្រើននៃការកាន់កាប់ដីធ្លីដែលបានធ្វើឡើងតាមរយៈកម្មវិធីបែងចែកដីធ្លីក្នុង១៩៨៩ពុំមានឯកសារបញ្ជាក់ច្បាស់លាស់នៅឡើយទេ។

ករណីវិវាទដីធ្លីនូវសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា មានបញ្ហាជាច្រើនណាស់ចំពោះដីធ្លីដោយហេតុថា មនុស្សនៅសម័យនោះមានការកើនឡើង[46]។ ប៉ុន្តែថ្នាក់ដឹកនាំបានបែងចែកដីធ្លីឱ្យមានគោលការណ៍សមធម៌ ហើយប្រជាជនស្ទើរគ្រប់រូបដែលមានសិទ្ធិទទួលដី។ តាមការស្រាវជ្រាវរបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទៅលើការវាយតម្លៃសង្គមទាក់ទងនឹងដីធ្លី នៅសម័យនោះបានបញ្ជាក់ពីមូលហេតុចំនួនបីដែលនាំឱ្យកើតមានវិសមភាពក្នុងការកាន់កាប់ដីធ្លីមានដូចជា៖ សម្ពាធប្រជាសាស្ត្រ ការតាំងទីលំនៅមិនជាប់លាប់របស់ប្រជាជន និងការកេងចំណេញហួសហេតុក្នុងការទិញលក់ដីធ្លី[47]។

- **សម្ពាធប្រជារាស្ត្រ** ក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ប្រជាជនកើនយ៉ាងលឿនហើយគេបានប៉ាន់ស្មានថាពីឆ្នាំ១៩៩០-១៩៩៨ កំណើនមានទំហំប្រហែល៣០ភាគរយ។ គេឃើញមានគ្រួសារថ្មីៗជាច្រើនបានកើតឡើងហើយមួយចំនួនធំជាអ្នកគ្មានដី។ ដោយសារតែមានពហុកម្មមុខរបរតែមួយកម្រិតតូចរីឯចំនួនប្រជាជនរស់នៅដោយពឹងផ្អែកលើកសិកម្ម បានកើនឡើងគួរឱ្យកត់សម្គាល់នាំឱ្យមានចំនួនប្រជាជនកាន់តែច្រើនឡើងថែមទៀត ដែលត្រូវរស់នៅដោយពឹងផ្អែកលើផ្ទៃដីកសិកម្មផងដែរ។
- **ការតាំងទីលំនៅមិនជាប់លាប់របស់ប្រជាជន** នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ មានប្រជាជនយ៉ាងច្រើនដែលមិនទាន់បានតាំងទីលំនៅជាប់លាប់នៅឡើយ។ ឧទាហរណ៍ ជាក់ស្តែងគឺជនមាតុភូមិនិវត្តន៍ជាច្រើនដែលមកពីព្រំដែនថៃក្នុងឆ្នាំ១៩៩២-១៩៩៣ មិនបានទទួលដីធ្លីដើម ដែលគាត់ធ្លាប់រស់នៅទេ

[45] សៀវភៅសិក្សា និងស្រាវជ្រាវ ច្បាប់ភូមិបាលកម្ពុជា រៀបចំដោយគម្រោងអនុវត្តច្បាប់ភូមិបាលរបស់ធនាគារអភិវឌ្ឍន៍ អាស៊ី រាជធានីភ្នំពេញ ឆ្នាំ២០០៣ ទំព័រ ២៦

[46] សូ សុវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី វ័ន្ធមុនីៈ ការវាយតម្លៃបញ្ហាសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា ការអង្កេតនៅមូលដ្ឋាន ឯកសារពិភាក្សាលេខ២០ វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០០២ ទំព័រ ១៥

[47] សូ សុវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី វ័ន្ធមុនីៈ ការវាយតម្លៃបញ្ហាសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា ការអង្កេតនៅមូលដ្ឋាន ឯកសារពិភាក្សាលេខ២០ វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០០២ ទំព័រ ១៦

ដោយសារដីនៅតំបន់ដែលពួកគាត់តាំងទីលំនៅមានម្ចាស់កាន់កាប់រួចទៅហើយ និងខ្លះជាដីដែលមានមីនហើយជួនកាលមានភាគីផ្សេងៗតវ៉ាជំទាស់។ មានប្រជាជនជាច្រើននៅក្នុងក្រុមនេះ ដែលមិនបានទទួលផលពីការបែងចែកដីធ្លីក្នុងគម្រោងបែងចែកឆ្នាំ១៩៩៨ ហើយត្រូវទៅរស់នៅលើដីធ្លីរបស់សាច់ញាតិដែលជាហេតុមានការពុះចែកដីក្នុងគ្រួសារ និងនាំឱ្យមានកំណើនវិសមភាពដីធ្លីកើតឡើង[48]។

– **ការកេងចំណេញហួសហេតុក្នុងការទិញលក់ដីធ្លី** មានមនុស្សមួយចំនួនតូចដែលធ្វើឱ្យមានកំណើនវិសមភាពក្នុងការកាន់កាប់ដីធ្លី ដោយសារតែការទិញលក់ដី ដើម្បីកេងយកចំណេញហួសហេតុ។ សព្វថ្ងៃមានការទទួលស្គាល់ជាទូទៅថា អត្ថប្រយោជន៍នៃការអភិវឌ្ឍន៍នៅក្នុងទសវត្សរ៍ចុងក្រោយនេះភាគច្រើនបំផុត គឺបានទៅដល់អ្នករស់នៅក្នុងក្រុងភ្នំពេញ ឬទីប្រជុំជនផ្សេងៗទៀត។ ជាមួយគ្នានេះផងដែរដោយសក្តានុពលវិស័យវិនិយោគកម្ពុជានៅមានកម្រិត រួមជាមួយនឹងអស់លទ្ធភាពនៃវិស័យវិនិយោគលើផ្នែកសណ្ឋាគារ និងភោជនីយដ្ឋានប្រជាជនបែរជាមកវិនិយោគលើដីធ្លី ពីព្រោះគ្មានជម្រើសណាផ្សេងទេ។ ដូច្នេះការផ្ទេរដីធ្លីពីប្រជាជនក្រីក្រភាគច្រើននៅក្នុងជនបទទៅឱ្យពួកមានរស់នៅទីក្រុងបានឱ្យក្លាយជាដំណើរការមួយដែលមិនអាចជៀសផុតបានដែលជា ហេតុនាំឱ្យវិសមភាពដីធ្លីកើតឡើង[49]។

## កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា

នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺមានច្បាប់រដ្ឋធម្មនុញ្ញជាច្បាប់កំពូលក្នុងប្រទេស ដែលបានអនុម័តនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ នាសម័យប្រជុំវិសាមញ្ញានីតិកាលទី១។ ក្នុងរដ្ឋធនុញ្ញនេះក៏បានចែងថា គណៈកម្មាធិការប្រជាជន ត្រូវមាននៅគ្រប់គ្រង គ្រប់ឃុំគ្រប់ស្រុក គ្រប់ខេត្ត ដែលបានជ្រើសរើសដោយក្រុមរណសិរ្ស និងអង្គការមហាជន[50]។ ចំពោះការដោះស្រាយវិវាទដីធ្លី មានតុលាការប្រជាជន និងតុលាការយោធា ជាអង្គការជំនុំជម្រះរឿងក្ដីវិវាទ។ ប៉ុន្តែរាល់បញ្ហាដែលទាក់ទង់ទៅនឹងការវិវាទដីធ្លីនោះ មានតែអាជ្ញាធរមូលដ្ឋាន និងប្រធានក្រុមសាមគ្គីបង្កបង្កើនផលដែលតែងតែមានការដោះស្រាយវិវាទជាមួយប្រជាជនដោយប្រកបដោយក្តីមេត្តា និងប្រើប្រាស់នៅនីតិវិធីដោះស្រាយដូចខាងក្រោម៖

[48] Kato ១៩៩៩

[49] សូ សុវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី វ័ត្ថមុនីៈ ការវាយតម្លៃបញ្ហាសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា ការអង្កេតនៅមូលដ្ឋាន ឯកសារពិភាក្សាលេខ២០ វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០០២ ទំព័រ ១៧

[50] រដ្ឋធម្មនុញ្ញ នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៨១ មាត្រា៧២

- **ការចរចា** គឺជាការឆ្លងឆ្លើយគ្នារវាងភាគីពីរ ឬច្រើន ក្នុងគោលបំណងទៅរកការយោគយល់គ្នា ការដោះស្រាយវិវាទ ដើម្បីទទួលបានការព្រមព្រៀងគ្នា ឈានទៅរកអត្ថប្រយោជន៍រួមមួយរបស់គូភាគីចរចានីមួយៗ។
- **ការផ្សះផ្សា** ការណែនាំគូភាគី ដើម្បីរកដំណោះស្រាយវិវាទពាក់ព័ន្ធ និងព្យាយាមពន្យល់ឱ្យមានការព្រមព្រៀងពីភាគីក្នុងការដោះស្រាយជម្លោះ។
- **ការសម្រុះសម្រួល** គឺជាជម្រើសដ៏ល្អបំផុតសម្រាប់មនុស្ស ដោយប្រើនៅសន្តិវិធី និងអហិង្សា តាមរយៈយន្តការសម្រុះសម្រួល។

ជាពិសេសនូវសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា គណៈម្មាភិបាលទូទាំងប្រទេសបានចេញសេចក្ដីសម្រេចចិត្តចំនួន៥៖[51]

១. សេចក្ដីសម្រេចចិត្តស្ដីពី គោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី

២. សេចក្ដីសម្រេចចិត្តស្ដីពី គោលនយោបាយចំពោះកសិកម្ម

៣. សេចក្ដីសម្រេចចិត្តស្ដីពី ការប្រកបរបរអាជីវកម្ម ផលិតកម្មតាមរបៀបវេរប្រវាស់ដៃ

៤. សេចក្ដីសម្រេចចិត្តស្ដីពី គោលនយោបាយចំពោះផលិតកម្ម អាជីវកម្មរូបភាពសិប្បកម្មឧស្សាហ៍កម្មតូចៗ

៥. សេចក្ដីសម្រេចចិត្តស្ដីពី គោលនយោបាយចំពោះការដឹកជញ្ជូន។

## ផ្នែកទី៧៖ ការដោះស្រាយវិវាទសម័យរដ្ឋកម្ពុជា (១៩៨៩-១៩៩៣)

### កថាខណ្ឌទី១៖ របបគ្រប់គ្រងដីធ្លីសម័យរដ្ឋកម្ពុជា និងករណីវិវាទ

ក្រោយជំនួបរវាង សម្ដេច ហ៊ុន សែន និង សម្ដេច សីហនុ នៅខែធ្នូ ឆ្នាំ១៩៨៧ និងឆ្នាំ១៩៨៨ "ការប្រជុំក្រៅផ្លូវការនៅទីក្រុងហ្សាការតា" ប្រទេសឥណ្ឌូណេស៊ី នាំឱ្យមានការរួបរួមរវាងភាគីទំនាស់ទាំងអស់នៅកម្ពុជា ដែលមានអំពាវនាវឱ្យមានការផ្សះផ្សាជាតិ។ នាកិច្ចប្រជុំវិសាមញ្ញនៅថ្ងៃទី២៩-៣០ ខែមេសា ឆ្នាំ១៩៨៩ រដ្ឋសភាបានធ្វើវិសោធនកម្មមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ ដោយប្ដូរឈ្មោះ ប្រទេសកម្ពុជាឱ្យទៅជា "រដ្ឋកម្ពុជា"[52] ។ របបគ្រប់គ្រងដីធ្លីនោះ មានកម្មសិទ្ធិឯកជនត្រូវផ្ដល់ឱ្យតែទៅលើដីលំនៅឋានតែមួយគត់ ហើយដីដែលស្ថិតនៅតំបន់ទីក្រុងត្រូវបានបញ្ញត្តិតាមច្បាប់ដោយឡែក។ តាមច្បាប់នេះរបបកម្មសិទ្ធិអាចផ្ទេរបានតាមរយៈសន្តិកម្ម មតកសាសន៍ កិច្ចសន្យានៃការលក់ ដោយប្រទានកម្ម និងដោយភោគៈ[53]។ រដ្ឋសភាព

[51] ហាប់ ផល្លី ការវិវត្តនៃប្រព័ន្ធគ្រប់គ្រងដីធ្លីនៅកម្ពុជា ខែកញ្ញា ឆ្នាំ២០០៩

[52] ក្រុមប្រឹក្សារដ្ឋ លេខ២៩ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៨៩ ស្ដីពីរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា មាត្រា១

[53] ក្រឹត្យច្បាប់ លេខ១០០ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២ ស្ដីពីច្បាប់ភូមិបាល មាត្រា២

បានអនុម័តច្បាប់ភូមិបាលនៅក្នុងឆ្នាំ១៩៩២ ច្បាប់នេះបានបញ្ជាក់ជាផ្លូវការនូវដំណើរការកែទម្រង់ដីធ្លីដែលបានចាប់ផ្តើមដោយអនុក្រឹត្យលេខ២៥។ ច្បាប់ភូមិបាលនេះមានលក្ខណៈស្រដៀងគ្នាយ៉ាងច្រើនទៅនឹងក្រមរដ្ឋប្បវេណីរបស់កម្ពុជាកាលពីមុនដែលទទួលស្គាល់ការបន្តមរតកបណ្តាំលក់ ធ្វើអំណោយ និងភោគៈដែលជាការផ្ទេរកម្មសិទ្ធិ។ ដើម្បីទទួលបានសិទ្ធិភោគៈនេះ យោងតាមច្បាប់ភូមិបាលកម្ពុជាឆ្នាំ១៩៩២ ត្រង់ផ្នែកទី២ មាត្រា៦១ ដល់៧៦ បានកំណត់ដោយសង្ខេបថា ភោគីត្រូវតែបង្ហាញថាដីភោគៈរបស់ខ្លួន គឺបានមកៈ

- ដោយសន្តិវិធី គឺមិនមានជម្លោះដណ្តើមដីគ្នាកើតឡើង
- ដោយសុចរិត គឺកាន់កាប់ដីភោគៈដោយស្មោះត្រង់
- ដោយមានការដឹងឮជាសាធារណៈ គឺអាជ្ញាធរមូលដ្ឋាន ប្រធានភូមិ ស្រុកខណ្ឌដឹងឮ
- ដោយមិនអាក់ខាន គឺកាន់កាប់លើដីភោគៈយ៉ាងហោចណាស់អស់រយៈពេលប្រាំឆ្នាំ
- និងដោយគ្មានការបន្លំ គឺកាន់កាប់ដីភោគៈដោយមិនបន្លំយកដីរបស់គេ[54]។

ដោយសារការកែប្រែច្បាប់ភូមិបាលឆ្នាំ១៩៩២ គេសង្កេតឃើញមានបញ្ហាចោទឡើងជាច្រើន ដែលប៉ះពាល់ដល់ការអនុវត្តច្បាប់នេះ។ បញ្ហាចោទឡើងនោះ គឺអាជ្ញាធរចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋដូច្នេះប្រជាពលរដ្ឋគ្រាន់តែបានចូលកាន់កាន់ភោគៈនៃដីតែប៉ុណ្ណោះ ហើយស្ថានភាពប្រជាពលរដ្ឋមានការផ្លាស់ប្តូរទីកន្លែងច្រើនដង ដែលពិបាកក្នុងការចូលទៅកាន់តំបន់ទាំងនោះដើម្បីទទួលបានសេវានៃការធ្វើប័ណ្ណកម្មសិទ្ធិពីអាជ្ញាធរជំនាញ។ ចំពោះបញ្ហាចោទឡើងមួយទៀតនោះ គឺអាជ្ញាធរមានការលំបាកក្នុងការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋគ្រប់រូបអំពីកាតព្វកិច្ចតាមផ្លូវច្បាប់ថ្មី ស្តីពីការប្រកាសជូនដំណឹងពីភោគៈរបស់ខ្លួន និងការបង់ពន្ធទៀងទាត់។

ដូច្នេះហើយប្រជាពលរដ្ឋមិនបានទទួលព័ត៌មាន ហើយពួកគាត់មិនអាចទទួលរួមអនុវត្តតាមកាតព្វកិច្ចថ្មីទាំងនេះបានឡើង ដែលជាហេតុនាំឱ្យពួកគាត់មិនអាចទាមទារកម្មសិទ្ធិដីធ្លីដោយផ្អែកលើភោគៈរបស់ពួកគាត់នោះទេ។ ឧបសគ្គដែលគេមើលឃើញចំពោះការអនុវត្តច្បាប់ភូមិបាលឆ្នាំ១៩៩២ ត្រូវបានដោះស្រាយ និងកែប្រែជាបន្តបន្ទាប់រហូតដល់មានការអនុម័តច្បាប់ភូមិបាលថ្មីនៅឆ្នាំ២០០១។

ករណីវិវាទដីធ្លីនូវសម័យរដ្ឋកម្ពុជា គឺបណ្តាលមកពីហេតុការណ៍ដូចខាងក្រោម[55]៖

- ការចូលទន្ទ្រានដីតាមទំនើងចិត្ត ទាំងដីរបស់រដ្ឋ និងឯកជន។ ភាពគ្មានដីធ្លីបណ្តាលឱ្យប្រជាពលរដ្ឋធ្វើចំណាកស្រុក ដើម្បីរកដីទំនេរសង់លំនៅដ្ឋាន។ នៅពេលពួកគេឃើញដីទំនេរមិនមានមនុស្សរស់

[54]រៀបរៀងដោយសាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាក្រកម្ពុជាឆ្នាំសិក្សា២០០៧-២០១១ ទំព័រ១០

[55] ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/២៩៧ ចុះថ្ងៃទី២៦ កុម្ភៈ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ទំព័រ ២២៨

នៅពួកគេចាប់ផ្តើមតាំងទីលំនៅបណ្តោះអាសន្ន តែតាមពិតដីមួយចំនួនមានម្ចាស់កម្មសិទ្ធិរួចទៅហើយគ្រាន់តែម្ចាស់ដីនោះ មិនបានរស់នៅលើដីនោះ។

– ការកាន់កាប់ដីធ្លីមិនមានភាពច្បាស់លាស់របស់ប្រជាពលរដ្ឋ ដោយហេតុថា ពួកគាត់មិនបានបោះបង្គោលព្រំដីជាដើម។

**កថាខណ្ឌទី២៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យរដ្ឋកម្ពុជា**

នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យរដ្ឋកម្ពុជា មានច្បាប់រដ្ឋធម្មនុញ្ញជាបង្គោល ដើម្បីងាយស្រួលក្នុងការដោះស្រាយវិវាទដីធ្លី និងវិវាទបញ្ហាផ្សេងៗទៀត[56]។ ប៉ុន្តែសម័យនោះដែលប្រទេសកម្ពុជារបស់យើងមានការប្រែប្រួលផ្លាស់ប្តូរស្រប ទៅតាមស្ថានការណ៍នយោបាយអន្តរជាតិក្នុងការបញ្ចប់សង្គ្រាមត្រជាក់ពិភពលោក។ ចំណែកប្រទេសកម្ពុជាបានឈ្មោះពីរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជាមកឈ្មោះ "រដ្ឋកម្ពុជា" ដើម្បីឱ្យស្របនឹងរដ្ឋធម្មនុញ្ញមួយដោយបានវិសោធនកម្មស្ទើរតែទាំងស្រុងពីរដ្ឋធម្មនុញ្ញនាឆ្នាំ១៩៨១។ ចំពោះការដោះស្រាយវិវាទដីធ្លី តែងតែយកច្បាប់ភូមិបាលដែល ប្រកាសឱ្យប្រើប្រាស់នាថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ ដើម្បីមកដោះស្រាយ និងពន្យល់ប្រជាពលរដ្ឋឱ្យយល់ច្បាស់លាស់អំពីកម្មសិទ្ធិលើដីធ្លី[57]។ រាល់ការដោះស្រាយនៅសម័យនោះតែងតែមានព្រឹទ្ធាចារ្យជើងចាស់ជាអ្នកដោះស្រាយជាមួយអាជ្ញាធរ ដោយយកច្បាប់ភូមិបាល និងរដ្ឋធម្មនុញ្ញ។ ប៉ុន្តែការដោះស្រាយនោះ វិធីក្រៅប្រព័ន្ធតុលាការមកប្រើប្រាស់ដែលមានលក្ខណៈដូចជា[58]៖

– **ការចរចា** គឺជាល្បិច និងតិចនិចមួយក្នុងការឆ្លងឆ្លើយគ្នារវាងភាគីពីរ ឬច្រើនក្នុងគោលបំណងទៅរកការយោគយល់គ្នា ការដោះស្រាយវិវាទ ដើម្បីទទួលបានការព្រមព្រៀងគ្នា ឈានទៅរកអត្ថប្រយោជន៍រួមមួយរបស់គូភាគីចរចានីមួយៗ។

– **ការផ្សះផ្សា** គឺជានីតិវិធីពន្យល់ណែនាំឱ្យចេះអាធ្យាស្រ័យជាមួយគ្នា និងគ្នាព្រមទាំងឱ្យការស្រឡាញ់គ្នា ជាពិសេសនោះមិនឱ្យប្រជាពលរដ្ឋមានសេចក្តីច្រណែនគ្នា និងលោភ។

– **ការសម្រុះសម្រួល** គឺជាសន្តិវិធី និងអហិង្សា មិនឱ្យប្រជាពលរដ្ឋវាយគ្នា និងមិនឱ្យការខឹង គុំគួនមួម៉ៅជាមួយគ្នាទេ ឱ្យមានសេចក្តីអាណិតអាសូរ និងមេត្តាចិត្ត។

---

[56] រដ្ឋធម្មនុញ្ញ នៃរបបរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើនាឆ្នាំ១៩៨៩

[57] ហាប់ ផល្លី ការវិវត្តនៃប្រព័ន្ធគ្រប់គ្រងដីធ្លីនៅកម្ពុជា ខែកញ្ញា ឆ្នាំ២០០៩

[58] សៀវភៅការដោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការ សាស្ត្រាចារ្យ វង្សី វណ្ណារ៉ា ឆ្នាំ២០០៨-២០០៩

# ជំពូកទី២

## នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យព្រះរាជាណាចក្រកម្ពុជា(១៩៩៣-បច្ចុប្បន្ន)

### ផ្នែកទី១៖ សញ្ញាណទូទៅនៃវិវាទដីធ្លី និងរបបគ្រប់គ្រងដីសម័យព្រះរាជាណាចក្រកម្ពុជា

ដីធ្លីនៅកម្ពុជា បែងចែកជាពីរប្រភេទធំៗ គឺដីរដ្ឋ និងដីឯកជន និងកំណត់ព្រំព្រទល់ឱ្យបានច្បាស់លាស់[59]។ ដោយមានកិច្ចសហប្រតិបត្តិការរបស់អង្គការសហប្រជាជាតិនៅក្នុងឆ្នាំ១៩៩៣ បានជំរុញឱ្យសភាជាតិអនុម័តនូវរដ្ឋធម្មនុញ្ញថ្មីមួយដែលបានប្រកាសយ៉ាងឱឡារិក អំពីការផ្លាស់ប្តូររបបនយោបាយកម្ពុជាមកជាព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងការបង្កើនឱ្យមានរាជរដ្ឋាភិបាលថ្មី មួយតាមបែបលទ្ធិប្រជាធិតេយ្យ។ រដ្ឋធម្មនុញ្ញនេះបានអះអាងជាថ្មីឡើងវិញពីសិទ្ធិបុគ្គលក្នុងការទទួលបាននូវកម្មសិទ្ធិដីធ្លី ប៉ុន្តែសម្រាប់តែប្រជាជនកម្ពុជាប៉ុណ្ណោះ[60]។ បន្ទាប់មកមានការតាក់តែងសេចក្តីព្រាងច្បាប់ភូមិបាលថ្មីជាបន្តបន្ទាប់។ ទីបំផុតច្បាប់ភូមិបាលថ្មីមួយត្រូវបានបង្កើតឡើងដោយព្រះរាជក្រម សនរកម/០៨ /០១/១៤ ចុះនៅថ្ងៃ៣០ ខែសីហា ឆ្នាំ២០០១ ដែលបានដោះស្រាយរាល់ចំណុចទន់ខ្សោយជាច្រើន ដែលមាននៅក្នុងច្បាប់ភូមិបាលឆ្នាំ១៩៩២។ ជាក់ស្តែងនៅក្នុងច្បាប់ថ្មី សិទ្ធិភោគៈបណ្តោះអាសន្ន ដែលធ្លាប់ត្រូវបានចាត់ទុកថាជាមធ្យោបាយសម្រាប់ទទួលបានដីធ្លីត្រូវលុបចោល។ មានតែអ្នកដែលទទួលសិទ្ធិភោគៈស្របច្បាប់ នៅលើចំណែកដីដែលគ្មានអ្នកកាន់កាប់នៅក្នុងពេលនៃការអនុម័តច្បាប់ភូមិបាលថ្មីនេះ តែប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឱ្យបន្តសិទ្ធិកាន់កាប់រហូតគ្រប់រយៈពេលប្រាំឆ្នាំដែលជាលក្ខណៈចាំបាច់ដើម្បីក្លាយជាម្ចាស់កម្មសិទ្ធិស្របច្បាប់[61]។ អ្នកដែលព្យាយាមទាមទារកម្មសិទ្ធិដីធ្លីតាមវិធីភោគៈជាបណ្តោះអាសន្ន លើចំណែកដីណាមួយនៅក្រោយពេលដែលច្បាប់នេះចូលជាធរមាន និងពុំត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិ។ ដូចគ្នានេះដែលប្រការដែលមានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ១៩៩២ តម្រូវឱ្យគ្រួសារនានាជាអ្នកកាន់កាប់ចំណែកដីណាមួយភោគៈនៅមុនពេលចូលធរមាននៃច្បាប់នេះ ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរដើម្បីអាចទទួលបានកម្មសិទ្ធិស្របច្បាប់ត្រូវបានលុបចោលផងដែរ[62]។

ដើម្បីអាចលុបចោលនូវការទាមទារសិទ្ធិភោគៈបណ្តោះអាសន្ន ដែលធ្លាប់បានប្រើប្រាស់ជាមធ្យោបាយទទួលបានកម្មសិទ្ធិស្របច្បាប់ពីមុនច្បាប់ថ្មីនេះ បានបង្កើតនូវលទ្ធភាពក្នុងការរៀបចំដីសម្បទាន

---

[59] សារណាបញ្ចប់ការសិក្សារ ស្តីពី បញ្ហានៃការចូលទន្ទ្រានកាន់កាប់លើដីរដ្ឋ ដែលស្រាវជ្រាវដោយនិស្សិតឈ្មោះ ជិនកេត មេត្តា ដឹកនាំដោយសាស្ត្រាចារ្យ បណ្ឌិត ហាប់ ផល្លី ឆ្នាំសិក្សា២០០៩-២០១៣

[60] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៤៤

[61] ច្បាប់ភូមិបាលកម្ពុជា ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ មាត្រា៣១

[62] ច្បាប់ភូមិបាលកម្ពុជា ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ មាត្រា៦៦

សង្គមកិច្ច។ ទន្ទឹមនិងការដែលរាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចក្នុងទ្រង់ទ្រាយធំក្រុមហ៊ុនធំៗនៅទសវត្សរ៍ឆ្នាំ១៩៩០ នៅក្រោមច្បាប់ថ្មីនេះក៏មានបញ្ញត្តិអំពីដីសម្បទានសង្គមកិច្ចដោយអនុញ្ញាតឱ្យប្រជាពលរដ្ឋដែលគ្មានដីធ្លីដាក់ពាក្យស្នើសុំចំណែកដី ដើម្បីប្រើប្រាស់ជាកន្លែងតាំងទីលំនៅ ឬសម្រាប់ដាំដំណាំចិញ្ចឹមជីវិតដោយឥតគិតថ្លៃ[63]។

ការគ្រប់គ្រងដីធ្លីដោយមានច្បាប់ភូមិបាលថ្មីជាបង្គោល ដើម្បីងាយស្រួលចែងអំពីការអនុវត្តប្រព័ន្ធផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី នៅទូទាំងប្រទេសរួមទាំងប្រព័ន្ធចុះបញ្ជីដីធ្លីងាយស្រួលជាងមុនដែលអាចអនុវត្តបាននៅកម្រិតភូមិ។ ជាងនេះទៅទៀត ចំណុចសំខាន់បំផុតនៃច្បាប់ភូមិបាលឆ្នាំ២០០១ គឺការផ្តល់កិច្ចការពារស្របច្បាប់ដើម្បីធានាសន្តិសុខលើកម្មសិទ្ធិដីធ្លី[64]។ ម្លោះហើយយើងអាចនិយាយបានថា ច្បាប់ថ្មីនេះផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់កាត់បន្ថយទំនាស់ដីធ្លី និងសម្រួលដល់ការគ្រប់គ្រងដីធ្លីដោយបញ្ជាក់ច្បាស់ពីរបបកម្មសិទ្ធិដីធ្លី និងការបង្កើតឱ្យមានកិច្ចការពារទ្រព្យសម្បត្តិរបស់រដ្ឋ[65]។

### កថាខណ្ឌទី១៖ ករណីវិវាទដីធ្លី និងគុណសម្បត្តិនៃរបបចុះបញ្ជីដីធ្លី

#### វាក្យខណ្ឌទី១៖ ករណីវិវាទដីធ្លី

ករណីវិវាទដីធ្លី គឺកើតមានច្រើនណាស់នាពេលបច្ចុប្បន្នកាលនេះ ដោយប្រភេទនៃការវិវាទដីធ្លីនេះនៅតែទទួលស្គាល់ហើយបានចែងក្នុងអនុក្រឹត្យលេខ៤៧ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីឆ្នាំ២០០២ និងអនុក្រឹត្យលេខ៤៧ ស្តីពីនីតិវិធី នៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីឆ្នាំ២០០២ ក្នុងនោះរួមមានវិវាទក្រៅតំបន់វិនិច្ឆ័យ និងវិវាទក្នុងតំបន់វិនិច្ឆ័យ។

**ក. វិវាទក្រៅតំបន់វិនិច្ឆ័យ** សំដៅលើវិវាទដែលកើតឡើងចំពោះដីធ្លីទាំងឡាយណាដែលមិនទាន់បានធ្វើការចុះបញ្ជីសុរិយោដី ហើយជាវិវាទកើតឡើងមិនស្ថិតនៅក្នុងតំបន់ធ្វើការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ។ ជាគោលការណ៍ច្បាប់នៅពេលវិវាទបែបនេះកើតឡើង នីតិវិធីនៃការដោះស្រាយគឺចាប់ផ្តើមដំបូងពីសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ រហូតដល់សុរិយោដីថ្នាក់ជាតិ។ ក្នុងករណីកើតមានវិវាទក្រៅតំបន់វិនិច្ឆ័យនេះត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ក្រុង ស្រុក ខណ្ឌតាមនីតិវិធីច្បាប់[66] ជាពិសេសនោះសំណុំរឿងដែលជាវិវាទក្រៅតំបន់វិនិច្ឆ័យ មានករណីដូចខាងក្រោម[67]៖

---

[63] ច្បាប់ភូមិបាលកម្ពុជា ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ មាត្រា៥១

[64] វេទិការសេដ្ឋកិច្ចកម្ពុជាលើកទី២ ដីធ្លី និង ការអភិវឌ្ឍមនុស្សនៅកម្ពុជា ឯកសារសម្រាប់ការពិភាក្សា លេខ៥ យូអ៊ីន ឌីភី កម្ពុជា ២០០១ ទំព័រ ១១

[65] រៀបរៀងដោយសាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាក្រកម្ពុជាឆ្នាំសិក្សា២០០៧-២០១១ ទំព័រ ១២

[66] អនុក្រឹត្យលេខ៤៨ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ មាត្រា១០

[67] អនុក្រឹត្យលេខ៤៨ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ មាត្រា១០

- ជនម្នាក់ៗទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភាគីតូចមួយចំនួន
- ភាគីម្ខាងនៃវិវាទគឺជាអាជ្ញាធរមានឋានៈខ្ពស់
- ករណីវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ ស្រុក- ខណ្ឌ
- វិវាទដែលពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ។

**ខ. វិវាទក្នុងតំបន់វិនិច្ឆ័យ** គឺជាវិវាទដែលកើតឡើងនៅក្នុងតំបន់ដែលធ្វើការចុះបញ្ជីជាប្រព័ន្ធដោយកំណត់ដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់សុរិយោដី នឹងចេញប្រកាសដោយអភិបាលរាជធានីខេត្ត។ ប៉ុន្តែទោះជាយ៉ាងនេះក្តីក្នុងករណីដែលសំណុំរឿងវិវាទណាមួយ ដែលមិនអាចដោះស្រាយបានសំណុំរឿងនោះត្រូវបានបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ[68]។

### វាក្យខណ្ឌទី២៖ គុណសម្បត្តិនៃរបបចុះបញ្ជីដីធ្លី

គុណសម្បត្តិនៃរបបចុះបញ្ជីដីធ្លី គឺមានសារៈប្រយោជន៍ណាស់សម្រាប់ប្រជាពលរដ្ឋ ព្រោះប្រជាពលរដ្ឋទទួលបានកម្មសិទ្ធិដីធ្លីនោះ អាចពង្រីកមុខរបរកសិកម្ម ឬមុខរបរផ្សេងៗទៀត លើដីកម្មសិទ្ធិនេះដែលជួយជំរុញដល់កំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្របានមួយកម្រិតថែមទៀត។ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់លើវិស័យដីធ្លីជូនពលរដ្ឋ និងបានដាក់ចេញនូវយុទ្ធនាការវាស់វែងដីធ្លី ដើម្បីផ្តល់កម្មសិទ្ធិជូនប្រជាពលរដ្ឋដែលជាគោលនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លីក្នុងគោលបំណងប្រជាពលរដ្ឋទទួលបាននូវគុណសម្បត្តិដូចខាងក្រោម[69]៖

- **សិទ្ធិប្រើប្រាស់** គឺសំដៅទៅលើសិទ្ធិរបស់កម្មសិទ្ធិករក្នុងការប្រើប្រាស់ទ្រព្យដែលជាកម្មសិទ្ធិរបស់ខ្លួនតាមតម្រូវការ ឬដោយសេរី យ៉ាងណាកុំបង្កឱ្យមានការខូចខាតដល់សិទ្ធិកម្មសិទ្ធិរបស់អ្នកដទៃ ឬផ្ទុយទៅនឹងបទប្បញ្ញត្តិច្បាប់ ។
- **សិទ្ធិចាត់ចែង** គឺជាសិទ្ធិរបស់កម្មសិទ្ធិករ តាមនោះរូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់សិទ្ធិមានសិទ្ធិសេរីភាពពេញលេញ ក្នុងការចាត់ចែងផ្ទេរប្រគល់ទ្រព្យរបស់ខ្លួនទៅឱ្យបុគ្គលដទៃផ្សេងទៀតឱ្យចាត់ចែង ឬគ្រប់គ្រងជំនួសយ៉ាងណាកុំឱ្យបំពានទៅលើសិទ្ធិរបស់អ្នកដទៃ ឬប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ដ៏ល្អប្រពៃ ។

[68] អនុក្រឹត្យលេខ៤៨ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ មាត្រា១២

[69] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រ កាលបរិច្ឆេទប្រកាសឱ្យប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា២៧៤

- **សិទ្ធិអាស្រ័យផល** គឺជាសិទ្ធិក្នុងការទាញយកផលប្រយោជន៍ពីទ្រព្យដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនឱ្យអស់លទ្ធភាពតាមដែលអាចធ្វើទៅបាន យ៉ាងណាកុំឱ្យប៉ះពាល់ទៅដល់សិទ្ធិរបស់អ្នកដទៃ និងផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ដ៏ល្អប្រពៃ។

**កថាខណ្ឌទី២៖ របបនៃការចុះបញ្ជីដីកម្មសិទ្ធិ**

របបនៃការចុះបញ្ជីដីកម្មសិទ្ធិ គឺមាននីតិវិធីក្នុងការចុះបញ្ជីដីទៅតាមការស្នើសុំរបស់ម្ចាស់ដី ដែលគេឱ្យឈ្មោះថា ការចុះបញ្ជីដាច់ដោយដុំ នៅតាមកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចប្រកាសឱ្យប្រជាពលរដ្ឋចូលរួមក្នុងការចុះបញ្ជីដីធ្លី តាមការកំណត់របស់រដ្ឋាភិបាល ដែលហៅថា ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ។ ក្រោយពីរបបខ្មែរក្រហមដួលរលំទៅរាល់ប័ណ្ណកម្មសិទ្ធិលើដីធ្លី នៅទូទាំងប្រទេសត្រូវបាត់បង់ទាំងអស់។ ច្បាប់បានកំណត់លុបចោលរាល់របបកម្មសិទ្ធិទាំងអស់ដែលមានមុនឆ្នាំ១៩៧៩។ ដើម្បីរៀបចំកសាងបញ្ជីដីធ្លី និងចេញប័ណ្ណកម្មសិទ្ធិដីធ្លីនៅទូទាំងប្រទេសឡើងវិញ ច្បាប់បានកំណត់បង្កើតនីតិវិធីពិសេសមួយគឺ "**ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ**"។

ការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ គឺជាការចុះបញ្ជីដីធ្លីដែលកើតចេញពីគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលដោយមិនចាំបាច់មានការស្នើសុំពីម្ចាស់ដីឡើយ។ រដ្ឋាភិបាលជាអ្នកកំណត់ជ្រើសរើសភូមិ ឬឃុំណាមួយដែលត្រូវធ្វើការចុះបញ្ជីដីធ្លី។ នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះត្រូវចែកចេញជា៥ដំណាក់កាលសំខាន់ៗ៖

**ដំណាក់កាលទី១ ត្រៀមរៀបចំ** នៅក្នុងដំណាក់កាលនេះ រដ្ឋាភិបាលនឹងត្រូវធ្វើការប្រកាសកំណត់តំបន់វិនិច្ឆ័យថា តើត្រូវធ្វើការចុះបញ្ជីដីធ្លីនៅក្នុងឃុំណាមួយ។ នៅក្នុងដំណាក់កាលនេះ អាជ្ញាធរត្រូវធ្វើការជូនដំណឹងដល់ប្រជាពលរដ្ឋនៅក្នុងឃុំ ឱ្យបានជ្រាបអំពីការចុះបញ្ជីដីធ្លីនេះ ដើម្បីឱ្យប្រជាពលរដ្ឋត្រៀមខ្លួនចូលរួមក្នុងដំណើរការនេះ។ គណៈកម្មការមួយត្រូវបង្កើតឡើង ដើម្បីជួយដល់ដំណើរការនៃការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ។ គណៈកម្មការនេះមានសមាសភាពដូចតទៅ៖

- អភិបាលខេត្ត-ក្រុង ជាប្រធាន
- អភិបាលស្រុក-ខណ្ឌ ជាសមាជិក
- ប្រធានក្រុមបច្ចេកទេសវាស់វែង ជាសមាជិក
- មេឃុំ-ចៅសង្កាត់ ឬតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ ជាសមាជិក
- គ្រប់មេភូមិទាំងអស់ នៅក្នុងឃុំ-សង្កាត់ ជាសមាជិក

– ចាស់ព្រឹទ្ធាចារ្យ ២រូប ដែលស្គាល់ប្រវត្តិដី នៅក្នុងឃុំជាសមាជិក[70]។

**ដំណាក់កាលទី២ វាស់វែង និងកសាងប្លង់សុរិយោដីម្ចាស់ដី** គឺជាអ្នកកំណត់ព្រំជាមួយអ្នកជិតខាង។ ចំណែកមន្ត្រីបច្ចេកទេសគ្រាន់តែជាអ្នកចុះទៅវាស់វែងទៅតាមព្រំដែលចង្អុលបង្ហាញដោយម្ចាស់ដីតែប៉ុណ្ណោះ[71] ។ ដូច្នេះ នៅក្នុងដំណាក់កាលនេះ ការចូលរួមចំណែកពីម្ចាស់ដីមានសារៈសំខាន់ណាស់។ ម្ចាស់ដីក៏ត្រូវត្រៀមនូវឯកសារចាំបាច់មួយចំនួនផងដែរ។ ឯកសារទាំងនេះ រួមមាន សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ សំបុត្រអាពាហ៍ពិពាហ៍ បណ្តាំមរតក សាលក្រមតុលាការ លិខិតទិញ-លក់ ។

**ដំណាក់កាលទី៣ ផ្សព្វផ្សាយ** អាជ្ញាធរត្រូវធ្វើការបិទផ្សាយជាសាធារណៈនូវប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ដើម្បីឱ្យប្រជាពលរដ្ឋពាក់ព័ន្ធអាចធ្វើការត្រួតពិនិត្យ និងតវ៉ាសុំធ្វើការកែប្រែប្រសិនបើមានកន្លែងមិនត្រឹមត្រូវ។ គួរបញ្ជាក់ថា នៅក្នុងដំណើរការចុះបញ្ជីនេះ ប្រសិនបើកើតមានវិវាទណាមួយ ដូចជា វិវាទរឿងព្រំដីជាដើម ភាគីជម្លោះអាចសុំឱ្យគណៈកម្មការរដ្ឋបាលជួយដោះស្រាយ និងសម្រុះសម្រួលឱ្យដោយមិនចាំបាច់ប្តឹងផ្តល់គ្នាទៅដល់តុលាការនោះទេ[72]។

**ដំណាក់កាលទី៤ វិនិច្ឆ័យ និងសម្រេច** ដំណាក់កាលនេះ គឺមានពាក់ព័ន្ធតែជាមួយស្ថាប័នរដ្ឋតែប៉ុណ្ណោះ។ ផុតរយៈពេល៣០ថ្ងៃ ដែលបើកឱ្យមានការតវ៉ាមន្ត្រីមានសមត្ថកិច្ចត្រូវធ្វើការពិនិត្យទៅលើប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីដែលត្រូវចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី។ ដីទាំងឡាយណាដែលមិនជាប់មានទំនាស់ហើយមិនមែនចូលជាដីរបស់រដ្ឋ នឹងត្រូវចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី ហើយប្រធានមន្ទីរភូមិបាលខេត្ត-ក្រុង នឹងចុះហត្ថលេខាលើប័ណ្ណកម្មសិទ្ធិស្ថាពរ[73]។

**ដំណាក់កាលទី៥ ការចែកប័ណ្ណ** គឺជាដំណាក់កាលចុងក្រោយ។ ក្រោយពីអាជ្ញាធរចុះហត្ថលេខាចេញប័ណ្ណហើយ ប័ណ្ណទាំងនេះនឹងត្រូវចែកជូនដល់ម្ចាស់ដីវិញ។ ម្ចាស់ដីត្រូវទៅទទួលប័ណ្ណដោយផ្ទាល់ដៃហើយប័ណ្ណនេះ គឺជាប័ណ្ណកម្មសិទ្ធិជាស្ថាពរនៃម្ចាស់ដីធ្លី[74]។

---

[70] អនុក្រឹត្យលេខ៤៨ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ មាត្រា៧-៨

[71] អនុក្រឹត្យលេខ៤៨ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ មាត្រា៩-១០-១១-១២

[72] អនុក្រឹត្យលេខ៤៨ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ មាត្រា១៣-១៤

[73] អនុក្រឹត្យលេខ៤៨ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ មាត្រា១៤-១៦

[74] អនុក្រឹត្យលេខ៤៨ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ មាត្រា១៦-១៨

**កថាខណ្ឌទី៣៖ របបនៃការចុះបញ្ជីសិទ្ធិប្រត្យក្សផ្សេងទៀតទាក់ទងអចលនវត្ថុនៅក្នុងក្រមរដ្ឋប្បវេណី**

របបនៃការចុះបញ្ជីសិទ្ធិប្រត្យក្សផ្សេងទៀតទាក់ទងអចលនវត្ថុនៅក្នុងក្រមរដ្ឋប្បវេណី គឺត្រូវចុះបញ្ជីនៅស្ថាប័នដែលមានសមត្ថកិច្ច នៅក្នុងរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាល សុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតសៀវភៅទទួលពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើ អចលនវត្ថុ ដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងៗទៀត។ រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលបានទទួលពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចនលវត្ថុត្រូវផ្ញើពាក្យសុំនោះ និងឯកសារពាក់ព័ន្ធទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានីខេត្ត ដែលអចលនវត្ថុតាំងនៅដោយគ្មានការយឺតយ៉ាវ[75]។ ពាក្យដែលសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវធ្វើជាការលាយលក្ខណ៍អក្សរនៅរដ្ឋបាលសុរិយោដីរាជធានីខេត្ត ដែលមានសមត្ថកិច្ចចុះបញ្ជីត្រូវចុះបញ្ជីទៅតាមចំណុច ដែលមាននៅក្នុងពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ឬលិខិតផ្ទុកផ្តាក់[76]។ វិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុមានដូចជា[77]៖

- ឈ្មោះ ឬនាមករណ៍របស់បុគ្គលមានសិទ្ធិចុះបញ្ជី
- គោលបំណង នៃការចុះបញ្ជី
- មូលហេតុ នៃការចុះបញ្ជី និងកាលបរិច្ឆេទ
- ឈ្មោះរបស់ឧបាទេសិក
- ការហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ជាអាទិ៍ ប្រសិនបើមាន
- ចំនួននៃចំណែករបស់ម្ចាស់សិទ្ធិអវិភាគម្នាក់ៗ
- ការសន្យាពិសេស អំពីការលក់សិទ្ធិ ប្រសិនបើមាន (រួមទាំងលក្ខណៈត្រូវចុះបញ្ជី និងការកំណត់ពេល)
- លេខរៀង នៃការចុះបញ្ជី។

ចំណុចពិសេសនូវក្នុងប្រកាអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីមានលក្ខណៈពិសេសចំពោះសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដូចខាងក្រោម៖

- **ចំណុចដែលត្រូវចុះបញ្ជី អំពីសិទ្ធិជួលអចិន្ត្រៃយ៍** សំដៅដល់សិទ្ធិជួលអចលនវត្ថុ រយៈពេលវែងចាប់ពី ១៥ឆ្នាំឡើងទៅ[78]។ សិទ្ធិជួលអចិន្ត្រៃយ៍ពុំមានអានុភាពឡើយ បើមិនបង្កើតឡើងជាលាយលក្ខណ៍

[75] ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ប្រការ៥

[76] ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ប្រការ៦

[77] ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ប្រការ១៤

[78] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា២៤៤

អក្សរ ។ សិទ្ធិជួលអចិន្ត្រៃយ៍ ដែលត្រូវបានបង្កើតឡើង ដោយពុំបានធ្វើជាលាយលក្ខណ៍អក្សត្រូវចាត់ទុកជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល ហើយអាចត្រូវបញ្ឈប់ដោយភាគីនៅពេលណាក៏បាន ដោយផ្អែកតាមបញ្ញត្តិនៃមាត្រា៦១៥ នៃក្រមនេះចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ដែលមិនបានចុះបញ្ជី បញ្ញត្តិនៃមាត្រា៥៨៩នៃក្រមនេះ ត្រូវយកមកអនុវត្តរហូតដល់គ្រប់អំឡុងពេល១៥ឆ្នាំ។ អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍ មានអត្ថិភាព មិនអាចលើសពី៥០ឆ្នាំបានឡើយ។ ប្រសិនបើបានបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ដែលមានអំឡុងពេលលើសពី៥០ឆ្នាំ ត្រូវបន្ថយមកត្រឹម៥០ឆ្នាំ។ សិទ្ធិជួលអចិន្ត្រៃយ៍អាចបន្តសាជាថ្មីបាន ។ ប៉ុន្តែអំឡុងពេលនេះ មិនអាចលើសពី៥០ឆ្នាំឡើយ គិតចាប់ពីថ្ងៃដែលបន្តសាជាថ្មី។ ប្រសិនបើអ្នកជួលអចិន្ត្រៃយ៍ មិនបានបង់ថ្លៃឈ្នួល ដែលបានកំណត់ក្នុងអំឡុងពេល៣ឆ្នាំ អ្នកឱ្យជួលអចិន្ត្រៃយ៍ អាចរំលាយការជួលអចិន្ត្រៃយ៍នោះបាន។ នេះបើយោងតាមក្រមរដ្ឋប្បវេណី មាត្រា២៥០។

- **ចំណុចដែលត្រូវចុះបញ្ជី អំពីផលុបភោគ** គឺជាការបង្កើតតាមលិខិតជាលាយល័ក្ខណ៍អក្សរ ឬមិនតាមលិខិតជាលាយលក្ខ័ណ៍អក្សរបាន។ ចំពោះផលុបភោគដែលមានរដូវប្រមូលផលការស្នើឱ្យរំលត់ត្រូវធ្វើនៅមុនពេលដែលផលុបភោគីចាប់ផ្តើមការងារកសិកម្មសម្រាប់រដូវកាលបន្ទាប់[79]។
- **ចំណុចដែលត្រូវចុះបញ្ជី អំពីសេវភាព** គឺត្រូវតែមានលិខិតជាលាយល័ក្ខណ៍អក្សរ ឬមិនតាមលិខិតជាលាយលក្ខ័ណ៍អក្សរក៏បាន។ កម្មសិទ្ធិករនៃដីបម្រើអាចស្នើសុំឱ្យរំលត់សេវភាពដែលមិនធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរនៅពេលណាក៏បាន។ ករណីដែលការស្នើសុំឱ្យរំលត់មិនបានបញ្ជាក់អំពីពេលរលត់ និងករណីដែលអំឡុងពេលស្នើសុំឱ្យរំលត់រហូតដល់ពេលរលត់ដែលបានបញ្ជាក់នៅក្នុងការស្នើសុំឱ្យរំលត់នោះតិចជាងអំឡុងពេលមួយខែសេវភាពត្រូវរលត់ នៅពេលដែលអំឡុងពេលមួយខែ បានកន្លងហួសគតិចាប់ពីពេលស្នើសុំឱ្យរំលត់[80]។

## ផ្នែកទី២៖ ប្រភេទនៃវិវាទដីធ្លី

មូលហេតុដែលនាំឱ្យមានការវិវាទដីធ្លីនៅក្នុងប្រទេសកម្ពុជារបស់យើង គឺបណ្តាលមកពីការរំលោភយកដី ឬទំនាស់ដែលទាក់ទងទៅនឹងការយកដីទៅបញ្ចាំ ដែលជាហេតុធ្វើឱ្យប្រជាពលរដ្ឋនៅតាមមូលដ្ឋានចាប់ផ្តើមបាត់បង់ដីធ្លីដែលត្រូវបានទៅលើប្រជាជន ឬស្ថាប័នមកពីក្រៅសហគមន៍។ បន្ថែមពីលើនេះទៅទៀតវិវាទដីធ្លីកើតមានឡើងផងដែរ ដោយសារភាពក្រីក្រការបាត់បង់ឯកសារសុរិយោដី ការខ្វះការយល់ដឹងរបស់

[79] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា២៥៨
[80] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា២៨៦

សាធារណជនអំពីក្របខ័ណ្ឌច្បាប់ ការរីករាលដាលផលិតកម្មលើទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ពីគ្រប់ស្រទាប់ប្រជាជន ការផ្តល់ដីសម្បទានសម្រាប់គោលដៅកសិកម្មដោយមិនបានធ្វើការសិក្សាពីផលប៉ះពាល់ទៅលើសង្គម អតុល្យភាពខាងលទ្ធភាពចូលទៅក្នុងទីផ្សារដីការប្រព្រឹត្តអំពើពុករលួយ[81]។

នៅពេលបច្ចុប្បន្ននេះ ប្រជាពលរដ្ឋកំពុងប្រឈមមុខទៅនឹងបញ្ហាវិវាទដីធ្លីរបស់ពួកគាត់មិនថាតិច ឬច្រើននោះទេ។ ដីកម្មសិទ្ធិ ប្រឈមនឹងការរំលោភបំពាន និងដីកាន់កាប់ ប្រឈមនឹងការបណ្តេញចេញ។ បញ្ហាប្រឈមទាំងនេះបាននាំឱ្យប្រជាពលរដ្ឋទទួលរងទុក្ខលំបាកដោយប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃ និងសិទ្ធិសេរីភាពរបស់ពួកគាត់។ ជីវភាពប្រចាំថ្ងៃរងគ្រោះដោយបាត់បង់ការងារ បាត់បង់មុខរបរ ការចំណាយកើនឡើង និងការបាត់បង់ការសិក្សារបស់កូនរបស់គាត់ ព្រោះមានជាប់ពាក់ព័ន្ធក្នុងរឿងក្តីក្តាំង ដូចខាងក្រោម[82]៖

- វិវាទព្រំប្រទល់ដី
- វិវាទលើកេរមត៌ក
- វិវាទលើកម្មសិទ្ធិដោយសារច្បាប់ (ភាពផ្ទុយគ្នារវាងច្បាប់ និងប្រពៃណី)
- វិវាទលើកម្មសិទ្ធិដោយមិនមានការចុះបញ្ជីដីធ្លី
- វិវាទរវាងដីកម្មសិទ្ធិរបស់រដ្ឋ និងដីឯកជន។
- វិវាទលើទ្រព្យសម្បត្តិឯកជន
- វិវាទលើទ្រព្យរួម
- វិវាទលើទ្រព្យរបស់រដ្ឋ។

ប្រការទាំងអស់នេះ ហើយដែលនាំឱ្យយើងអាចធ្វើការបែងចែកនៃវិវាទដីធ្លីនាបច្ចុប្បន្នតាមរយៈតួអង្គនៃវិវាទដែលពាក់ព័ន្ធមានប្រភេទនៃការវិវាទដីធ្លីដូចជា៖ ករណីវិវាទរវាងរូបវន្តបុគ្គលឯកជន និងរូបវន្តបុគ្គលឯកជន ករណីវិវាទរវាងរូបវន្តបុគ្គលឯកជន និង សមូហភាព ករណីវិវាទរវាងនីតិបុគ្គលឯកជន និងនីតិបុគ្គលឯកជន ករណីវិវាទរវាងបុគ្គលឯកជន និងបុគ្គលសាធារណៈ។

**កថាខណ្ឌទី១៖ ករណីវិវាទរវាងរូបវន្តបុគ្គលឯកជន និងរូបវន្តបុគ្គលឯកជន**

ជាធម្មតាទៅហើយ រូបវន្តបុគ្គលឯកជនច្រើនមានជម្លោះទាក់ទងគ្នាទៅនឹងបញ្ហាដីធ្លី នេះក៏ដោយសារតែតម្លៃដីបានឡើងថ្លៃក្នុងទីផ្សារ ហើយម្នាក់ៗចង់មានចង់បានដីកាន់តែធំឡើង ដែលជាមូលហេតុនាំឱ្យមានការពង្រីកព្រំដីប៉ះពាល់ដល់អ្នកជិតខាង។ កាលពីដើមឡើយព្រំដីមិនត្រូវបានកំណត់ឱ្យបានច្បាស់លាស់ទេ ព្រោះ

[81] រាជរដ្ឋាភិបាលកម្ពុជា ឯកសារបឋមក្របខ័ណ្ឌយុទ្ធសាស្រ្តគោលនយោបាយដីធ្លី អនុម័តដោយគណៈមន្ត្រីនាសម័យប្រជុំពេញអង្គថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២ ទំព័រ ២៨

[82] Bebertte Wehrman Land Conflicts A practical guide to dealing with land disputer, GTZ Eschborn 2008.

ពុំទាន់មានដីប្លង់ដីត្រឹមត្រូវ គឺរូបវន្តបុគ្គលឯកជនក្នុងភូមិគ្រាន់តែឯកភាពគ្នាក្នុងការកំណត់ព្រំដីរបស់ខ្លួនតាមរយៈយកវត្ថុអ្វីមួយជាសញ្ញានៃការកំណត់ព្រំដី ដូចជាដើមឈើ ឬការធ្វើរបងឈើជាដើម ដែលជាហេតុនាំឱ្យកើតមានជម្លោះនៅពេលដែលមានការស្នើសុំធ្វើប្លង់សុរិយោដី ឬចុះបញ្ជីសុរិយោដី[83]។

វិវាទដីធ្លីដែលមានជាប់ពាក់ព័ន្ធជាមួយរូបវន្តបុគ្គលឯកជន និងរូបវន្តបុគ្គលឯកជនច្រើនកើតមានឡើងទៅលើការទាមទារដីថ្មីដែលកើតចេញពីមូលហេតុមួយចំនួនដូចជា នៅពេលដែលការកំណត់ព្រំរវាងអ្នកជិតនិងការវាស់វែងដីធ្លី ដើម្បីចុះបញ្ជីយកប័ណ្ណកម្មសិទ្ធិ។

**ឧទាហរណ៍៖**

ជាប្រពៃណី គេតែងតែប្រើរបង ឬបង្គោលព្រំសម្រាប់បញ្ជាក់កម្មសិទ្ធិដីធ្លីហើយ និងអនុវត្តសិទ្ធិលើដីធ្លីនោះទៅតាមទម្លាប់ក្នុងមូលដ្ឋានរបស់រូបវន្តបុគ្គលឯកជន។ ក្នុងករណីខ្លះទៀតព្រំប្រទល់ដីរឹតតែមើលមិនសូវឃើញប៉ុន្តែអ្នកជិតខាងបានដឹងឮ។ ដូច្នេះគេអាចនិយាយថា សិទ្ធិប្រើប្រាស់ដីក្នុងកន្លែងណាមួយមិនបានកំណត់ជាក់លាក់ល្អទេ ប៉ុន្តែអ្នកផងបានស្គាល់យ៉ាងច្បាស់។ ពេលតម្លៃដីធ្លីកើនឡើងខ្ពស់ព្រំប្រទល់នៃការកាន់កាប់ដីដែលមានព្រំប្រទល់ជាប់គ្នាមិនបានកំណត់ច្បាស់លាស់នោះទេ អាចបណ្តាលឱ្យកើតមានវិវាទនៅពេលដែលចាប់ផ្តើមពិភាក្សាគ្នាដើម្បីរកព្រំប្រទល់ឱ្យបានពិតប្រាកដ។ ក្នុងករណីនេះ ភាគីទាំងសងខាងអាចបង្កឱ្យទៅជាវិវាទ ដោយសារការលោភលន់របស់ខ្លួនចង់ឱ្យដីខ្លួនមានទំហំធំមុន ទោះបីជាតិចឬច្រើន ដោយចាប់ផ្តើមពីការបង្ខិតព្រំដីចូលទៅក្នុងដីរបស់អ្នកជិតខាង។ ចំណុចមួយទៀត វិវាទដីធ្លីប្រភេទនេះ អាចបណ្តាលមកពីការផ្តល់ដីធ្លីចំណែកណាមួយរបស់ភាគីម្ខាងឱ្យទៅភាគីម្ខាងទៀតសម្រាប់ស្នាក់នៅ ឬប្រើប្រាស់ជាបណ្តោះអាសន្នតែគ្មានឯកសារគ្រប់គ្រាន់សម្រាប់ជាអំណះអំណាងនោះទេ ក្រោយមកពេលដែលដីមានតម្លៃខ្ពស់ម្ចាស់ដីគេក៏ចង់បានដីនោះមកវិញដើម្បីលក់ តែភាគីដែលបានកាន់កាប់ និងប្រើប្រាស់នោះ បានអះអាងថាខ្លួនបានកាន់កាប់ និងប្រើប្រាស់យូរឆ្នាំមកហើយ ជាពិសេសគឺបញ្ជាក់ថាខ្លួនបានទទួលកម្មសិទ្ធិលើដីធ្លីនោះតាមការឯកភាពពីភាគីម្ខាងទៀត[84]។

**កថាខណ្ឌទី២៖ ករណីវិវាទរវាងរូបវន្តបុគ្គលឯកជន និងសមូហភាព**

ការវិវាទបុគ្គលឯកជន និងសមូភាព គឺជាការវិវាទដែលមានឡើងដោយរូបវន្តបុគ្គល ឯកជនតែម្នាក់និងបុគ្គលច្រើននាក់ដែលរស់នៅតាមសហគមន៍។ ដែលបង្ហាញនូវការឯកភាពនៃសង្គមវប្បធម៌ និងការរស់នៅតាមប្រពៃណី និងការដាំដុះលើដីដែលខ្លួនកាន់កាប់នៅតាមទំនៀមទម្លាប់ នៃការប្រើប្រាស់ជាសមូហភាព។

[83] រៀបរៀងដោយសាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាក្រកម្ពុជាឆ្នាំសិក្សា២០០៧-២០១១ ទំព័រ ៤៣
[84] រៀបរៀងដោយសាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាក្រកម្ពុជាឆ្នាំសិក្សា២០០៧-២០១១ ទំព័រ ៤៣

សមាជិកនៃសហគមន៍ជនជាតិដើមភាគតិចអាចទទួលបាននូវគុណប្រយោជន៍ការធានាសិទ្ធិ និងការការពារដែលរៀបចំឡើងដោយច្បាប់ (ច្បាប់ភូមិបាល) ចំពោះរាល់បុគ្គលដែលឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យនៃវប្បធម៌ និងសង្គមរបស់សហគមន៍។ ដីសហគមន៍ជនជាតិដើមភាគតិច ជាដីដែលសហគមន៍បានរៀបចំវេនិវេសនដ្ឋាន និងប្រកបរបរកសិកម្មប្រពៃណី ដីដែលបានដាំដុះដាក់ស្តែង និងដីដែលបម្រុងទុកចាំបាច់ក្នុងការប្តូរវេនដាំដំណាំដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយគ្មានអាជ្ញាធរណាមួយក្រៅពីសហគមន៍អាចទទួលបានសិទ្ធិពីអចលនវត្ថុរបស់ជនជាតិដើមភាគតិចបានឡើយ[85]។

ចាប់តាំងពីមានវត្តមានរូបវន្តបុគ្គលបានបង្កើតនៅក្រុមហ៊ុនលើដីសម្បទាន បានបង្កឱ្យមានការជួញដូរដីធ្លី នៅក្នុងតំបន់ជនជាតិដើមភាគតិច ហើយបន្តកម្រិតសិទ្ធិជនជាតិភាគតិចលើដីធ្លីប្រពៃណីរបស់ខ្លួនដែលកំពុងប្រើប្រាស់។ ជាក់ស្តែងនៅខេត្តភាគឦសាន ដូចជាខេត្តរតនគិរី និងមណ្ឌលគិរីមានជនជាតិដើមភាគតិចច្រើនលើសលប់រស់នៅ ហើយក៏ឃើញមាននៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែងដែរច្រើនគួរសមផងដែរ។ សហគមន៍ជនជាតិដើមភាគតិចក្នុងតំបន់ទាំងនោះ បានកំពុងតែរងសម្ពាធនៃការផ្ទេរកម្មសិទ្ធិលើដីធ្លីតាមរយៈការដណ្តើមយកដីធ្លី និងការលក់ដីធ្លីដែលមានការបង្ខិតបង្ខំ ឬដោយខុសច្បាប់។ ការផ្តល់សម្បទានដីសេដ្ឋកិច្ចនិងសម្បទានដទៃទៀត គឺជាការផ្ទេរកម្មសិទ្ធិដីធ្លីយ៉ាងឆាប់រហ័សហើយសម្បទានទាំងអស់នោះកំពុងតែគំរាមកំហែងដល់ជីវភាពរស់នៅវប្បធម៌ និងសុខមាលភាពរបស់សហគមន៍ជនជាតិដើមភាគតិច[86]។

**ឧទាហរណ៍៖**

នៅខែមីនា ឆ្នាំ២០០៧ អ្នកស្រុកជនជាតិដើមភាគតិចក្នុងឃុំក្បាលរមាស បានធ្វើបាតុកម្មប្រឆាំងនឹងសកម្មភាពរបស់ក្រុមហ៊ុនក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែងដែលកំពុងតែគំរាមកំហែងយកដីចម្ការ និងសិទ្ធិប្រមូលអនុផលព្រៃឈើរបស់ពួកគេ។ អ្នកស្រុកបានទាមទារឱ្យក្រុមហ៊ុនបញ្ឈប់សកម្មភាពនៅជុំវិញភូមិរបស់ខ្លួន ហើយសូមធ្វើការវាស់វែងព្រំដីរបស់ខ្លួនឱ្យបានច្បាស់លាស់[87]។

ករណីវិវាទខាងលើនេះ ពុំទាន់ដោះស្រាយនៅឡើយទេ ព្រោះព្រំប្រទល់ដីសម្បទានមិនទាន់ត្រូវបានកំណត់នៅឡើយ ទោះបីជាមានការសន្យាពីមន្ត្រីជាន់ខ្ពស់ក៏ដោយ។ ជុំវិញនឹងវិបត្តិដីធ្លីខាងលើនេះគេច្រើនឃើញមានលំនាំនៃការដោះស្រាយជម្លោះរវាងប្រជាពលរដ្ឋជាមួយ នឹងក្រុមហ៊ុនតាមរយៈការរិះរកមធ្យោបាយដោះស្រាយច្រើនដង ដោយមានចេញជាគោលនយោបាយដោះស្រាយមួយចំនួនដូចជា ការដោះដូរយកលុយ

---

85 ច្បាប់ភូមិបាលកម្ពុជា ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ មាត្រា២៥

86 វេទិកានៃអង្គមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាការផ្ទេរកម្មសិទ្ធិដីធ្លីក្នុងសហគមន៍ជនជាតិដើមតិច-ខេត្តរតនគិរី ឆ្នាំ២០០៦

87 តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជាទស្សនៈវិស័យខាងសិទ្ធិមនុស្ស ខែមិថុនា ឆ្នាំ២០០៧ ទំព័រ ២៨ ។

ការជួរយកដីកន្លែងផ្សេងនិងការដាំប្រវាស់ជាមួយគ្នា។ ក្នុងដំណោះស្រាយទាំងនោះ ប្រជាពលរដ្ឋទទួលយកនូវដំណោះស្រាយផ្សេងៗគ្នា ប៉ុន្តែក្រុមហ៊ុននៅតែមានភាពមិនត្រឹមត្រូវក្នុងការវាស់វែងទំហំដីរបស់ប្រជាពលរដ្ឋ ដែលបង្កឱ្យមានវិវាទកាន់តែស្មុគស្មាញមិនចេះចប់។

ម្ល៉េះហើយនាំឱ្យមានការព្រួយបារម្ភជាខ្លាំង ចំពោះដីរបស់សហគមន៍ជនជាតិដើមភាគតិចដែលប្រឈមទៅនឹងដីសម្បទានទៅឱ្យក្រុមហ៊ុនធ្វើឱ្យមានផលប៉ះពាល់ដល់កត្តាពីរសំខាន់គឺ កត្តាបរិស្ថាន និងកត្តាជីវភាព[88]។ កត្តាបរិស្ថានធ្វើឱ្យមានការប្រែប្រួលនូវបរិស្ថានដោយសារតែការកាប់កាប់បំផ្លាញព្រៃឈើ និងការឈូសឆាយ ដែលជាហេតុធ្វើឱ្យបាត់បង់ខ្យល់ បាត់បង់ការទាក់ទាញទឹកភ្លៀងបណ្តាលឱ្យមានបរិយាកាសប្រែប្រួល។ ជាពិសេសក្នុងតំបន់ភូមិភាគឦសាន ប្រែជាអស់ព្រៃ អាកាសធាតុក្តៅហួតហែងគ្មានភ្លៀង ព្រោះការដាំដំណាំសម្រាប់ឧស្សាហកម្មដូចជាកៅស៊ូជាដើម ពុំអាចមានលទ្ធភាពដូចដើមឈើធំៗដែលជាព្រៃនោះឡើយ។ កត្តាជីវភាព ប្រជាពលរដ្ឋបាត់បង់នូវព្រលឹងវិញ្ញាណ ទំនៀមទម្លាប់ ការគោរពជំនឿការភិតភ័យសេចក្តីបារម្ភដក់ជាប់ក្នុងចិត្ត មានជំងឺខាតពេលវេលាបាត់បង់ប្រាក់ចំណូលគ្មានដីបង្កបង្កើនផល។ ក្រុមហ៊ុនបានឈូសឆាយដីព្រៃអារក្សព្រៃ ដែលជាព្រៃរបស់ជនជាតិដើមភាគតិចសម្រាប់ធ្វើការគោរពតាមជំនឿមិនហ៊ានប៉ះពាល់។ ការប្រកាសខាងលើនេះធ្វើឱ្យមានការប្រែប្រួលបរិស្ថាន និងអាចធ្វើឱ្យបាត់បង់អត្តសញ្ញាណរបស់សហគមន៍ជនជាតិដើមភាគតិច[89]។

**កថាខណ្ឌទី៣៖ ករណីវិវាទរវាងនីតិបុគ្គលឯកជន និងនីតិបុគ្គលឯកជន**

ករណីវិវាទដីធ្លី ដែលជាប់ពាក់ព័ន្ធជាមួយនិងនីតិបុគ្គលឯកជន និងនីតិបុគ្គលឯកជនមានតិចតួចទេ។ មូលហេតុគឺ បណ្តាលមកពីការគិតតែផលប្រយោជន៍ឯកជនជាធំពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច រដ្ឋអំណាចមូលដ្ឋាន បុគ្គលិកស្ថាប័នរដ្ឋ យោធា និងមន្ត្រីរាជការមួយចំនួនជាដើម ដែលប្រើប្រាស់នូវមុខតំណែងរបស់ខ្លួនក្នុងអង្គភាពរដ្ឋ បម្រើឱ្យតែប្រយោជន៍ឯកជនរបស់ខ្លួនដោយល្មើសនឹងមនសិការការងារជាបុគ្គលិករដ្ឋភ្លេចអស់កាតព្វកិច្ចបម្រើផលប្រយោជន៍សាធារណៈ និងប្រជាពលរដ្ឋ។ ការគិតគូរតែផលប្រយោជន៍ឯកជននេះបង្កឱ្យមានការមិនសប្បាយចិត្ត និងខឹងសម្បាពីមជ្ឈដ្ឋានប្រជាពលរដ្ឋដែលរងគ្រោះ ហើយនាំឱ្យមានការហើយនាំឱ្យមានវិវាទកើតមានឡើង។

ថ្វីត្បិតតែច្បាប់អនុក្រឹត្យ គោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ដីធ្លីមិនទាន់បានឆ្លើយតបទាំងស្រុងតាមស្ថានភាពបច្ចុប្បន្ន នឹងតម្រូវការជាក់ស្តែងរបស់សង្គមកម្ពុជាក្តី ក៏លិខិតបទដ្ឋាន និងច្បាប់ភាគច្រើនល្មមអាចប្រើប្រាស់សម្រាប់ជាត្រីវិស័យសម្រាប់ធ្វើឱ្យការ

[89] រៀបរៀងដោយសាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាក្រកម្ពុជាឆ្នាំសិក្សា២០០៧-២០១១ ទំព័រ ៣៧

អនុវត្តបានដោយប្រសិទ្ធភាព។ ក៏ប៉ុន្តែផ្ទុយទៅវិញ បញ្ហាដីធ្លីកំពុងតែកើតឡើងពាសពេញផ្ទៃប្រទេសដោយសារតែអសមត្ថភាព កង្វះតម្លាភាព និងអំពើពុករលួយរបស់មន្ត្រីរាជការ និងយោធាឱកាសនិយមមួយចំនួនដែលប្រើប្រាស់អំណាចនិងតួនាទីរបស់ខ្លួនដើម្បីចាប់យកដីពីប្រជាពលរដ្ឋបម្រើផលប្រយោជន៍ឯកជន។ ការចង់មានចង់បានដោយខ្វះមនសិការពីសំណាក់មន្ត្រីរាជការ និងយោធាមួយចំនួនបានបង្កជាវិវាទមានលក្ខណៈស្មុគស្មាញ និងអាចកើតមានអំពើហិង្សា ព្រោះមន្ត្រីទាំងនោះមានការយល់ដឹងនិងអនុវត្តច្បាប់ទម្លាប់តែពួកគេបានបំពានច្បាប់ដោយឃុបឃិតជាមួយនឹងជនលោភលន់មួយចំនួន ឬក្រុមហ៊ុនឯកជនរំលោភយកដីធ្លីរបស់ប្រជាពលរដ្ឋដោយប្រើប្រាស់ទាំងច្បាប់ និងទាំងកាយកម្លាំងប្រដាប់អាវុធជាដើម ក្នុងការបណ្តេញប្រជាពលរដ្ឋចេញ។ វិវាទនេះមានករណីពីរ គឺវិវាទដីធ្លីដែលមានពាក់ព័ន្ធមន្ត្រីរាជការ និងយោធាជាមួយនិងប្រជាពលរដ្ឋដូចខាងក្រោម[90]៖

**ក. វិវាទពាក់ព័ន្ធទៅ នឹងមន្ត្រីរាជការ** ការបំពានយកដីពីសំណាក់អ្នកមានអំណាចមកលើប្រជាពលរដ្ឋទន់ខ្សោយ ច្រើនកើតមានឡើងនៅតំបន់ដែលទើបចាប់ផ្តើមអភិវឌ្ឍន៍ដីថ្មីៗ និងដីដែលទើបមានតម្លៃក្នុងទីផ្សារ។ អ្នកមានអំណាចខ្លះបានបំពានច្បាប់ដោយប្រើមុខនាទីធំៗ នៅក្នុងមន្ត្រីរាជការរបស់ខ្លួនទៅបំពានលើដីប្រជាពលរដ្ឋទន់ខ្សោយដោយអះអាងថាដីដែលប្រជាពលរដ្ឋកំពុងរស់នៅជាដីរបស់ខ្លួន ព្រោះប្រជាពលរដ្ឋទាំងនោះគ្មានប័ណ្ណកម្មសិទ្ធិសម្គាល់ដីរបស់គាត់រស់នៅ។ ផ្ទុយទៅវិញអ្នកមានអំណាចបែរជាមានប័ណ្ណកម្មសិទ្ធិលើដីធ្លីទាំងនោះវិញ។ នេះក៏ដោយសារតែបំពានសិទ្ធិ និងការប្រើប្រាស់មុខតំណែងរបស់ខ្លួនពីសំណាក់មន្ត្រីរាជការមួយចំនួនក្នុងការយកដីរបស់ប្រជាពលរដ្ឋដោយអយុត្តិធម៌ ព្រោះប្រជាពលរដ្ឋទន់ខ្សោយគ្មានសមត្ថភាព និងលទ្ធភាពដើម្បីតតាំងនិងអ្នកមានអំណាចទាំងនោះបានទេ។ ជាក់ស្តែងនៅឆ្នាំ២០០៩ មានករណីវិវាទរវាងប្រជាពលរដ្ឋនិងភាគីមន្ត្រីរាជការចំនួន១២០ករណី ហើយក្នុងចំណោមនោះមាន៣៦ករណី ដែលរាជរដ្ឋាភិបាលបានចេញមុខជាភាគីទំនាស់ជាមួយប្រជាពលរដ្ឋ ដោយដកហូតយកដីធ្វើការអភិវឌ្ឍដើម្បីប្រយោជន៍សាធារណៈ[91]។

**ខ. វិវាទពាក់ព័ន្ធ និងយោធា** ករណីទំនាស់ដីធ្លីដែលកើតមានឡើងដោយយោធាភាគច្រើនគឺដីធ្លីដែលស្ថិតនៅក្នុងតំបន់ដាច់ស្រយាល ដែលពីមុនមកពុំមានអ្នកណាចាប់អារម្មណ៍ និងចង់បានដីទាំងនោះឡើយ។ ជម្លោះដណ្តើមយកដីរវាងប្រជាពលរដ្ឋជាមួយនឹងយោធាបានកើតមានឡើងដោយសារតែរដ្ឋបានផ្តល់សិទ្ធិឱ្យទៅអង្គភាពយោធា ដើម្បីធ្វើការអភិវឌ្ឍន៍តំបន់យោធា ដូចជា ការបោះទីតាំងមូលដ្ឋានអង្គភាពយោធាថ្មីនៅលើដីធ្លី

[90] រៀបរៀងដោយសាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាក្រកម្ពុជាឆ្នាំសិក្សា២០០៧-២០១១ ទំព័រ៣៩-៤០
[91] របាយការណ៍ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៩ សមាគមអាដហុក លេខ៩ ឆ្នាំទី៩ ផ្សាយ ខែមករា ឆ្នាំ២០១០ ទំព័រ ២៨

របស់អ្នកស្រុកជាដើម។ ទន្ទឹមនឹងការយកដីធ្លីធ្វើជាកម្មសិទ្ធិឯកជននោះ រាល់ការអភិវឌ្ឍន៍ដោយយោធាបានធ្វើឱ្យមានការប៉ះពាល់ដល់ប្រជាពលរដ្ឋដែលកំពុងរស់នៅ និងកំពុងតែធ្វើស្រែចម្ការជាច្រើនហិកតាទៀតផងដែរ។

ក្រៅពីមូលហេតុខាងលើនេះ ទំនាស់ក៏អាចកើនឡើងជាមួយនឹងកាន់កាប់ដីមួយចំនួន ដោយយោធានៅនៅពេលមានសង្គ្រាម ជាពិសេសនៅពេលមានសង្គ្រាមជាមួយនិងខ្មែរក្រហម។ ក្រោយពេលដែលខ្មែរក្រហមបានធ្វើសមាហរណកម្មនៅឆ្នាំ១៩៩៧ សន្តិភាព និងសន្តិសុខក៏បានប្រសើរឡើង ប៉ុន្តែខាងយោធានៅតែបន្តការគ្រប់គ្រងលើតំបន់នោះទៀត[92]។ មានដីមួយចំនួនដែលយោធាបានទុកចោលឱ្យនៅទំនេរហើយប្រជាពលរដ្ឋបានមកកាន់កម្ម នឹងធ្វើការដាំដុះតែក្រោយមកយោធាបានទាមទារដីទាំងនោះ ពីប្រជាពលរដ្ឋនោះមកវិញដែរបានបង្កជាជម្លោះកើតឡើង។ ទំនាស់មួយប្រភេទទៀត គឺទាហានជាមួយបុគ្គលិកទាមទារយកដីធ្លីដែលគ្រប់គ្រងដោយអង្គភាពយោធា ដោយបញ្ជាក់ថាអង្គភាពយោធាបានអនុញ្ញាតឱ្យពួកគេរួមទាំងក្រុមគ្រួសារទទួលបាននូវដីដែលខ្លួនធ្លាប់តាំងទីលំនៅបានមកវិញនៅពេលអនាគត។ ជាក់ស្តែងករណីទំនាស់រវាងប្រជាពលរដ្ឋជាមួយ និងភាគីយោធា មានចំនួន៣៨ករណី ហើយទំនាស់ដីធ្លីប្រភេទនេះ ភាគច្រើនបានកើតឡើងនៅតាមព្រំដែនថៃ-កម្ពុជាថៃតែប៉ុណ្ណោះ និងមានមន្ត្រីយោធាមួយចំនួននៅតែទន្ទ្រានយកដីស្រែប្រជាពលរដ្ឋមកធ្វើកម្មសិទ្ធិផ្ទាល់ខ្លួន[93]។

**កថាខណ្ឌទី៤៖ ករណីវិវាទរវាងបុគ្គលឯកជន និងបុគ្គលសាធារណៈ**

ទំនាស់ដីធ្លីរវាងបុគ្គលឯកជន និងបុគ្គលសាធារណៈ កើតមានឡើងអាចបណ្តាលមកពីអ្នកភូមិ ឬរដ្ឋអំណាចមូលដ្ឋាន។ អ្នកភូមិបានកាន់កាប់ដីរបស់រដ្ឋដែលអាជ្ញាធរចោទប្រកាន់ថាជាការកាន់កាប់ដីធ្លីដោយខុសច្បាប់ ហើយមួយទាមទារដីទាំងអស់នោះមកដោយបណ្តេញបុគ្គលឯកជនចេញ។ រីឯបុគ្គលសាធារណៈនៅមូលដ្ឋានត្រូវបានបុគ្គលឯកជនចោទប្រកាន់ ពីបទចោទប្រកាន់ពីការលក់ដីភូមិដែលមិនបម្រើផលប្រយោជន៍ជាសមូហភាពនោះទៅឱ្យក្រុមហ៊ុនឯកជន។ ទំនាស់លើដីធ្លីប្រភេទនេះមានច្រើនរូបភាពដូច[94]៖

- មានទំនាស់នៅកន្លែងខ្លះនៅពេលដែលប្រធានភូមិ ឬប្រធានឃុំ បានលក់ដីភូមិទៅឱ្យក្រុមហ៊ុន ឬបុគ្គលនៅក្រៅឃុំ ដោយគ្មានការពិគ្រោះជាមួយនឹងអ្នកភូមិ។ ឧទាហរណ៍នៅខេត្តកំពតមានគេរាយការណ៍ពីករណីប្រធានឃុំ និងប្រធានភូមិបានលក់ដីធំទៅឱ្យឈ្មួញដោយគ្មានការពិគ្រោះយោបល់

---

[92] សូ សុវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី វិត្ថមុនី Brett Ballared និង Sarthi Achary ការវាយតម្លៃបញ្ហា សង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា ការអង្កេតនៅមូលដ្ឋាន ឯកសារពិភាក្សាលេខ២០ វិទ្យាស្ថានបណ្តុះបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០០២ ទំព័រ ៤១

[93] របាយការណ៍ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៩ សមាគមអាដហុក លេខ៩ ឆ្នាំទី៩ ផ្សាយ ខែមករា ឆ្នាំ២០១០ ទំព័រ ២៨

[94] រៀបរៀងដោយសាស្ត្រាចារ្យ អ៊ិន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាក្រកម្ពុជាឆ្នាំសិក្សា២០០៧-២០១១ទំព័រ៣៨-៣៩

ជាមួយអ្នកភូមិ ឬការមិនបានផ្តល់សំណងប៉ះប៉ូវអ្វីឡើយ[95]។ នៅក្នុងករណីនេះ រដ្ឋអំណាចមូលដ្ឋានទទួលបានផលចំណេញផ្ទាល់ពីការលក់ ចំណែកឯអ្នកភូមិត្រូវបានបាត់បង់លទ្ធភាពប្រើប្រាស់ដីភូមិ។

– ទំនាស់កើតមានឡើងនៅពេលដែលប្រជាពលរដ្ឋបានចាប់យកដីសាធារណៈ ដែលរដ្ឋអំណាចមូលដ្ឋាន ឬអាជ្ញាធរស្រុកបានអះអាងថាមានកម្មសិទ្ធិ។ ឧទាហរណ៍ ទំនាស់នៅស្រុកស្អាង ខេត្តកណ្តាល ទាក់ទងទៅនឹងជនមាតុភូមិនិវត្តន៍មួយក្រុមកាលពីឆ្នាំ១៩៩២ ដែលបានចូលទៅតាំងទីលំនៅដ្ឋានតាមមាត់ព្រែក ឬទន្លេ ដែលត្រូវបានចាត់ទុកជាដីសាធារណៈរបស់រដ្ឋអំណាចមូលដ្ឋាន។ ក្នុងការដោះស្រាយបញ្ហាទាំងនោះ មន្ត្រីស្រុកបានហៅប៉ូលិសមូលដ្ឋានមកដេញជនមាតុភូមិនិវត្តន៍ចេញ ព្រោះគេបានចាត់ទុកថាបានតាំងទីលំនៅដោយខុសច្បាប់នៅលើដីរបស់ដីដែលជាប់ទាក់ទិន។ បញ្ហាបែបនេះកាន់តែស្មុគស្មាញនៅពេលដែលព្រំប្រទល់រវាងភូមិ និងការគ្រប់គ្រងដោយសារតែអ្នកនៅក្នុងសហគមន៍មិនត្រូវបានកំណត់ច្បាស់លាស់នោះទេ ព្រោះវាជាទម្លាប់មួយរបស់ប្រជារដ្ឋកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៩មក រដ្ឋមិនបានទទួលស្គាល់នូវសិទ្ធិលើកម្មសិទ្ធិដីធ្លីទេ ដូចនេះប្រជាពលរដ្ឋអាចទៅរស់នៅកន្លែងណាក៏បានដោយមិនមានលិខិតស្នាម[96]។ ប៉ុន្តែបច្ចុប្បន្នកម្មសិទ្ធិដីធ្លីត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញកម្ពុជាតាំងពីឆ្នាំ១៩៩៣ និងឈប់ទទួលស្គាល់សិទ្ធិកាន់កាប់ដីភោគៈដែលមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ២០០១[97]។

## ផ្នែកទី៣៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីសម័យព្រះរាជាណាចក្រកម្ពុជា

### កថាខណ្ឌទី១៖ នីតិវិធីនៃការដោះស្រាយវិវាទដីធ្លីតាមប្រពៃណី

ការដោះស្រាយតាមបែបប្រពៃណី ត្រូវបានប្រើប្រាស់នៅកម្រិតមូលដ្ឋាន ដើម្បីដោះស្រាយរាល់ទំនាស់ដែលកើតមានឡើងទាក់ទងនឹងអ្នកជិតខាង ឬសាច់ញាតិនៅក្នុងមូលដ្ឋាន។ ចំពោះវិវាទដែលទាក់ទងទៅនឹងបញ្ហាដីធ្លីនៅតាមមូលដ្ឋានគេច្រើនឃើញប្រជាជនកម្ពុជាតែងយកវិធីដោះស្រាយតាមប្រពៃណីមកដោះស្រាយបញ្ហាទាំងអស់នោះ មុនឈានទៅដល់ការដោះស្រាយតាមផ្លូវការ។ ការដោះស្រាយតាមវិធីបែបនេះ ជាទម្លាប់ដែលភាគីយល់ឃើញពីផលវិបាកនៃការដោះស្រាយតាមផ្លូវតុលាការដូចជា៖

---

[95] សូ.សូវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី រ័ត្នមុនី Brett Ballared និង Sarthi Achary ការវាយតម្លៃបញ្ហា សង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា ការអង្កេតនៅមូលដ្ឋាន ឯកសារពិភាក្សាលេខ២០ វិទ្យាស្ថានបណ្តុះបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០០២ ទំព័រ ៤១

[96] សូ សូវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី រ័ត្នមុនី Brett Ballared និង Sarthi Achary ការវាយតម្លៃបញ្ហា សង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា ការអង្កេតនៅមូលដ្ឋាន ឯកសារពិភាក្សាលេខ២០ វិទ្យាស្ថានបណ្តុះបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០០២ ទំព័រ ៤១

[97] រៀបរៀងដោយសាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាក្រកម្ពុជាឆ្នាំសិក្សា២០០៧-២០១១ ទំព័រ ៣៩

- រឿងក្តីនៃវិវាទដីធ្លី ភាគច្រើនត្រូវការពេលវេលាជាច្រើនក្នុងការជំនុំជម្រះ
- ការតម្កល់ទុកឥតចាត់ការនៃរឿងក្តីបានអូសបន្លាយពេលវេលា ដែលធ្វើឱ្យភាគីវិវាទច្រើនស្ថិតនៅក្នុងស្ថានភាពលំបាកនៃការយកផលពីដីធ្លីមានវិវាទនោះ
- ភាពដាច់ស្រយាលឆ្ងាយពីតុលាការ ដែលធ្វើឱ្យភាគីវិវាទពិបាកធ្វើដំណើរទៅវិញទៅមក និងពិបាកទទួលបាននូវព័ត៌មានពីតុលាការ
- ការចំណាយទៅលើប្រាក់ប្រដាប់ក្តី និងមេធាវី ដែលជាហេតុនាំឱ្យប្រជាជនមូលដ្ឋានពុំមានលទ្ធភាពគ្រប់គ្រាន់លើដំណើរការក្តីបាន
- ប្រព័ន្ធតុលាការមាននីតិវិធីស្មុគស្មាញច្រើនថ្នាក់ ដែលធ្វើឱ្យភាគីនៃវិវាទមិនអាចមិនអាចមានសមត្ថភាពស្វែងយល់ដឹងពីដំណើរការកាត់ក្តីបានទាំងអស់
- សេចក្តីសម្រេចរបស់តុលាការ ច្រើនកាត់ឱ្យឈ្នះនិងចាញ់ ឬបង្គាប់ឱ្យបង់សំណងខូចខាតដល់ភាគីម្ខាងនៃវិវាទ ដែលបណ្តាលឱ្យមានការខាតបង់ទាំងស្រុងចំពោះភាគីម្ខាងទៀត ហើយអាចជះឥទ្ធិពលជាអវិជ្ជមានដល់ទំនាក់ទំនងនងរវាងភាគីវិវាទ។

ដោយសារមូលហេតុទាំងអស់នេះហើយ បានជាវិវាទដីធ្លីដែលភាគច្រើនកើតនៅតាមមូលដ្ឋាន ឬតាមទីជនបទតែងយកវិវាទដោះស្រាយបែបប្រពៃណីមកអនុវត្ត ព្រោះវាផ្តល់ផលចំណេញច្រើន ដូចជាចំណេញពេលវេលាមិនចាំបាច់ចំណាយសោហ៊ុយលុយកាក់ទៅលើតុលាការ-មេធាវី ការធ្វើដំណើរទៅវិញទៅមក និងអាចទៅនឹងអាចនៅរក្សាការរាប់អានគ្នារវាងភាគីនៃជម្លោះបានទៀត។ តែទោះបីជាយ៉ាងណាក៏ដោយការអនុវត្តតាមប្រព័ន្ធដំណោះស្រាយបែបប្រពៃណីនេះ ក៏មានផលវិបាកច្រើនផងដែរ ព្រោះការដោះស្រាយមិនអនុវត្តតាមបច្ចេកទេស និងច្បាប់ ដែលជាហេតុនាំឱ្យភាគីនៃវិវាទណាមួយអាចធ្វើការបដិសេធ ឬមិនគោរពតាមសេចក្តីសម្រេចដែលកំណត់នៅក្នុងដំណោះស្រាយខាងលើហើយអាចឈានដល់ការប្រើប្រាស់អំពើហិង្សា។ វិធីដែលគេយកមកដោះស្រាយ មានដូចជាការដោះស្រាយដោយខ្លួនឯងរវាងភាគីដែលមានជម្លោះ ការពឹងផ្អែកលើការសម្របសម្រួលដោយតតិជននៅក្នុងភូមិវត្តមានអាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយជម្លោះ និងការដោះស្រាយដោយផ្អែកទៅលើជំនឿ និងវត្ថុស័ក្តិសិទ្ធិ[98]។

**វាក្យខណ្ឌទី១. ការចរចាទ្វេរភាគី**

នៅពេលមានវិវាទដីធ្លីកើតមានឡើង ជាដំបូងភាគីនៃវិវាទតែងតែព្យាយាមដោះស្រាយដោយខ្លួនឯងសិនមុនឈានដល់ការស្វែងរកអន្តរាគមន៍ពីតតិយជន ឬអាជ្ញាធរមូលដ្ឋាន ឬក៏តុលាការ។ ការដោះស្រាយ

[98] រៀបរៀងដោយសាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាក្រកម្ពុជាឆ្នាំសិក្សា២០០៧-២០១១ ទំព័រ ២១

ដោយភាគីវិវាទ ធ្វើឡើងតាមរយៈការចរចាដោយផ្ទាល់នៅចំពោះមុខគ្នាដើម្បីស្វែងរកចំណុចស្រុះស្រួលគ្នា ហើយបង្កើតនូវកិច្ចព្រមព្រៀងស្រុះស្រួលជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខាទទួលស្គាល់ទាំងសងខាង។ តាមធម្មតា ដំណោះស្រាយបែបនេះតែងតែអនុវត្តនូវគោលការណ៍ឈ្នះឈ្នះ ដោយផ្អែកតាមឆន្ទៈចរចាដើម្បីឈានដល់ការសម្រេចបាននូវដំណោះស្រាយប្រកបទៅដោយការពេញចិត្តទាំងសងខាង។ ដំណោះស្រាយដែលភាគីដែលគូភាគីអាចពេញចិត្តទទួលយកទាំងអស់គ្នាបាន វាមិនមែនមានតែការបែងចែកគ្នានូវចំណែកដីដែលមានវិវាទនោះទេ ប៉ុន្តែវាអាចជាការយល់ដឹងពីសេចក្តីត្រូវការរបស់ភាគីម្ខាងៗ ឬការផ្តល់ឱ្យភាគីម្ខាងទៀតនូវវត្ថុអ្វីផ្សេងក្រៅពីដី ដូចជាលុយ ផលដំណាំមួយចំណែកលទ្ធភាពប្រើប្រាស់ដីមួយរយៈ ឬយកដីនៅកន្លែងផ្សេងមកជំនួសជាដើម។ តាមរយៈការចរចាដើម្បីដោះស្រាយដោយភាគីវិវាទផ្ទាល់បានផ្តល់អត្ថប្រយោជន៍សំខាន់ៗដូចជា៖

- ការចរចាចំណាយអស់ប្រាក់តិចជាងដោយមិនមានបង់ប្រាក់ប្រដាប់ក្តី ឬមានថ្លៃចំណាយផ្សេងៗ
- ការចរចាធ្វើឡើងជាឯកជន ដោយមិនចាំបាច់មានការចូលរួមពីតុលាការ គ្មានអ្នកសារព័ត៌មាន និងគ្មានអ្នកដទៃទៀតចូលរួមក្រៅពីភាគីនៃវិវាទ
- ការចរចាមានសក្តានុពលនៅក្នុងការដោះស្រាយបញ្ហាបានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព គឺបញ្ហាអាចត្រូវបានដោះស្រាយភ្លាមឱ្យតែភាគីវិវាទឈានការស្រុះស្រួលគ្នាដោយមិនត្រូវរង់ចាំសវនាការរបស់តុលាការក្នុងការធ្វើសេចក្តីសម្រេចឡើយ
- ភាគីវិវាទជាអ្នកគ្រប់គ្រងយ៉ាងពេញលេញទៅលើដំណើរការ នៃការបញ្ចប់នៃការចរចា ហើយគ្មានការបង្ខំភាគីណាមួយឱ្យចូលក្នុងដំណើរការចរចា ឬការស្រុះស្រួលណាមួយដោយគ្មានការព្រមព្រៀងពីភាគីនោះឡើយ
- ការចរចាផ្តល់លទ្ធផលដល់ពួកគេក្នុងការរិះរកការស្រុះស្រួលគ្នា ហើយអាចរក្សានូវទំនាក់ទំនងដែលពួកគេមាន តាមរយៈការស្វែងរកដំណោះស្រាយណាមួយដែលអាចទទួលបានចំពោះភាគីទាំងសងខាង
- ការស្រុះស្រួលតាមរយៈការចរចាលើរឿងក្តី អាចត្រូវបានកត់បញ្ចូលក្នុងនីតិវិធីតុលាការនៅចំពោះមុខចៅក្រម ហើយនឹងអាចអនុវត្តបានដូចសាលក្រមដែរ[៩៩]។

ទោះបីជាយ៉ាងនេះក្តី ការអនុវត្តតាមនីតិវិធីចរចាដោយភាគីវិវាទផ្ទាល់ បានប្រឈមនឹងគុណវិបត្តិមួយចំនួន។ តាមរយៈការចរចា ភាគីម្ខាងអាចពន្យារពេលដំណើរការប្រសិនបើខ្លួនចង់ ហើយក៏គ្មានវិធីអ្វីអាចបង្ខំឱ្យ

[99] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា ២២២

ភាគីណាមួយអាចឱ្យពន្លឿនសកម្មភាពបានឡើយ។ ការធ្វើបែបនេះជានេះជាវិធីដែរ អាចប្រើសម្រាប់ពន្យារបញ្ហា ឬគេចវេះពាក្យបណ្តឹងនៅតុលាការ។ម្យ៉ាងទៀត នៅពេលដែលភាគីម្ខាងប្រកាន់ជំហរមិនសមហេតុផលនៅក្នុងការចរចា ដំណើរការនៃការចរចានិងមានលក្ខណៈយឺតយ៉ាវហើយបង្ខិនពេលវេលាទៀតផង។ ជាចំណុចសំខាន់នៃគុណវិបត្តិនៃការចរចា គឺនៅត្រង់ថាទោះបីជាភាគីទាំងសងខាងបានឯកភាពគ្នាលើកិច្ចព្រមព្រៀងស្រុះស្រួលមួយដែលបានសរសេរជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខាយ៉ាងណាក៏ដោយ ក៏ភាគីណាមួយអាចមិនគោរពតាមលក្ខខណ្ឌនៃការស្រុះស្រួលនោះបានដែរ។ ដោយសារតែការស្រុះស្រួលនោះ គ្រាន់តែជាកិច្ចព្រមព្រៀងតាមរយៈការចរចា ភាគីម្ខាងទៀតគ្មានវិធីដោយផ្ទាល់ក្នុងការដាក់ឱ្យអនុវត្តដូចតាមផ្លូវតុលាការបានឡើយ។ ជាលទ្ធផល ភាគីនោះអាចនៅតែត្រូវដាក់ពាក្យប្តឹងទៅតុលាការ ដោយត្រូវរង់ចាំក្នុងរយៈពេលយូរដើម្បីអនុវត្តកិច្ចព្រមព្រៀងស្រុះស្រួល។ ប្រសិនបើការពន្យារពិភាក្សា ចរចាគ្នាដោយសន្តិវិធីមិនអាចដោះស្រាយវិវាទនោះបានទេភាគីនៃវិវាទតែងតែទៅពឹងពាក់នរណាម្នាក់នៅក្នុងភូមិ ឬមូលដ្ឋានមកជួយដោះស្រាយឱ្យតាមការព្រមព្រៀងរបស់ភាគីជម្លោះនោះ[100]។

## វាក្យខណ្ឌទី២. ការផ្សះផ្សា និងការសម្រុះសម្រួលតាមរយៈអាជ្ញាធរដែនដី

ជាធម្មតាមេភូមិ និងមេឃុំគឺជាអ្នកដែលមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់គាត់។ នៅពេលវិវាទរវាងប្រជាពលរដ្ឋកើតមានឡើង អាជ្ញាធរថ្នាក់ភូមិ ឃុំ-សង្កាត់ តែងតែបានទទួលព័ត៌មានចូលរួមផ្សះផ្សាសម្រុះសម្រួល និងដោះស្រាយមុនគេបង្អស់ ដោយសារតែស្ថិតនៅក្នុងដែនដីរបស់ឃុំ-សង្កាត់នោះ។ ទាក់ទងទៅនឹងការដោះស្រាយវិវាទដីធ្លី វត្តមានរបស់អាជ្ញាធរមូលដ្ឋានបានដើរតួនាទីសំខាន់ជាស្ពានចម្លង រវាងយន្តការក្រៅផ្លូវការក្នុងសង្គម និងរចនាសម្ព័ន្ធផ្លូវការរបស់រដ្ឋ[101]តាមរយៈការប្រើប្រាស់ប្រពៃណី និងទំនៀមទម្លាប់របស់មូលដ្ឋានផ្ទាល់ ដើម្បីដោះស្រាយទំនាស់រវាងអ្នកជិតខាង ឬនៅក្នុងគ្រួសារហើយក្នុងពេលជាមួយគ្នានេះក៏តំណាងឱ្យអាជ្ញាធរស្របច្បាប់របស់រដ្ឋាភិបាលផងដែរ។ បន្ថែមពីរឿងនេះទៅទៀត អាជ្ញាធរមូលដ្ឋានមានកាតព្វកិច្ចចម្បងជូនដំណឹងអំពីច្បាប់ និងវិធានការគតិយុត្តិដោះស្រាយវិវាទដីធ្លីផ្សេងៗដោយភាគីដែលមានជម្លោះឱ្យបានយល់ដឹងហើយក៏អាចជួយរៀបចំឯកសារ និងការដាក់ពាក្យបណ្តឹងទៀតផង។ ជាប្រយោជន៍ដល់រឿងក្តីនៃវិវាទការដឹងឮរបស់អាជ្ញាធរថ្នាក់មូលដ្ឋានអាចផ្តល់ជាសក្ខីកម្មតាមផ្លូវតុលាការ នឹងអាចនាំព័ត៌មានទៅអាជ្ញាធរថ្នាក់លើតាមរយៈការលើកសំណើដំណោះស្រាយជាដើម។

---

[100] រៀបរៀងដោយសាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីនៅព្រះរាជាណាក្រកម្ពុជាឆ្នាំសិក្សា២០០៧-២០១១ទំព័រ ២៣

[101] សូ សូវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី វ័ត្ថមុនី Brett Ballared និង Sarthi Achary ការវាយតម្លៃបញ្ហា សង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា ការអង្កេតនៅមូលដ្ឋាន ឯកសារពិភាក្សាលេខ២០ វិទ្យាស្ថានបណ្តុះបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០០២ ទំព័រ ៤២

### វាក្យខណ្ឌទី៣. ការដោះស្រាយវិវាទដោយពឹងផ្អែកលើជំនឿ និងវត្ថុស័ក្តិសិទ្ធិ

ជាទំនៀមទម្លាប់ទៅហើយ ដែលប្រជាពលរដ្ឋខ្មែរមានជំនឿលើអរូបិយក្នុងការដោះស្រាយបញ្ហា ឬទំនាស់អ្វីមួយក្នុងសហគមន៍មូលដ្ឋានរបស់ពួកគាត់។ ប្រជាពលរដ្ឋខ្មែរតែងតែប្រារព្ធពិធី ដូចជាការស្បថស្បែ ការបន់ស្រន់ បួងសួង និងដាក់បណ្ដាសាជាដើម នៅចំពោះមុខវត្ថុស័ក្តិសិទ្ធិដែលមានបារមីក្នុងសហគមន៍របស់ខ្លួនរៀងៗខ្លួន។ ជាក់ស្ដែងវិធីនេះក៏បានយកមកអនុវត្តផងដែរក្នុងការផ្ដល់សក្ខីកម្មរបស់សាក្សីក្នុងតុលាការ ដែលតម្រូវឱ្យសាក្សីមុននឹងផ្ដល់សក្ខីកម្មត្រូវស្បថជាមុនសិន[102]។ នៅក្នុងជម្លោះដីធ្លីបច្ចុប្បន្នប្រជាជនខ្មែរនៅតាមសហគមន៍មួយចំនួន ជាពិសេសនៅសហគមន៍ជនជាតិភាគតិច នៅតំបន់ព្រៃសានដែលជឿលើអារុក្ខអារក្សអ្នកតាព្រៃភ្នំបានប្រារព្ធពិធីបួងសួង និងដាក់បណ្ដាសាបន្ទាប់ពីស្វែងរកអន្តរាគមន៍តាមផ្លូវច្បាប់ និងអ្នកមានអំណាចជាច្រើនលើកច្រើនសារមកតែមិនបានសម្រេច។ ជាក់ស្ដែងប្រជាជនក្នុងតំបន់បឹងកក់ក៏ធ្លាប់បានរៀបចំពិធីដាក់បណ្ដាសានេះ ឡើងដើម្បីដាក់បណ្ដាសាទៅលើអ្នកដែលបានរឹបអូសយកដីធ្លីរបស់ពួកគាត់។ ហើយការរៀបចំពិធីនេះទៀតសោត ពុំត្រូវបានហាមឃាត់ដោយអាជ្ញាធរមូលដ្ឋាននោះទេ ព្រោះវាជាសិទ្ធិបញ្ចេញមតិរបស់ប្រជាពលរដ្ឋ។

ការប្រារព្ធនេះ មានគោលបំណងបួងសួងសុំសេចក្ដីសុខសុំឱ្យឈ្នះលើអ្នកដែលមានបំណងចង់បានដីរបស់ពួកគាត់នឹងដាក់បណ្ដាសាដល់ជនទាំងនោះ។ ទោះបីជាយ៉ាងណាក៏ដោយមានការព្រួយបារម្ភចំពោះការប្រារព្ធពិធីនេះថា ការបួងសួង និងដាក់បណ្ដាសាគ្រាន់តែជាវិធីអរូបិយមួយតែប៉ុណ្ណោះវាមិនមែនជាដំណោះស្រាយនៃបញ្ហានោះទេ កូនសោសំខាន់ក្នុងការដោះស្រាយវិវាទដីធ្លីតាមរយៈផ្លូវតុលាការ និងក្រៅប្រព័ន្ធតុលាការប៉ុណ្ណោះ[103]។

### វាក្យខណ្ឌទី៤. គុណសម្បត្តិ និងគុណវិបត្តិនៃការដោះស្រាយវិវាទដីធ្លីតាមប្រពៃណី

ជាទំនៀមទម្លាប់របស់ប្រជាពលរដ្ឋខ្មែរទៅហើយ ក្នុងការដោះស្រាយបញ្ហា ឬទំនាស់អ្វីមួយក្នុងសហគមន៍មូលដ្ឋានរបស់ពួកគាត់។ តែងតែមានអាជ្ញាធរមូលដ្ឋានចេញមុខជួយដោះស្រាយវិវាទដីធ្លីទៅតាមប្រពៃណី ដើម្បីជួយសម្រុះសម្រួលប្រជាពលរដ្ឋឱ្យសេចក្ដីចេះអាណិតអាសូរគ្នា និងមានការយល់ដឹងពីផលប្រយោជន៍ខ្លឹមសារជាច្រើនសម្រាប់ប្រជាពលរដ្ឋដូចជា[104]៖

---

[102] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ឧបសម្ព័ន្ធ នីតិវិធីក្នុងការធ្វើសម្បថ

[103] ទស្សនៈរបស់លោក ផៃ សូវេត មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់អង្គការសិទ្ធិមនុស្សនៅពេលផ្ដល់បទសម្ភាសន៍ឱ្យវិទ្យុបារាំង ចុះថ្ងៃអាទិត្យ ទី០៣ ខែតុលា ឆ្នាំ២០២១០

[104] សៀវភៅសិក្សាស្ដីពីទស្សនាទានសំខាន់ៗ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា ទំព័រ ១៦

- **គុណសម្បត្តិ**
  - **សន្សំថែការចំណាយ** ការចរចាបែបមិនសូវចំណាប្រាក់ច្រើនទេ ពីព្រោះមានព្រឹទ្ធាចារ្យចាស់ទុំក្នុងភូមិ និងអាជ្ញាធរមានសមត្ថកិច្ចជួយដោះស្រាយព្រមទាំងជួយផ្សះផ្សាគ្នា ដើម្បីឱ្យមានការយល់ព្រមទាំងសងខាងអំពីដីធ្លី។
  - **ល្បឿន** វិធីសាស្ត្រនៃការសម្រុះសម្រួលតាមប្រពៃណីនេះធ្វើឱ្យភាគីទាំងសងខាងមិនចំណាយពេលច្រើនក្នុងការដោះស្រាយវិវាទដីធ្លី។ ការដោះស្រាយតាមប្រពៃណីពេលខ្លះមានសក្តានុពលណាស់ក្នុងការដោះស្រាយបញ្ហាបានយ៉ាងច្រើន ឆាប់រហ័ស និងមានប្រសិទ្ធភាព។
  - **ការរក្សាទំនាក់ទំនងគ្នា** ចិត្តសាស្ត្រនៃដោះស្រាយតាមប្រពៃណីនេះ មានត្រូវឱ្យមនុស្សចេះមានការយល់អធ្យាស្រ័យគ្នាទៅវិញទៅមកដោយគិតថា មានធម៌នៅក្នុងចិត្តដើម្បីប្រតិបត្តិឱ្យបានល្អហើយត្រូវមាននៅមេត្តា ករុណា មុទិតា និងឧបេក្ខាជាដើម។ ការពន្យល់បែបនេះធ្វើឱ្យមនុស្សមានសេចក្តីស្រឡាញ់គ្នាចេះជួយសង្គ្រោះគ្នា ហើយមានទំនាក់ទំនងល្អជាគ្នាដោយមិនប្រកាន់ចំពោះការវិវាទរឿងដីធ្លី ហើយការស្រុះស្រួលទៀត។
- **គុណវិបត្តិ**
  - **ខាតពេលវេលា** បើប្រសិនមិនព្រមទាំងការដោះស្រាយវិវាទបែបប្រពៃណីនេះទេ ត្រូវដាក់ពាក្យបណ្តឹងអាជ្ញាធរមានសមត្ថកិច្ចដើម្បីដោះស្រាយលើកវិវាទ។ ជាពិសេស ភាគីមានការខាតពេលវេលាដើម្បីរងចាំការដោះស្រាយ និងមានការចំណាយប្រាក់មួយចំនួនទៀត។
  - **សេចក្តីសម្រេច** ព្រឹទ្ធាចារ្យចាស់ទុំនូវក្នុងភូមិ និងអាជ្ញាធរមូលដ្ឋានគ្មានសិទ្ធិសម្រេចលើកការវិវាទដីធ្លីទេ បានត្រឹមតែសម្រុះសម្រួលគ្នាតែប៉ុណ្ណោះ។

## កថាខណ្ឌទី២៖ ការដោះស្រាយវិវាទដីធ្លីតាមរយៈគណៈកម្មការសុរិយោដី

### វាក្យខណ្ឌទី១. គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ

គណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ គឺជាស្ថាប័នដោះស្រាយវិវាទដីធ្លីថ្នាក់ទាបជាងគេបង្អស់ក្នុងចំណោមគណៈកម្មការសុរិយោដីទាំងបីថ្នាក់។ គណៈកម្មការនេះ មានទីតាំងស្ថិតនៅក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌ។ លើសពីនេះទៀត គណៈកម្មការនេះមានសិទ្ធិអាចប្រើប្រាស់ត្រារបស់សាលាក្រុង-ស្រុក-ខណ្ឌដែរ។ នៅក្នុងរចនាសម្ព័ន្ធនៃគណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ មានសមាសភាពប្រធាន និងសមាជិកអចិន្ត្រៃយ៍ រួមជាមួយនឹងសមាជិកអាដហុក។ ប្រធាននៃគណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ គឺជាអភិបាលក្រុង-ស្រុក-ខណ្ឌ និងអនុប្រធាន១រូបដែលជា

ប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌ។ ចំពោះសមាជិកអាជហុក គឺជាតំណាងអាជ្ញាធរដែនដីដូចជាឃុំ-សង្កាត់-ក្រុង-ស្រុក-ខណ្ឌ ជាដើមដែលមានជាប់ពាក់ព័ន្ធ និងចាស់ព្រឹទ្ធាចារ្យដែលចូលរួមក្នុងការប្រជុំណាមួយច្បាស់លាស់តែប៉ុណ្ណោះ។

នៅពេលដែលធ្វើការដោះស្រាយវិវាទ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ មានសិទ្ធិក្នុងការកោះអញ្ជើញសមាជិកអចិន្ត្រៃ និងសមាជិកអាជហុកទាំងអស់ឱ្យមកចូលរួមក្នុងកិច្ចប្រជុំដោះស្រាយវិវាទ។ ប៉ុន្តែ សមាជិកអាជហុកពុំមានសិទ្ធិក្នុងការចូលរួមគ្រប់ការប្រជុំជាទូទៅនោះទេ។ ការទាមទារឱ្យមានសមាជិកអាជហុកដែលជាអ្នកតំណាងបែបនេះ គឺដើម្បីជួយសម្រួលដល់ការដោះស្រាយវិវាទក៏ដូចជាធ្វើឱ្យមានភាពសុក្រឹត្យភាពដល់ភាគីវិវាទផងដែរ ព្រោះថាសមាជិកប្រភេទនេះគឺជាអ្នកស្ថិតនៅក្នុងតំបន់មូលដ្ឋាននៃវិវាទ ឬជាអ្នកដែលអាចយល់ច្បាស់ពីស្ថានភាពនៃវិវាទច្រើនជាងសមាជិកអចិន្ត្រៃយ៍មួយចំនួន[105]។

គណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ មានសមត្ថកិច្ចដោះស្រាយវិវាទដីធ្លីដែលកើតមានឡើងនៅក្រៅតំបន់វិនិច្ឆ័យ ហើយមានសិទ្ធិត្រឹមតែធ្វើការសម្រុះសម្រួលវិវាទដែលត្រូវអនុវត្តយកតាមទម្លាប់ប្រពៃណី និងបច្ចេកទេសសុរិយោដី។ នេះមានន័យថាគណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ គ្មានសិទ្ធិសម្រេច ឬវិនិច្ឆ័យចំពោះវិវាទនោះទេ។ បើគ្មានការព្រមព្រៀងពីភាគីវិវាទនោះទេ គឺមានសិទ្ធិត្រឹមតែធ្វើការសម្រុះសម្រួលតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ក្នុងការធានានូវសមភាពនៃការដោះស្រាយវិវាទដីធ្លី គណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ អាចធ្វើការបញ្ជូនវិវាទដីធ្លីទៅគណៈកម្មការសុរិយោដីជាន់ខ្ពស់ ដោយពុំចាត់ចែងគ្រប់វិវាទនោះទេ ដោយត្រូវគោរពតាមលក្ខខណ្ឌ ៤ យ៉ាងដូចខាងក្រោម៖

- ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃបណ្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួន។
- ភាគីម្ខាងនៃវិវាទជាអាជ្ញាធរមានឋានៈខ្ពស់។ ពោលគឺសំដៅលើអាជ្ញាធរ ឬថ្នាក់ដឹកនាំដែលមានឋានានុក្រមក្នុងមុខងាររដ្ឋបាល ឬនយោបាយខ្ពស់ជាងប្រធាន គណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ។
- ករណីវិវាទដែលពាក់ព័ន្ធ នឹងផលប្រយោជន៍ប្រធានគណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ។
- វិវាទពាក់ព័ន្ធដីសាធារណៈរបស់រដ្ឋ។

ម្យ៉ាងវិញទៀត ចំពោះវិវាទដីធ្លីដែលកើតនៅក្នុងតំបន់វិនិច្ឆ័យ ជាគោលការណ៍បានកំណត់ថាមិនមែនជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌនោះទេ តែគឺជាសមត្ថកិច្ចរបស់គណៈកម្មការ

[105] អនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្ម ការសុរិយោដី មាត្រា៥

រដ្ឋបាលដែលត្រូវបានបង្កើតឡើង ដើម្បីដឹកនាំការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅក្នុងតំបន់វិនិច្ឆ័យ ហើយមានភារកិច្ចធ្វើការដោះស្រាយវិវាទដីធ្លីដែលកើតឡើងក្នុងកំឡុងពេលនៃការចុះបញ្ជី[106]។ គោលបំណងនៃការបង្កើតគណៈកម្មការនេះ គឺដើម្បីជួយផ្សព្វផ្សាយពន្យល់អំពីសិទ្ធិលើអចលនវត្ថុជូនដល់ប្រជាពលរដ្ឋ និងជួយសម្រុះសម្រួលដល់អ្នកកាន់កាប់ដែលតវ៉ា ឬមានវិវាទលើដីធ្លីដែលកើតឡើងនៅក្នុងតំបន់វិនិច្ឆ័យ។ គណៈកម្មការរដ្ឋបាល មានភារកិច្ចជួយផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានផ្សេងៗទាក់ទងនឹងការចុះបញ្ជី និងជួយដល់ការសម្រុះសម្រួលវិវាទនានា។

គណៈកម្មការរដ្ឋបាលនេះមិនមែនជាស្ថាប័នអចិន្ត្រៃយ៍ទេ ប៉ុន្តែត្រូវបានបង្កើតឡើងសម្រាប់តែការចុះបញ្ជីសុរិយោដីតាមលក្ខណៈជាប្រព័ន្ធតែប៉ុណ្ណោះ ហើយនៅពេលបេសកម្មនេះត្រូវបាន បញ្ចប់គណៈកម្មការនេះក៏នឹងលែងមានទៀតដែរ។

**រចនាសម្ព័ន្ធនៃគណៈកម្មការរដ្ឋបាល មានសមាសភាពដូចខាងក្រោម៖**

- តំណាងអភិបាលរាជធានី-ខេត្ត ជាប្រធាន
- មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យជាមន្ត្រីសុរិយោដី ជាសមាជិក
- មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដីនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក
- អភិបាលក្រុង-ស្រុក-ខណ្ឌ ឬ តំណាង ជាសមាជិក
- មេភូមិ ឬតំណាង ជាសមាជិក
- ចាស់ព្រឹទ្ធាចារ្យក្នុងតំបន់វិនិច្ឆ័យពីររូប ជាសមាជិក។

**វាក្យខណ្ឌទី២. គណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្ត**

គណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្ត ជាគណៈកម្មការសុរិយោដីថ្នាក់ទីពីរដែលមាននៅគ្រប់រាជធានី-ខេត្តទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជា។ គណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្តមានទីតាំងស្ថិតក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត (មន្ទីរសុរិយោដីរាជធានី-ខេត្ត)។ គណៈកម្មការនេះ ក៏មានសិទ្ធិក្នុងការប្រើប្រាស់ត្រារបស់សាលារាជធានី-ខេត្ត។

ក្នុងរចនាសម្ព័ន្ធនៃគណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្ត មានសមាសភាពដូចជាប្រធាន និងសមាជិកអចិន្ត្រៃយ៍ រួមជាមួយនឹងសមាជិកអាដហុក។ ប្រធានគណៈកម្មការនេះ គឺជាអភិបាលរាជធានី-ខេត្តដែលត្រូវបានតែងតាំងឡើងដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តធម៌ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគ

[106] ប្រកាសលេខ ១១២ ដនស្រ/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដីមាត្រា២

រូបនីយកម្ម និងសំណង់។ រីឯសមាជិកអចិន្ត្រៃយ៍ គឺជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីរាជធានី-ខេត្តដែលត្រូវតែងតាំងដូចប្រធានគណៈកម្មការផងដែរ គឺតាមរយៈប្រកាសរួម។ ចំពោះសមាជិកអាដហុករបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្ត មិនសូវមានភាពចាំបាច់ដូចសមាជិកអាដហុករបស់គណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខេត្តនោះទេ។ ដោយហេតុថា ដំណោះស្រាយវិវាទដីនៅគណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្ត គឺជាការដោះស្រាយលើកទី២ ដែលវិវាទត្រូវបានបញ្ជូនមកពីគណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ[107]។

ដើម្បីជួយសម្រួលការងាររបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្ត លេខាធិការដ្ឋានត្រូវបានបង្កើតឡើងដោយមានតួនាទីជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត។ មន្ត្រីបម្រើការនៅលេខាធិការដ្ឋាន គឺជាមន្ត្រីមុខងារសាធារណៈដែលតែងតាំងឡើងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តាមសំណើររបស់គណៈកម្មការសុរិយោដី។ លេខាធិការដ្ឋាននេះ មានមុខងារចម្បងដូចជា៖

- ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងរាល់ពាក្យបណ្ដឹងទាក់ទងវិវាទដីធ្លី
- ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្ត
- រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្ត
- ធ្វើរបាយការណ៍ពីលទ្ធផលនៃការស៊ើបអង្កេត
- ធ្វើកំណត់ហេតុអំពីដំណើរការសម្រុះសម្រួល និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការសម្រុះសម្រួល។
- បញ្ជូនកំណត់ហេតុ និងរបាយការណ៍ទាំងនោះទៅគណៈកម្មការសុរិយោដីថ្នាក់ ជាតិ។ ករណីការសម្រុះសម្រួលបានសម្រេចត្រូវផ្ញើលទ្ធផលនៃការសម្រុះសម្រួលនោះទៅកាន់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌ។
- រៀបចំនិងតម្កល់ឯកសារ។

មុនពេលមានប្រកាសលេខ ០៣២ ប្រក/គសជ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០១០ ស្ដីពីការធ្វើប្រតិភូកម្មមុខងារជូនអភិបាលគណៈអភិបាលរាជធានី-ខេត្ត និងប្រធានគណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្ត គណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្តមានសិទ្ធិត្រឹមតែធ្វើការសម្រុះសម្រួលតែប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្នតាមរយៈប្រកាសខាងលើ គណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្តមានសិទ្ធិក្នុងការធ្វើសេចក្ដីសម្រេចលើករណីវិវាទ

[107] អនុក្រឹត្យលេខ៤៧អនក្រ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការ សុរិយោដី មាត្រា ១២

តាមរយៈការបើកការប្រជុំសម្រេច បន្ទាប់ពីគណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្តបានធ្វើការសម្រុះសម្រួលចំនួនបីដង ដោយមិនអាចសម្រេចបាននូវការព្រមព្រៀងរវាងភាគីវិវាទ។

**វាក្យខណ្ឌទី៣. គណៈកម្មការសុរិយោដីថ្នាក់ជាតិ**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ គឺជាស្ថាប័ននៃការដោះស្រាយវិវាទដែលមានឋានុក្រមខ្ពស់ជាងគេបង្អស់ក្នុងចំណោមគណៈកម្មការសុរិយោដីទាំងបីថ្នាក់។ គណៈកម្មការនេះមានទីស្នាក់ការនៅក្នុងទីស្ដីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មការសុរិយោដីថ្នាក់ជាតិមានសិទ្ធិក្នុងការប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

សមាសភាពនៅក្នុងរចនាសម្ព័ន្ធនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានដូចជា ប្រធាននិងសមាជិកអចិន្ត្រៃយ៍រួមជាមួយនឹងសមាសជិកអាដហុក។ គណៈកម្មការនេះត្រូវដឹកនាំដោយប្រធានមួយរូបដែលជារដ្ឋមន្ត្រីក្រសួងរៀបចំ នគរូបនីយកម្ម និងសំណង់។ ហើយមានសមាសជិកអចិន្ត្រៃយ៍ពីររូបដែលជាអគ្គលេខាធិការក្រសួងមហាផ្ទៃ និងទីស្ដីការគណៈរដ្ឋមន្ត្រី។ ប្រធាន និងសមាជិកអចិន្ត្រៃយ៍ត្រូវបានតែងតាំងឡើងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ប្រធានមានសិទ្ធិកោះហៅសមាជិកអចិន្ត្រៃយ៍ និងសមាជិកអាដហុកឱ្យចូលរួមក្នុងកិច្ចប្រជុំដោះស្រាយតាមសភាពការណ៍ជាក់ស្ដែង។ មិនខុសពីគណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្តទេ គណៈកម្មការសុរិយោដីថ្នាក់ជាតិមានលេខាធិការដ្ឋានមួយដែលជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេតផងដែរ។ ការងារចម្បងៗរបស់លេខាធិការដ្ឋានរួមមាន៖

- ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្ត និងរាល់ពាក្យបណ្ដឹងផ្សេងៗ ដែលទាក់ទងនឹងវិវាទដីធ្លី
- ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ
- បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការនៅពេលមានបណ្ដឹងតវ៉ាលើសេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ
- រៀបចំ និងតម្កល់ទុកឯកសារ។

ក្រៅពីមុខងារចម្បងៗទាំងនេះ លេខាធិការដ្ឋានក៏បម្រើការងារជាផ្នែករដ្ឋបាល កិច្ចការទូទៅផ្នែកស៊ើបអង្កេត និងផ្នែកតម្កល់ឯកសាររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិផងដែរ។ ក្នុងការដោះស្រាយវិវាទ គណៈកម្មការសុរិយោដីថ្នាក់ជាតិមានសិទ្ធិក្នុងការសម្រេចលើវិវាទតាមរយៈការបើកសវនាការដែលមានពីរប្រភេទ គឺសវនាការចល័ត និងសវនាការអចល័ត។

សរុបមកការបង្កើតគណៈកម្មការសុរិយោដីថ្នាក់ជាតិ គឺជាយន្តការមួយយ៉ាងសំខាន់ដែលអាចរាំងស្កាត់វិវាទជាមុន ឬដោះស្រាយវិវាទដីធ្លីបានដោយឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាពតាមរយៈដោយមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់។ ជាក់ស្តែង ជាលទ្ធផលចាប់តាំងពីដំណាច់ខែកញ្ញា ឆ្នាំ២០០៧ មកគណៈកម្មការសុរិយោដីបានជួយដោះស្រាយបញ្ចប់វិវាទដីធ្លីចំនួន១,៣៨០ ករណីដែលពាក់ព័ន្ធនឹងប្រជាពលរដ្ឋ ៧,៣៨៤គ្រួសារ និងផ្ទៃដីទំហំ ២,៥៤២[108]។

**កថាខណ្ឌទី៣៖ ការដោះស្រាយវិវាទតាមរយៈអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនៅកម្ពុជា**

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដែលត្រូវបានបង្កើតឡើងតាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦។ ដោយសារតែពីមួយថ្ងៃទៅមួយថ្ងៃទំនាស់ដីធ្លីកាន់តែស្រួចស្រាវ និងកើតឡើងឥតឈប់ឈរហើយផ្ទួបផ្សំជាមួយនឹងឆន្ទៈនយោបាយដើម្បីដោះស្រាយវិបត្តិនេះឱ្យបានធូរស្បើយ និងលុបបំបាត់ទាំងស្រុងទើបរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តបង្កើតអាជ្ញាធរនេះឡើង។ ជាក់ស្តែងសមាជិករបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីភាគច្រើនគឺជាមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល។ ដូច្នេះដំណើរការនៃការដោះស្រាយទំនាស់ដីធ្លីអាចដំណើរការបានដោយរលូន និងគ្មានការគំរាមកំហែងពីភាគីវិវាទ ទោះបីជាភាគីនោះជាបុគ្គលដែលមានអំណាចក៏ដោយ។ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានមុខងារសំខាន់ៗដូចជាទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លីតាមរយៈការអប់រំផ្សព្វផ្សាយឱ្យសាធារណៈជនបានយល់ដឹងពីផលវិបាកដែលបណ្តាលមកពីទំនាស់ដីធ្លី និងមានវិធានការដាក់វិន័យចំពោះជនល្មើសដែលបានរំលោភបំពានលើបញ្ហាដីធ្លីដោយខុសច្បាប់ជាធរមាន។ ទទួលសំណុំរឿងដីធ្លីដែលហួសពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងទទួលពាក្យ បណ្តឹងពីគ្រប់មជ្ឈដ្ឋានដែលមានពាក់ព័ន្ធទំនាស់ដីធ្លី។ ស្វែងយល់ស៊ើបអង្កេត និងដោះស្រាយទំនាស់ដីធ្លី ឃ្លាំមើលការដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដី និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ និងធ្វើរបាយការណ៍អំពីលទ្ធផលការងារនៃការដោះស្រាយទំនាស់ដីធ្លីដាក់ជូនប្រមុខរាជរដ្ឋាភិបាល[109]។

អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី មានប្រធាន១រូប ដែលជាតំណាងឱ្យនាយករដ្ឋមន្ត្រី និងអនុប្រធានមួយចំនួនតាមការចាំបាច់[110]។ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានអគ្គលេខាធិការដ្ឋានជាសេនាធិការ។ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានតួនាទី និងភារកិច្ចដូចជា៖

---

108 សៀវភៅកម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ឆ្នាំ២០០៨-២០១៣ ទំព័រ ១៨៤

109 ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ កុម្ភៈ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មាត្រា៣

110 ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ កុម្ភៈ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មាត្រា២

- ទទួល និងពិនិត្យសំណុំរឿង ពាក្យបណ្តឹង និងចុះស្វែងយល់ស៊ើបអង្កេត ហើយធ្វើរបាយការណ៍ អំពីលទ្ធផលនៃការស៊ើបអង្កេតលើបញ្ហាពាក់ព័ន្ធទំនាស់ដីធ្លី ដើម្បីដាក់ជូនប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីធ្វើការពិនិត្យ និងសម្រេចទៅតាមដំណាក់កាល និងតាមករណីនីមួយៗ។
- រៀបចំប្រជុំ និងធ្វើកំណត់ហេតុអង្គប្រជុំរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។
- ចុះស្វែងយល់ស៊ើបអង្កេត និងឃ្លាំមើលសកម្មភាពរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការដោះស្រាយទំនាស់ដីធ្លីតាមការបញ្ជារណែនាំពីប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។
- បញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅតុលាការនៅពេលមានបណ្តឹងតវ៉ាលើសេចក្តីសម្រេចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីទៅតុលាការ។
- រៀបចំ និងតម្កល់ទុកឯកសារពាក់ព័ន្ធទំនាស់ និងបណ្តឹងដីធ្លី។
- រៀបចំសេចក្តីព្រាងរបាយការណ៍ អំពីសកម្មភាពការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីជូនដល់ប្រធានអាជ្ញាធរជាតិតាមកាលកំណត់ ដើម្បីរាយការណ៍ជូនដល់ប្រមុខរាជរដ្ឋាភិបាល។
- ផ្សព្វផ្សាយជូនសាធារណៈជន អំពីលទ្ធផលនៃការដោះស្រាយទំនាស់ដីធ្លី ដែលអាជ្ញាធរជាតិបានដោះស្រាយចប់ជាស្ថាពរ។ ការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី គឺជាយន្តការថ្មីក្នុងការដោះស្រាយទំនាស់ដីធ្លីដែលមានទ្រង់ទ្រាយធំដែលគណៈកម្មការសុរិយោដីទាំងបីថ្នាក់គ្មានសមត្ថភាពដោះស្រាយ។

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានរចនាសម្ព័ន្ធដូចតទៅ៖

- នាយកដ្ឋានទប់ស្កាត់ និងអប់រំ
- នាយកដ្ឋានស៊ើបអង្កេត និងអធិការកិច្ច
- នាយកដ្ឋានទទួល និងដោះស្រាយបណ្តឹង
- នាយកដ្ឋានបូកសរុប ព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ និង
- នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក[111]។

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានទីតាំងក្នុងទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយការចំណាយក្នុងកិច្ចដំណើរការជាបន្ទុកថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ហើយអាជ្ញាធរនេះបានធ្វើការយ៉ាងសកម្មដែលសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់

[111] អនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មាត្រា៨

ជាក់ស្តែងនៅក្នុងរបាយការណ៍ការងារប្រចាំខែកក្កដា ឆ្នាំ២០១០ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបានបង្ហាញថាទំនាស់ដីធ្លីចំនួន០៥ករណីត្រូវបានដោះស្រាយរួចរាល់ និងកំពុងតែដោះស្រាយលើករណីទំនាស់ចំនួន១៥២ករណី។

ដូចដែលបានកត់សម្គាល់ឃើញថា យន្តការនៃការដោះស្រាយវិវាទដីធ្លីតាមរយៈគណៈកម្មការសុរិយោដីទាំងបីថ្នាក់ គណៈកម្មការរដ្ឋបាល និងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដែលបានរៀបរាប់ខាងលើគឺសុទ្ធតែជាយន្តការនៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ ដែលជាគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ដោយសារតែវិវាទដីធ្លីជាការងារលំបាក និងស្មុគស្មាញ ហើយមានទំនាក់ទំនងនឹងវិស័យជាច្រើនផ្នែក[112]។ ទន្ទឹមនឹងនេះដែរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាយុទ្ធសាស្ត្រទី៦ នៃការពង្រឹងនីតិរដ្ឋរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា[113]។

**កថាខណ្ឌទី៤៖ គុណសម្បត្តិ និងគុណវិបត្តិនៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ**

- **គុណសម្បត្តិនៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ**
  - **ភាពមិនលម្អៀង** គឺការដំណោះស្រាយជម្លោះ ក្រៅប្រព័ន្ធតុលាការភាគច្រើ គឺបង្ហាញឱ្យប្រជាជនបានឃើញអំពីភាពយុត្តិធម៌ និងអព្យាក្រឹត្យ។
  - **ពេលវេលា** ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺមានពេលវេលាឆាប់រហ័សជាងការដោះស្រាយជម្លោះតាមប្រព័ន្ធតុលាការ ពីព្រោះភាគីជម្លោះយល់ព្រមបញ្ចប់ជម្លោះទៅតាមការសម្រុះសម្រួល ឬការសម្រេចរបស់អាជ្ញាធរ[114]។
  - **មិនចំណាយសោហ៊ុយក្នុងជម្លោះ** ជាទូទៅការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺមិនចាំបាច់ជួលមេធាវីនោះទេ[115] ចំណែកឯការដំណោះស្រាយវិវាទតាមតុលាការត្រូវចំណាយសោហ៊ុយច្រើន ដូចជា ជួលមេធាវី និងកិច្ចការផ្សេងៗទៀត។
  - **ជៀសវាងអំពើពុករលួយ**[116] ការដោះស្រាយក្រៅប្រព័ន្ធតុលាការនេះ គឺមិនមានជនរងគ្រោះណាវេទនាដោយសារតែអំពើពុករលួយទេ ពីព្រោះអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយប្រកបដោយសន្តិវិធី និងនយោបាយឈ្នះ ឈ្នះ។

[112] លឹម វាន់ ឯកសារស្រាវជ្រាវស្តីពីរបបដីធ្លីនៅកម្ពុជា ឆ្នាំ២០០៦ ទំព័រ ១១

[113] សៀវភៅកម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជាឆ្នាំ២០០៨-២០១៣ ទំព័រ ១៣

[114] សៀវភៅការដោះស្រាយទំទាស់ដីធ្លីក្រៅប្រព័ន្ធតុលាការ ផ្នែក គណៈកម្មការសុរិយោដី សាស្ត្រាចារ្យ វុឌ្ឍី វណ្ណារ៉ា ឆ្នាំ២០០៨-២០០៩ ទំព័រ ៩-១០

[115] សៀវភៅការដោះស្រាយទំទាស់ដីធ្លីក្រៅប្រព័ន្ធតុលាការ ផ្នែក គណៈកម្មការសុរិយោដី សាស្ត្រាចារ្យ វុឌ្ឍី វណ្ណារ៉ា ឆ្នាំ២០០៨-២០០៩ ទំព័រ ២០

[116] កិច្ចស្រាវជ្រាវ ស្តីពី យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដឹកនាំដោយ លោកស្រី ប៉ូលី បញ្ញា ឆ្នាំសិក្សា២០១៧-២០១៨

- **គុណវិបត្តិនៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ**
  - **អំណាចមិនស្មើភាពគ្នា** ពេលខ្លះរឿងក្តីដែលឡើងតែងតែមានករណីវិវាទរវាងរូបវន្តបុគ្គលឯកជន និងរូបវន្តបុគ្គលឯកជន វិវាទរវាងរូបវន្តបុគ្គលឯកជន និងសមូហភាព វិវាទរវាងនីតិបុគ្គលឯកជន និងនីតិបុគ្គលឯកជន វិវាទរវាងបុគ្គលឯកជន និងបុគ្គលសាធារណៈ។ ចំណុចនេះហើយដែលធ្វើឱ្យមានការគំរាមកំហែង ឬសម្ពុតភាគីដែលទន់ខ្សោយជាងឱ្យមានការព្រមព្រៀងលើដំណោះស្រាយដោយភាពអយុត្តិធម៌[117]។
  - **ភាគីគ្មានហេតុផល** មានភាគីណាមួយ ឬភាគីទាំងពីរគ្មានហេតុផលមិនមានឆន្ទៈក្នុងការដោះស្រាយវិវាទទេ មិនអានចាប់បង្ខំឱ្យភាគីព្រមព្រៀងគ្នាបានទេ។
  - **ការអនុវត្តដំណោះស្រាយ** ចំពោះវិវាទខ្លះមានលក្ខណៈស្មុគស្មាញច្រើនរបស់ភាគីជម្លោះណាមួយនោះ គឺភាគច្រើនដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការដោះស្រាយនោះទេ។ មួយវិញទៀត ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺចង់ភាគីទាំងពីរទទួលយកសេចក្តីសម្រេច ដែលកើតចេញពីការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការបានឡើយ[118]។

ដូច្នេះការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ គឺជានីតិវិធីដោះស្រាយវិវាទមួយដែលមានសារៈសំខាន់បំផុតសម្រាប់ប្រជាពលរដ្ឋទូទៅ។ ជាពិសេសសម្រាប់ប្រជាពលរដ្ឋ ដែលមានស្ថានភាពគ្រួសារក្រីក្រលំបាក ដែលគ្មានលទ្ធភាពគ្រប់គ្រាន់សម្រាប់ការចំណាយផ្សេងៗ ជាច្រើនដូចជា៖ ប្រាក់សោហ៊ុយធ្វើដំណើរចុះឡើង និងមិនខាត់បង់ពេលវេលា និងការងារ ឬការប្រកបរបរស៊ីចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគាត់។

អាត្មាភាពយល់ឃើញថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជានីតិវិធីដ៏ប្រសើរបំផុតអាចជួយសម្រួល និងដោះស្រាយវិវាទដីធ្លីជូនប្រជាពលរដ្ឋបានមួយផ្នែកធំ និងមានប្រសិទ្ធភាពខ្ពស់ប្រសិនបើអាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ប្រើមធ្យោបាយផ្សព្វផ្សាយព័ត៌មានឱ្យប្រជាពលរដ្ឋកម្ពុជាយល់ដឹងឱ្យកាន់តែច្បាស់លាស់គ្រប់គ្នាគ្រប់ទីកន្លែងនៅទូទាំងប្រទេសកម្ពុជាពីអត្ថប្រយោជន៍នៃការដោះស្រាយវិវាទដីធ្លី ក្រៅប្រព័ន្ធតុលាការ។ ជាពិសេសអ្វីដែលសំខាន់គ្រប់ក្រសួង ឬស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវបណ្តុះបណ្តាលជំនាញបន្ថែមដល់មន្ត្រីដែលមានតួនាទីជាអ្នកដោះស្រាយវិវាទជូនភាគីជម្លោះ ដើម្បីឱ្យមានប្រសិទ្ធភាពកាន់តែប្រសើរឡើងក្នុងការដោះស្រាយវិវាទ។

[117] ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា សៀវភៅស្តីពីទស្សនាទានសំខាន់ៗ មេធាវី ស៊្មីរិន អ៊ែម អូស្វើរមីឡឺរ ខែមករា ឆ្នាំ២០១០ បោះពុម្ពលើកទី២

[118] កិច្ចការស្រាវជ្រាវ ដំណោះស្រាយវិវាទដីធ្លីនៅកម្ពុជា ដឹកនាំដោយបណ្ឌិត ហាប់ ផល្លី ឆ្នាំ២០១៣ ទំព័រ ១៧-១៨

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការបកស្រាយយ៉ាងលម្អិតលើប្រធានបទស្តីអំពី នីតិវិធីដោះស្រាយវិវាទដីធ្លីនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ននៅព្រះរាជាណាចក្រកម្ពុជា យើងសង្កេតថាវិវាទដីធ្លីនៅក្នុងប្រទេសកម្ពុជាបណ្តាលមកពីការរំលោភដីធ្លីរបស់ប្រជាកសិករពីសំណាក់ រូបវន្តបុគ្គលឯកជន និងរូបវន្តបុគ្គលឯកជន នីតិបុគ្គលឯកជន និងនីតិបុគ្គលឯកជន រូបវន្តបុគ្គលឯកជន និងសមូហភាព បុគ្គលឯកជន និងបុគ្គលសាធារណៈ និងជាការកើតឡើងតម្លៃនៃដី និងការមិនយល់ដឹងគោលការណ៍ច្បាប់ជាដើម ហើយត្រូវបានបង្រួមមកត្រឹមកត្តា៤សំខាន់គឺ កត្តាមនុស្ស កត្តាច្បាប់ កត្តាសង្គម និងកត្តាប្រវត្តិសាស្ត្រ។ ដើម្បីដោះស្រាយបញ្ហានេះរាជរដ្ឋាភិបាលបានបង្កើតនូវគោលការណ៍ក្នុងដោះស្រាយវិវាទដីធ្លី ដោយធ្វើការបែងចែកប្រភេទដីវិវាទ ដែលបានចុះបញ្ជីរួចត្រូវប្រគល់ជូនតុលាការដែលមានសមត្ថកិច្ចក្នុងការដោះស្រាយ ចំណែកឯប្រភេទដីវិវាទដែលមិនទាន់បានចុះបញ្ជីរួចត្រូវប្រគល់ជូនគណៈកម្មសុរិយោដី មានសមត្ថកិច្ចដោះស្រាយវិវាទនោះត្រូវប្រគល់ឱ្យអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

ទន្ទឹមនឹងការបែងចែកសមត្ថកិច្ចនេះផងដែរ យើងសង្កេតឃើញថា នីតិវិធីនៃការបែងចែកនេះមានសារៈប្រយោជន៍យ៉ាងច្រើនចំពោះប្រជាពលរដ្ឋ និងបន្ធូរការងារដែលបានកស្ទះនៅតុលាការ។ ជាក់ស្តែងចំពោះការដោះស្រាយវិវាទដីធ្លីតាមរយៈគណៈកម្មការសុរិយោដី ទាំងបីថ្នាក់ជាយន្តការបង្វិតភ្នាក់ងាររដ្ឋបាលឱ្យជិតប្រជាពលរដ្ឋក្នុងការបម្រើសេវាដោះស្រាយវិវាទដីធ្លី ដើម្បីជួយក្នុងដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋដោយមិនគិតថាថ្លៃសេវា ហើយប្រជាពលរដ្ឋអាចទទួលបានចំណេញទាំងពេលវេលាទាំងប្រាក់កាសព្រមទាំងអាចរក្សានូវទំនាក់ទំនងល្អជាមួយភាគីវិវាទបាន ដោយស្ថាប័ននេះប្រកាន់យកនូវគោលការណ៍នៃការសម្រុះសម្រួល។ មិនតែប៉ុណ្ណោះចំពោះសវនាការទាំងពីរប្រភេទរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានរៀបចំឡើងនៅទីតាំងក្បែរ ឬនៅលើដីមានវិវាទដែលផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋមិនចាំបាច់ធ្វើដំណើរទៅដល់ស្ថាប័នគណៈកម្មការសុរិយោដីថ្នាក់ជាតិនេះ។ ម្យ៉ាញវិញទៀត គណៈកម្មការសុរិយោដីគឺជាស្ថាប័នប្រកបដោយបច្ចេសទេសដោយសារការចុះស៊ើបអង្កេតដល់ដីធ្លីដែលកើតវិវាទ ព្រមទាំងមានឧបករណ៍ក្នុងការវាស់វែងប្រកបដោយបច្ចេកទេសខ្ពស់ និងសម្បូរបែបទៀតផង។ មួយវិញទៀត ចំពោះអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី គឺស្ថាប័នប្រកបដោយអំណាច ព្រោះសមាជិកសុទ្ធតែមានឋានៈខ្ពស់នៅក្នុងរាជរដ្ឋាភិបាល។ លើសពីនេះទៅទៀត អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី គឺស្ថាប័នប្រកបដោយបច្ចេសទេសគតិយុត្តនិងមានលក្ខណៈនយោបាយ។ ហើយទំនាស់ដែលបានដោះស្រាយនៅអាជ្ញាធរនេះសុទ្ធតែជាទំនាស់ដែលភាគីជាបុគ្គលមានអំណាច និងមានបញ្ហាស្មុគស្មាញខ្លាំង។ ការបង្កើតស្ថាប័ននេះឡើង គឺដោយសារ

តែកាលានុវត្តភាពនៃសង្គម។ ក្រៅពីអាជ្ញាធរនេះមានស្ថាប័នតុលាការក៏ជាស្ថាប័នប្រកាន់យកនូវគោលការណ៍ច្បាប់ ព្រមទាំងភស្តុតាងដែលជាប័ណ្ណកម្មសិទ្ធិដែលមានភាពរឹងមាំក្នុងការធ្វើសេចក្តីសម្រេច។ ដោយខិតខំប្រឹងប្រែងក្នុងការដោះស្រាយវិវាទដីធ្លី ក្រៅប្រព័ន្ធតុលាការទាំងនេះបានជួយស្វែងរកនូវភាពយុត្តិធម៌ជូនប្រជាពលរដ្ឋដោយខិតខំប្រឹងប្រែងក្នុងការដោះស្រាយវិវាទដីធ្លីដែលបានកើតឡើង ហើយមាននីតិវិធីក្នុងការដោះស្រាយផ្សេងៗគ្នាទៅតាមប្រភេទនៃស្ថាប័ន។ ក្រៅពីគោលការណ៍ចម្បងៗដែលបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្នបានបង្កើតនូវគោលការណ៍ដោះស្រាយវិវាទដីធ្លីដែលមាន លក្ខណៈពិសេសជាក់លាក់មួយចំនួនជាក់ស្តែងអាជ្ញាធរថ្នាក់ក្រោមជាតិគ្រប់លំដាប់ ជាពិសេសគឺក្រុមប្រឹក្សា ឃុំ-សង្កាត់ និងអាជ្ញាធរភូមិជាដើម។

តែទោះបីជាយ៉ាងណាក៏ដោយ គោលការណ៍ និងនីតិវិធីនៃការដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការនៅតែមានភាពអសកម្មមួយចំនួនដែរ។ តួយ៉ាងចំពោះនីតិវិធីនៅក្នុងការដោះស្រាយវិវាទដីធ្លីតាមរយៈគណៈកម្មការសុរិយោដី អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងតុលាការច្បាប់បានចែងពីគោលការណ៍នៃពេលវេលាក្នុងការដោះស្រាយវិវាទដីធ្លី។ មួយវិញទៀតរាជរដ្ឋាភិបាលបានជំរុញឱ្យអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយលើកបញ្ហាវិវាទដីធ្លីឱ្យបានគ្រប់ខេត្ត ក្រុង ស្រុក និងឃុំ មិនឱ្យចំណាយពន្យារពេលយូរ និងមិនឱ្យមានការខាតបង់នូវពេលវេលាក្នុងការប្រកបអាជីវកម្មជាដើម។

សរុបសេចក្តីមកសង្ឃឹមថា ការស្រាវជ្រាវលើប្រធានបទនេះ នឹងផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់អ្នកសិក្សាក៏ដូចជាប្រជាពលរដ្ឋគ្រប់រូបដែលចង់យល់ដឹងអំពីគោលការណ៍ និងនីតិវិធីដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការនៅកម្ពុជានាពេលបច្ចុប្បន្ននេះ។

# អនុសាសន៍

ខាងក្រោមនេះ ជាមតិយោបល់ដ៏មានសារៈប្រយោជន៍ដែលកើតចេញពីការស្រាវជ្រាវរបស់អាត្មាភាព ដើម្បីធ្វើឱ្យដំណើរការយន្តការដោះស្រាយវិវាទដីធ្លីដោយស្ថាប័នដោះស្រាយវិវាទដីធ្លី ប្រព្រឹត្តទៅបានដោយធានានូវការទទួលខុសត្រូវតម្លាភាព យុត្តិធម៌ និងអាចទទួលយកបានមាន ដូចខាងក្រោម៖

- **ស្ថាប័នតុលាការ**
  - រាជរដ្ឋាភិបាលគួរតែបង្កើតឱ្យមានតុលាការពិសេសដែលមានជំនាញ និងសមត្ថកិច្ចចំពោះតែការដោះស្រាយវិវាទដីធ្លី ព្រោះដើម្បីជៀសវាងករណីបណ្តឹងពីវិវាទដីធ្លី ច្រើនកកស្ទះនៅតុលាការដោយហេតុថា វិវាទដីធ្លីមានកំណើតច្រើនពីមួយថ្ងៃ ទៅមួយថ្ងៃ
  - សូមឱ្យតុលាការគួរមាននីតិវិធីក្នុងការចុះស៊ើបអង្កេត និងប្រមូលភស្តុតាងដល់កន្លែងកើតហេតុដើម្បីធានានូវការអនុវត្តប្រកបដោយយុត្តិធម៌
  - ចំពោះនីតិវិធីដោះស្រាយវិវាទដីធ្លីតាមរយៈតុលាការ ត្រូវកំណត់ពេលវេលាឱ្យបានជាក់លាក់ដោយមិនត្រូវធ្វើការពន្យារពេល ដែលជាហេតុធ្វើឱ្យភាគីបណ្តឹងខាតពេលវេលាក្នុងការប្រកបរបរ
  - មន្ត្រីចៅក្រមត្រូវមានបទពិសោធន៍ក្នុងការដោះស្រាយវិវាទដីធ្លី និងធ្លាប់ទទួលបានការបណ្តុះបណ្តាលពីជំនាញដីធ្លី
  - រាជរដ្ឋាភិបាលគួរបង្កើតតុលាការរដ្ឋបាល ដើម្បីឱ្យប្រជាពលរដ្ឋធ្វើបណ្តឹងប្រឆាំងចំពោះមន្ត្រីណាដែលមិនគោរពនូវមុខងាររបស់ខ្លួនក្នុងការបម្រើសេវាដោះស្រាយវិវាទដីធ្លី ឬមានភាពយឺតយ៉ាវ និងភាពលម្អៀងក្នុងការធ្វើសេចក្តីសម្រេច។
- **គណៈកម្មការសុរិយោដី**
  - ពង្រឹងការអនុវត្តច្បាប់ភូមិបាលតាមរយៈការផ្សព្វផ្សាយ ពីច្បាប់ភូមិបាលឱ្យបានដល់ប្រជាពលរដ្ឋមូលដ្ឋាន ជាពិសេសពីតួនាទីភារៈកិច្ច និងនីតិវិធីរបស់គណៈកម្មការសុរិយោដី និងសិទ្ធិផ្សេងៗរបស់ភាគីវិវាទទាំងពេលដាក់ពាក្យបណ្តឹង និងរាល់ដំណាក់កាលនៃដំណើរការសម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីឱ្យបានច្បាស់លាស់ដល់គូភាគីវិវាទ។
  - បង្កើនសមត្ថភាពដល់មន្ត្រីគណៈកម្មការសុរិយោដី ពីនីតិវិធីដោះស្រាយវិវាទរបស់គណៈកម្មការសុរិយោដីជាពិសេសអំពីបច្ចេកទេស និងជំនាញក្នុងការសម្រុះសម្រួល។

- បង្កើនចំនួនសមាសភាពគណៈកម្មការសុរិយោដី ឬត្រូវចុះបញ្ជីសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ ទាំងមូលក្នុងរាជធានី-ខេត្តដែលមានស្រាប់ ដើម្បីងាយស្រួលក្នុងការចល័តជួយគ្នាទៅវិញទៅមកស្ថានភាពករណីវិវាទតិច ឬច្រើនរបស់ ក្រុង-ស្រុក-ខណ្ឌ នីមួយៗ។
- ថវិកា មធ្យោបាយក្នុងដំណើរ និងសម្ភារៈជាកត្តាចាំបាច់ដើម្បីធានានូវការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី។ ថវិកា មធ្យោបាយ និងសម្ភារៈមួយចំនួនអាចទទួលបានពីកិច្ចសហការណ៍ពីសំណាក់អង្គការសង្គមស៊ីវិលនានា ដែលមានទីតាំងនៅក្នុងរាជធានី-ខេត្តនោះ។
- សុំឱ្យមានវិធានការចំពោះបណ្តឹង របស់ជនរងគ្រោះលើសពីសមត្ថភាពរបស់គណៈកម្មការសុរិយោដីចំពោះការប្រងើយកន្តើយ និងធ្វេសប្រហែលមិនចាត់វិធានការដោយចេតនាដែលបណ្តាលឱ្យប៉ះពាល់ផលប្រយោជន៍ជនរងគ្រោះ។ ប្រការនេះគួរតែប្តឹងទៅតុលាការរដ្ឋបាលក្នុងករណីដែលរដ្ឋបាលបង្កើតស្ថាប័នតុលាការរដ្ឋនេះឡើង។
- សមាសភាពក្នុងក្រុមសម្រុះសម្រួល នៃគណៈកម្មការសុរិយោដីក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត គួរអនុញ្ញាតឱ្យសង្គមស៊ីវិល ដែលមានការចាប់អារម្មណ៍បានចូលរួមក្នុងនាមជាអ្នកសម្រុះសម្រួល។
- ឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តពិតប្រាដករបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយករណីវិវាទដីធ្លីទាំងនេះ ជាកត្តាចាំបាច់មិនអាចខ្វះបាន។

- **អាជ្ញាធរជាតិដោះស្រាយជំនាស់ដីធ្លី**
  - គួរតែបង្កើនសមត្ថភាពជំនាញឱ្យបានច្បាស់លាស់ខាងដោះស្រាយ វិវាទដីធ្លីឱ្យបានកាន់តែប្រសើរ។
  - គួរតែចែងពីប្រភេទទំនាស់ដីធ្លីឱ្យបានច្បាស់លាស់ និងធ្វើការបង្កើតនូវនាយកដ្ឋានក្នុងការតាមដានដំណើរការដោះស្រាយទំនាស់ដីធ្លីឱ្យបានលឿន និងប្រកបដោយប្រសិទ្ធភាព។
  - គួរតែកំណត់ពេលវេលាក្នុងការដោះស្រាយទំនាស់ដីធ្លីឱ្យបានច្បាស់លាស់ ដើម្បីជៀសវាងក្នុងការពន្យារពេលក្នុងការដោះស្រាយ ដោយកំណត់នូវពេលវេលាមួយជាក់លាក់ក្នុងការឆ្លើយតបចំពោះការដាក់ពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ។

## ឯកសារយោង

### ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ មុនសម័យសង្គមរាស្ត្រនិយម ឆ្នាំ១៩៤៧
- រដ្ឋធម្មនុញ្ញ នៃរបបសង្គមរាសង្គមរាស្ត្រនិយម ដែលប្រកាសឱ្យប្រើនាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣
- រដ្ឋធម្មនុញ្ញ នៃរបបសាធារណៈរដ្ឋខ្មែរ ដែលប្រកាសឱ្យប្រើនាថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០
- រដ្ឋធម្មនុញ្ញ នៃរបបប្រជាធិបតេយ្យកម្ពុជា ដែលប្រកាសឱ្យប្រើនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥
- រដ្ឋធម្មនុញ្ញ នៃរបបសារធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសឱ្យប្រើនាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១
- រដ្ឋធម្មនុញ្ញ នៃរបបរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើនាឆ្នាំ១៩៨៩
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើនាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី ក្រមរដ្ឋប្បវេណី
- ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៦ ស្តីពី ក្រមនីតិវិធីរដ្ឋប្បវេណី
- ព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីភូមិបាលចាស់ និងច្បាប់ភូមិបាលថ្មី
- ព្រះរាជក្រមលេខ ០៤/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុក្រឹត្យលេខ៦៥ អនក្រ.រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- អនុក្រឹត្យ លេខ៤៨ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- អនុក្រឹត្យ លេខ ៣៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- អនុក្រឹត្យលេខ៤៧ អនក្រ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

- អនុក្រឹត្យ លេខ ៤២ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- ប្រកាស លេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី
- ប្រការសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១។

**សៀវភៅ**


- សូ សូវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី វ័ត្ថមុនី Brett Ballared និងSarthi Achary ការវាយតម្លៃបញ្ហា សង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា ការអង្កេតនៅមូលដ្ឋានឯកសារពិភាក្សា លេខ២០ វិទ្យាស្ថានបណ្តុះបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា រាជធានីភ្នំពេញ
- សៀវភៅកម្មវិធីនយោបាយរបស់គណៈបក្សប្រជាជនកម្ពុជា ឆ្នាំ២០០៨-២០១៣
- ទ្រី ហ៊ាន និក្ខេបបទបណ្ឌិតនីតិសាស្ត្រ ឯកទេសៈ នីតិឯកជន វិវាទដីធ្លីនៅកម្ពុជា ២០០១-២០០៩
- រៀបរៀងដោយ សាស្ត្រាចារ្យ អ៊ុន សកក្កដា គោលការណ៍ និងនីវិធីដោះស្រាយវិវាទដីធ្លី នៅព្រះរាជាណាក្រកម្ពុជា ឆ្នាំសិក្សា២០០៧-២០១១
- សៀក វណ្ណា និង សេក សេដ្ឋា របបកម្មសិទ្ធិដីធ្លីកម្ពុជា កម្មវិធីបណ្តុះបណ្តាលអំពីច្បាប់ភូមិបាល សម្រាប់និស្សិត ចៅក្រម និងព្រះរាជាអាជ្ញា នៅរាជបណ្ឌិតសភាពវិជ្ជាជីវៈ តុលាការ ឆ្នាំ២០០៩
- ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្រាវជ្រាវដោយ លោកស្រី ស៊ូ សោភា និង កញ្ញា ទិត្យ ស៊ីដែត ខែមិថុនា ឆ្នាំ២០១៥ នៅវិទ្យាស្ថានសភាពកម្ពុជា
- កម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងដីធ្លី ចងក្រងឡើងវិញដោយ ហាប់ ផល្លី ២០១០
- សៀវភៅការដោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការ សាស្ត្រាចារ្យ វុឌ្ឍី វណ្ណារ៉ា ឆ្នាំ២០០៨-២០០៩
- លឹម វាន់ ឯកសារស្រាវជ្រាវស្តីពីរបបដីធ្លីនៅកម្ពុជា ឆ្នាំ២០០៦
- ហាប់ ផល្លី ការវិវត្តនៃប្រព័ន្ធគ្រប់គ្រងដីធ្លីនៅកម្ពុជា ខែកញ្ញា ឆ្នាំ២០០៩
- កិច្ចការស្រាវជ្រាវ ដំណោះស្រាយវិវាទដីធ្លីនៅកម្ពុជា ដឹកនាំដោយបណ្ឌិត ហាប់ ផល្លី ឆ្នាំ២០១៣

- កិច្ចស្រាវជ្រាវ ស្ដីពី យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដឹកនាំដោយ លោកស្រី ប៉ូលី បញ្ញា ឆ្នាំសិក្សា២០១៧-២០១៨
- សេចក្តីសង្ខេបមេរៀនប្រវត្តិសាស្ត្រខ្មែរ សម្រាប់ជំនួយស្មារតីដល់សិស្សថ្នាក់ទី១២
- រៀបរៀង និងចងក្រងដោយ គង់ សុខហេង សិក្សាអត្ថបទ អក្សរសិល្ប៍ខ្មែរ សម្រាប់ថ្នាក់មធ្យម សិក្សាថ្នាក់ទី៧-១២ ឆ្នាំ២០១១
- របាយការណ៍ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៩ សមាគមអាដហុក លេខ៩ ឆ្នាំទី៩ ផ្សាយ ខែមករា ឆ្នាំ២០១០
- មេរៀន ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បង្រៀនដោយឯកឧត្តម លី តៃសេង ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣។

## គេហទំព័រ

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ការិយាល័យមេធាវី ខ្មែរ និងសហការី ។

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធ១** | ប្រកាស ស្តីពី គោលការណ៍ណែនាំ និង នីតិវិធីរបស់គណៈកម្មការសុរិយោដី |
| **ឧបសម្ព័ន្ធ២** | អនុក្រឹត្យ ស្តីពី ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ |
| **ឧបសម្ព័ន្ធ៣** | អនុក្រឹត្យ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី |

# ឧបសម្ព័ន្ធ ១



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

លេខ : ១១២ ដនស/ប្រក

**ប្រកាស**

**ស្តីពី**

**គោលការណ៍ណែនាំ និង នីតិវិធី**

**របស់គណៈកម្មការសុរិយោដី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៤៦ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យ លេខ ៤៧ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យ លេខ ៤៨ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញប្រកាស លេខ ៧៦ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ...

របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និង តួនាទីភារកិច្ចរបស់បណ្ណាការិយាល័យក្រោមឱវាទ

តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

## សំ រេ ច

## ១. និយមន័យ

**ប្រការ ១ :-**

ប្រកាសនេះកំណត់នីតិវិធីនៃការដាក់ពាក្យប្តឹង ការសម្រុះសម្រួល និង ការសំរេចលើបញ្ហាវិវាទដីធ្លីដែលបានប្តឹងទៅគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ។

**ប្រការ ២ :-**

គណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ (គសសខ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៤ និង មាត្រា ៥ នៃអនុក្រឹត្យ លេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង (គសខក) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និង មាត្រា ១២ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ (គសជ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និងមាត្រា១៧ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

" គណៈកម្មការរដ្ឋបាល " គឺជាគណៈកម្មការដែលបានបង្កើតឡើងដើម្បីដឹកនាំការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅក្នុងតំបន់វិនិច្ឆ័យ ។ ភារកិច្ចមួយនៃគណៈកម្មការនេះ គឺធ្វើការដោះស្រាយវិវាទដីធ្លីដែលកើតមាននៅក្នុងអំឡុងពេលនៃការចុះបញ្ជី

មានលក្ខណៈជាប្រព័ន្ធស្របតាមមាត្រា ៣ នៃអនុក្រឹត្យ លេខ ៤៦ អនក្រ/បក ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី ។

" ដីដែលមិនទាន់បានចុះបញ្ជីសុរិយោដី " គឺជាក្បាលដីទាំងឡាយដែលមិនទាន់បានចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ឬ មានលក្ខណៈដាច់ដោយដុំស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១ ។

"បុគ្គល" រួមមាន រូបវន្តបុគ្គល ឬ នីតិបុគ្គល ។

" ដើមបណ្តឹង" គឺជាជនដែលធ្វើការប្តឹងទាមទារអោយមានការដោះស្រាយវិវាទដោយអនុលោមតាមប្រកាសនេះ ។

" ចុងបណ្តឹង" គឺបុគ្គលដែលជំទាស់ទៅនឹងដើមបណ្តឹង ។

## ២. ការចាប់ផ្តើមដំណើរការដោះស្រាយទំនាស់

**ប្រការ ៣ :-**

បុគ្គលទាំងឡាយដែលទាមទារកម្មសិទ្ធិ (ឬ សិទ្ធិកម្មសិទ្ធិ) ឬភោគៈ (ឬ សិទ្ធិភោគៈ) លើដីមិនទាន់បានចុះបញ្ជីសុរិយោដី ហើយដីនោះមានបុគ្គលម្នាក់ ឬច្រើននាក់ផ្សេងទៀតបានទាមទារមួយផ្នែកឬទាំងមូលដែរ អាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការ សុរិយោដីថ្នាក់ស្រុក ឬ ខណ្ឌ ដែលដីនោះស្ថិតនៅ ។

**ប្រការ ៤ :-**

បុគ្គលដែលប្តឹងទាមទារធ្វើជាកម្មសិទ្ធិករ ឬ ភោគីនៃដីត្រូវដាក់ពាក្យបណ្តឹង លើកលែងតែក្នុងករណីដែលជននោះជាអសមត្ថជន ។ ក្នុងករណីនេះ អ្នកតំណាងស្របច្បាប់របស់ជននោះ អាចដាក់ពាក្យបណ្តឹងក្នុងនាមជននោះបាន ។

**ប្រការ ៥ :-**

បណ្តឹងទាមទារ ត្រូវធ្វើតាមទម្រង់បែបបទនៃពាក្យបណ្តឹង ដូចមាននៅក្នុងឧបសម្ព័ន្ធទី ១នៃប្រកាសនេះ ។ ដើមបណ្តឹង អាចទទួលយកទម្រង់បែបបទនៃពាក្យបណ្តឹងនេះពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬអាចធ្វើទម្រង់បែបបទនៃពាក្យបណ្តឹងរបស់ខ្លួនបាន អោយតែទម្រង់បែបបទនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់បែប បទនៃពាក្យបណ្តឹង ដូចមាន កំណត់នៅក្នុងឧបសម្ព័ន្ធទី ១ ។

ពាក្យបណ្ដឹង ត្រូវបញ្ចូលពត៌មានស្ដីពីដើមបណ្ដឹងដូចតទៅ : ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ភេទ ឈ្មោះសហព័ទ្ធ (ប្ដី-ប្រពន្ធ) កូន ឃុំ ស្រុក ខេត្ត មុខរបរ អាស័យដ្ឋានបច្ចុប្បន្ន ទីតាំងដីវិវាទ សេចក្ដីពណ៌នាពីវិវាទដោយមានភាពជាក់លាក់តាមដែលអាចធ្វើទៅបាន ឯកសារពាក់ព័ន្ធនានា ឈ្មោះ និង អាស័យដ្ឋានរបស់ចុងបណ្ដឹង ។ ដើមបណ្ដឹងត្រូវផ្ដល់រាល់ពត៌មានដូចបានតំរូវនៅក្នុងទម្រង់បែបបទបណ្ដឹងហើយត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខា ឬ ផ្ដិតមេដៃលើពាក្យបណ្ដឹងនោះ ។

ដើមបណ្ដឹងត្រូវ ផ្ដល់បែបបទបណ្ដឹងដែលបំពេញរួចយ៉ាងហោចចំនួន ០៤ ច្បាប់ ដែលមួយច្បាប់សំរាប់រក្សាទុកក្នុងសំណុំឯកសាររបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌមួយច្បាប់សំរាប់បិទផ្សាយ មួយច្បាប់សំរាប់បញ្ជូនទៅអោយដើមបណ្ដឹងវិញ និងមួយច្បាប់ទៀតសំរាប់ចុងបណ្ដឹង ។ ក្នុងករណីមានចុងបណ្ដឹងច្រើននាក់មានឈ្មោះនៅក្នុងពាក្យបណ្ដឹងនោះដើមបណ្ដឹងត្រូវផ្ដល់ឯកសារពាក្យបណ្ដឹងមួយច្បាប់ៗដល់ចុងបណ្ដឹងម្នាក់ៗដែលមានឈ្មោះ ។

**ប្រការ ៦ :-**

នៅពេលទទួលពាក្យបណ្ដឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបើកសំណុំរឿង ហើយត្រូវកំណត់លេខដើម្បី ជាការសំគាល់សំណុំរឿងវិវាទតាម ខេត្ត និងស្រុក ដែលដីវិវាទនោះស្ថិតនៅ ។

មន្ត្រីទទួលពាក្យបណ្ដឹង ត្រូវចុះលេខសំគាល់សំណុំរឿងវិវាទ ចុះហត្ថលេខា និង បោះត្រាផ្លូវការលើទម្រង់បែបបទនៃពាក្យបណ្ដឹងច្បាប់ដើម ហើយផ្ដល់ឯកសារដែលបានចុះបញ្ជីមួយច្បាប់ទៅដើមបណ្ដឹងវិញ ។ ឯកសារនេះគឺជាភស្ដុតាងនៃការដាក់ ពាក្យបណ្ដឹងរបស់ដើមបណ្ដឹង ។

មន្ត្រីទទួលពាក្យបណ្ដឹង ត្រូវថតចម្លងឯកសារនានាដែលបានភ្ជាប់មកជាមួយពាក្យបណ្ដឹងហើយត្រូវបញ្ចូលឯកសារថតចម្លងទាំងនេះទៅក្នុងសំណុំរឿងផ្លូវការ ។ មន្ត្រីទទួលពាក្យបណ្ដឹង ត្រូវបង្វិលឯកសារច្បាប់ដើមទៅអោយដើមបណ្ដឹងវិញ ។

**ប្រការ ៧ :-**

ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលពាក្យបណ្ដឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវបិទផ្សាយពាក្យបណ្ដឹងនោះរួមជាមួយនិងសេចក្ដីជូនដំណឹងអំពីបណ្ដឹងរៀបចំឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌដែលបញ្ជាក់ថាពាក្យបណ្ដឹងនោះបានចុះបញ្ជីហើយ ។ សេចក្ដីជូនដំណឹងពីបណ្ដឹងត្រូវធ្វើឡើងតាមទម្រង់បែបបទដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ២ ។ សេចក្ដីជូនដំណឹងនោះ ត្រូវអញ្ជើញបុគ្គលគ្រប់រូបដែលមានផលប្រយោជន៍នៅក្នុងដីវិវាទអោយឆ្លើយតបចំពោះពាក្យបណ្ដឹងក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយសេចក្ដីជូនដំណឹង និង ពាក្យបណ្ដឹងនោះ ។

ពាក្យបណ្តឹង និង សេចក្តីជូនដំណឹងអំពីពាក្យបណ្តឹងមួយច្បាប់ត្រូវបិទផ្សាយនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ហើយសាធារណជនអាចចូលមើលបានដោយសេរីក្នុងអំឡុងពេលម៉ោងធ្វើការធម្មតា ។ ត្រូវអនុញ្ញាតឱ្យជនគ្រប់រូបមើលសេចក្តីជូនដំណឹងដែលបានបិទផ្សាយនោះដើម្បីអោយដឹងថា តើខ្លួនមានផលប្រយោជន៍នៅក្នុងវិវាទនោះឬទេ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបិទសេចក្តីជូនដំណឹងមួយច្បាប់នៅលើទីតាំងដីដែលមានវិវាទ ។

ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់ចុងបណ្តឹងដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងអំពីការប្តឹងទាមទារនោះ តាមរយៈការផ្តល់ដល់ចុងបណ្តឹង នូវពាក្យបណ្តឹងដែលបំពេញរួចម្នាក់មួយច្បាប់ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់ចុងបណ្តឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការឆ្លើយតបចំពោះបណ្តឹងទាមទារនោះ ហើយត្រូវជូនដំណឹងដល់ចុងបណ្តឹងអំពីសិទ្ធិចូលរួមប្រជុំជាមួយគណៈកម្មការសុរិយោដី ថ្នាក់ស្រុក ខណ្ឌ ដើម្បីពិគ្រោះយោបល់អំពីបណ្តឹង ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់អោយចុងបណ្តឹងនូវសេចក្តីសង្ខេបអំពីរបៀបសម្រុះសម្រួល ។

**ប្រការ ៨ :-**

ចុងបណ្តឹងដែលមានឈ្មោះក្នុងពាក្យបណ្តឹង អាចឆ្លើយតបចំពោះបណ្តឹងតាមរយៈការដាក់សំណុំបែបបទឆ្លើយតបចំពោះបណ្តឹងដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី ៤ ទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីបានទទួលឯកសារចម្លងនៃពាក្យបណ្តឹងពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់ដល់ចុងបណ្តឹងនូវឯកសារថតចម្លងមួយច្បាប់នៃពាក្យបណ្តឹង និង សេចក្តីសង្ខេបអំពីរបៀប សម្រុះសម្រួល ។

រាល់បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍នៅក្នុងដីវិវាទនេះ ត្រូវដាក់បែបបទឆ្លើយតបចំពោះបណ្តឹងក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីពេលដែលសេចក្តីជូនដំណឹងអំពីបណ្តឹងត្រូវបានបិទផ្សាយនៅការិយាល័យគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និង នៅលើទីតាំងដីវិវាទដោយគិតពេលកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងមួយណាដែលបិទក្រោយគេ ។

ចុងបណ្តឹង អាចទទួលបានទម្រង់បែបបទឆ្លើយតបចំពោះបណ្តឹងពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬអាចដាក់ទម្រង់បែបបទរបស់ខ្លួនផ្ទាល់បាន អោយតែទម្រង់បែបបទនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់បែបបទដូចមាន កំណត់ក្នុងឧបសម្ព័ន្ធទី ៤ ។

ចុងបណ្ដឹងនោះ ត្រូវផ្ដល់ទម្រង់បែបបទឆ្លើយតបចំពោះបណ្ដឹងដែលបំពេញរួចយ៉ាងហោចចំនួន០៤ច្បាប់ ដែលមួយច្បាប់សំរាប់រក្សាទុកក្នុងសំណុំរឿងរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មួយច្បាប់សំរាប់បិទផ្សាយ មួយច្បាប់សំរាប់បញ្ជូនទៅអោយដើមបណ្ដឹងវិញ និងមួយច្បាប់ទៀតសំរាប់ចុងបណ្ដឹង ។ ក្នុងករណីមានចុងបណ្ដឹង ឬដើមបណ្ដឹងច្រើននាក់មានឈ្មោះនៅក្នុងពាក្យបណ្ដឹង នោះចុងបណ្ដឹងត្រូវផ្ដល់ឯកសារចម្លងឆ្លើយតបចំពោះបណ្ដឹងដល់ចុងបណ្ដឹង និង/ឬ ដើមបណ្ដឹង ដែលមានឈ្មោះ ម្នាក់១មួយច្បាប់ ។

ចុងបណ្ដឹង ត្រូវបង្ហាញឯកសារពាក់ព័ន្ធនៅពេលដាក់ពាក្យឆ្លើយតបចំពោះបណ្ដឹង ។ មន្ត្រីទទួលពាក្យត្រូវថតចម្លងឯកសារដែលបានដាក់ភ្ជាប់មកជាមួយនោះ រួចហើយបង្វិលឯកសារច្បាប់ដើមទាំងនោះទៅអោយចុងបណ្ដឹងវិញ ។

ពាក្យឆ្លើយតប និង ឯកសារដែលបានភ្ជាប់មកជាមួយនោះ ត្រូវបញ្ចូលទៅក្នុងសំណុំរឿងវិវាទផ្លូវការ ។

**ប្រការ ៩ :-**

គ្មានករណីណាមួយដែលដើមបណ្ដឹង ឬ ចុងបណ្ដឹងណាម្នាក់ត្រូវបានគេសុំ ឬតម្រូវអោយបង់ថ្លៃដាក់ពាក្យបណ្ដឹង ឬពាក្យឆ្លើយតបឡើយ ។

## ៣ . ការស៊ើបអង្កេត

**ប្រការ ១០ :-**

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវចាត់មន្ត្រីសុរិយោដីចុះទៅធ្វើការស៊ើបអង្កេតបណ្ដឹង ។ អ្នកស៊ើបអង្កេតត្រូវចុះទៅជួបភាគីទាំងអស់ កត់ត្រាសេចក្ដីអះអាងរបស់ភាគី និងប្រមូលរាល់ពត៌មានទាក់ទងផ្សេង១ និង ភស្តុតាងផ្សេង១ ទាក់ទងនឹងវិវាទនោះ រួមទាំងពត៌មានដែលចាំបាច់ដើម្បីកំណត់ថា តើភាគីពាក់ព័ន្ធទាំងអស់ក្នុងវិវាទដីធ្លីនេះមានឈ្មោះនៅក្នុងសំណុំរឿងវិវាទដែលបានដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ហើយឬនៅ ថាជាភាគីនៃវិវាទឬ អត់ ។ ការស៊ើបអង្កេតត្រូវចាប់ផ្ដើមអោយបានឆាប់បំផុតតាមដែលអាចធ្វើទៅបានបន្ទាប់ពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ បានទទួលពាក្យបណ្ដឹង ។

**ប្រការ ១១ :-**

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវវាស់វែង និងកំណត់ព្រំដីដែលមានវិវាទ ស្របតាមនីតិវិធីដូចមានចែងនៅក្នុងអនុក្រឹត្យស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ។ ប្រសិនបើរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ មិនអាចបំពេញការ៤៤-

ទទួលខុសត្រូវនេះបានដោយសារតែខ្លួនពុំមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ នោះអាចស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាល សុរិយោដីខេត្ត ក្រុង ។

**ប្រការ ១២ :-**

អ្នកស៊ើបអង្កេតមានសិទ្ធិជួបបុគ្គលណាម្នាក់ ឬ មានសិទ្ធិមើលឯកសារដែលកំណត់ថាចាំបាច់សំរាប់ការស៊ើបអង្កេតឱ្យបានពេញលេញ ។

បុគ្គលទាំងឡាយរួមទាំងសាក្សីរបស់ភាគី និង សាក្សីឯទៀតត្រូវជួបជាមួយអ្នកស៊ើបអង្កេត ប្រសិនបើខ្លួនត្រូវបានស្នើសុំដោយអ្នកស៊ើបអង្កេត ហើយអ្នកស៊ើបអង្កេតត្រូវកំណត់ការប្រជុំតាមពេលវេលា និង ទីកន្លែងដែលងាយស្រួលចំពោះអ្នកពាក់ព័ន្ធ ទាំងឡាយ ។

ឯកសារច្បាប់ដើមទាំងឡាយត្រូវបង្វិលទៅអោយអ្នកដែលផ្តល់ឯកសារនោះវិញ ហើយច្បាប់ថតចម្លងនៃឯកសារនោះត្រូវរក្សាទុកនៅក្នុងកំណត់ហេតុផ្លូវការនៃវិវាទ ។

**ប្រការ ១៣ :-**

ភាគីវិវាទនីមួយៗ ត្រូវមានវត្តមានក្នុងពេលធ្វើការស៊ើបអង្កេតដល់ទីកន្លែង និងត្រូវបាន់ស្មានសោហ៊ុយដែលទាក់ទងទៅនឹងការស៊ើបអង្កេតម្តងទៀតក្នុងករណីដែលមានភាគីណាមួយអវត្តមាន ។ បើអវត្តមានរបស់ភាគីមួយបង្កឡើងដោយសារទង្វើមិនសមរម្យរបស់ភាគីឯទៀត នោះភាគីដែលមានកំហុសត្រូវចេញសោហ៊ុយសំរាប់ថ្លៃការស៊ើបអង្កេតជាថ្មីនោះ។

**ប្រការ ១៤ :-**

ភាគីវិវាទ អាចផ្តល់ភស្តុតាង និងសាក្សីបាន ហើយរាល់ភស្តុតាង និងចម្លើយរបស់សាក្សីទាំងនោះត្រូវក្លាយជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ ។

អ្នកស៊ើបអង្កេត ត្រូវទទួលយក និង បញ្ចូលជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទនូវរាល់ភស្តុតាងដែលត្រូវបានផ្តល់ដោយភាគី ឬ ដែលត្រូវបានប្រមូលក្នុងអំឡុងពេលធ្វើការស៊ើបអង្កេត ។ ភស្តុតាងទាំងនោះមានជាអាទិ៍ :

- ផែនទី ឬ កំណត់ហេតុអង្កេតវាស់វែង
- ឯកសារសំគាល់ការកាន់កាប់ដី
- រូបថត របស់ភាគីកាន់កាប់ដី

- សំបុត្រស្នាមផ្សេងៗដែលបានធ្វើដោយមានចុះអាស័យដ្ឋាននៃដីនោះ សំបុត្រកំណើត ឬ ប័ណ្ណគ្រួសារ ដែលបង្ហាញពីវត្តមានយូរអង្វែងនៅលើដីនោះ ឬសៀវភៅសម្រង់ស្ថិតិរបស់ប្រធានភូមិ
- ចម្លើយរបស់អ្នកជិតខាងថា តើនរណាដែលបានរស់នៅលើដីនោះ
- បង្កាន់ដៃទទួលប្រាក់ ឬ ឯកសារផ្សេងៗទាក់ទងទៅនឹងការទិញដី ឬ ការផ្ទេរសិទ្ធិនៃដីនោះ ។

**ប្រការ ១៥ :-**

អ្នកស៊ើបអង្កេត ត្រូវសម្ភាសន៍សាក្សីទាំងឡាយដែលផ្តល់ដោយភាគីវិវាទ ឬ ដែលអ្នកស៊ើបអង្កេតចាត់ទុកថាចាំបាច់ដើម្បីបញ្ជាក់អង្គហេតុនៃវិវាទ ។ សាក្សីនីមួយៗត្រូវធ្វើសម្បថ ថានឹងនិយាយតែការពិតហើយរាយការណ៍រាល់ព្រឹត្តិការណ៍ និង អង្គហេតុទាំងឡាយដែលសាក្សីយល់ និងជឿថាត្រឹមត្រូវ ។

អ្នកស៊ើបអង្កេត ត្រូវពិនិត្យសាក្សីនីមួយៗដើម្បីកំណត់អំពីភាពគួរអោយជឿបាននៅក្នុងចម្លើយរបស់សាក្សី តើសាក្សីដឹងកើតណា ការដឹងរបស់សាក្សីផ្អែកលើព្រឹត្តិការណ៍ទាំងឡាយដែលបានសង្កេតឃើញដោយខ្លួនឯងផ្ទាល់ ឬដោយគ្រាន់តែបានឮពីអ្នកណាម្នាក់ផ្សេងទៀត ។ ចម្លើយសាក្សី និង ការសម្ភាសន៍សាក្សីត្រូវទុកជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ ។

**ប្រការ ១៦ :-**

អ្នកស៊ើបអង្កេត ត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការស៊ើបអង្កេតដោយអនុលោមតាមទំរង់នៃស្តង់ដារដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី ៥ ។ លទ្ធផលទាំងនេះត្រូវរួមបញ្ចូលនូវ ព្រំដីវិវាទ ផែនទី ឬ គំនូសតាងពាក់ព័ន្ធ សេចក្តីសង្ខេបអំពីចម្លើយរបស់សាក្សី និងចម្លើយលាយលក្ខណ៍អក្សរ សេចក្តីសង្ខេបនៃរាល់ឯកសារពាក់ព័ន្ធទៅនឹងដីវិវាទដែលមានការអះអាងដោយអ្នកស៊ើបអង្កេត ឬ ដែលបានទទួលពីភាគីវិវាទ ។

## ៤. ការកំណត់អំពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ថ្នាក់ស្រុក ខណ្ឌ ក្នុងការសម្រុះសម្រួលវិវាទ

**ប្រការ ១៧ :-**

បន្ទាប់ពីការស៊ើបអង្កេតត្រូវបានបញ្ចប់ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវកំណត់ថាតើគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានសមត្ថកិច្ចធ្វើការសម្រុះសម្រួលវិវាទនោះដែរឬទេ ។

វិវាទទាំងឡាយត្រូវ សម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ លើកលែងតែប្រធានគណៈកម្ម-

ការសុរិយោដីថ្នាក់ស្រុក ខណ្ឌ កំណត់ថាវិវាទនោះមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដោយសំអាងលើហេតុផលនានាដូចមានចែងនៅក្នុងប្រការ ១៨ នៃប្រកាសនេះ ឬ ដោយវិវាទនោះកើតឡើងដោយសារភាគីមួយ ឬច្រើនប្តឹងផ្អែកលើមូលដ្ឋានមិនច្បាស់លាស់ដូចមានចែងក្នុងប្រការ ១៩ នៃប្រកាសនេះ ។

**ប្រការ ១៨ :-**

ប្រសិនបើវិវាទមិនអាចដោះស្រាយបានដោយសមធម៌នៅថ្នាក់ស្រុក ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវដាក់សំណុំរឿងវិវាទនោះដោយផ្ទាល់ជូនទៅគណៈកម្មសុរិយោដីថ្នាក់ខេត្ត ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬ តាមសំណើរបស់ភាគីវិវាទទាំងសងខាងដូចមានចែងនៅក្នុងមាត្រា ១០ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

ប្រសិនបើមានភាគីតែម្ខាង ស្នើអោយបញ្ជូនករណីវិវាទនោះទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង វិវាទនោះត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងលើកលែងតែប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ យល់ឃើញថាសំណើនោះមិនសមហេតុផល ។ ហេតុផលនៃការបដិសេធសំណើនោះរួមមានការកំណត់របស់ប្រធានគណៈកម្មការដែលយល់ថាសំណើនោះធ្វើឡើងគ្រាន់តែដើម្បីឱ្យមានការយឺតយ៉ាវដល់ការដោះស្រាយវិវាទ ឬ បង្កអោយមានការលំបាកដល់ភាគីម្ខាងទៀត និងអាច មានហេតុផលផ្សេងទៀត ។

ប្រសិនបើប្រធានគណៈកម្មការ បដិសេធមិនបញ្ជូនវិវាទនោះដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង តាមសំណើរបស់ភាគីម្ខាង ប្រធានគណៈកម្មការ ត្រូវពន្យល់ជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការបដិសេធសំណើនោះ ហើយការពន្យល់នេះត្រូវតែជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទនោះ ។ ការសម្រុះសម្រួលដែលតម្រូវឱ្យមានការបញ្ជូនករណីវិវាទ ទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង រួមមាន :

- ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួនដែរ
- ភាគីម្ខាងនៃវិវាទគឺជាអាជ្ញាធរមានឋានៈខ្ពស់
- ករណីមានវិវាទពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការថ្នាក់ស្រុក ខណ្ឌ
- វិវាទពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ ។

ក្នុងករណីណាក៏ដោយ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មិនមានសិទ្ធិអំណាចសម្រុះសម្រួលវិវាទដែលទាក់ទងទៅ នឹងដីសាធារណៈរបស់រដ្ឋឡើយ ។

**ប្រការ ១៩ :-**

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវច្រានចោលបណ្តឹងទាមទារណាដែលមិនត្រឹមត្រូវ ឬ គ្មានមូលដ្ឋាន ឬ ដែលធ្វើឡើងដើម្បីយាយី ឬ បំភិតបំភ័យភាគីម្ខាង ។ ការច្រានចោលបណ្តឹងមិនមែនជាប្រការគួរលើកទឹកចិត្តអោយធ្វើនោះទេលើកលែងតែក្នុងករណីចាំបាច់ដើម្បីរារាំងភាពអយុត្តិធម៌តែប៉ុណ្ណោះ ។

បណ្តឹងមិនត្រឹមត្រូវ គឺបណ្តឹងដែលខ្វះមូលដ្ឋានអង្គហេតុសមហេតុផលឬទាក់ទងទៅនឹងវិវាទដែលស្ថិតនៅក្រៅវង្វង់សមត្ថកិច្ចនៃច្បាប់ភូមិបាលឆ្នាំ ២០០១ ។ លក្ខខណ្ឌនៃបណ្តឹងដែលមិនមានមូលដ្ឋានអង្គហេតុគ្រប់គ្រាន់ មានជាអាទិ៍ :

- សាក្សី ឬ ភស្តុតាងរបស់ភាគីម្ខាង បង្ហាញថាមានលក្ខណៈក្លែងបន្លំ ឬ ខុស ដូចជា សាក្សីរបស់ភាគីម្ខាងដកពាក្យចម្លើយរបស់ខ្លួនវិញ ឬ ផ្តល់ចម្លើយដែលប្រឆាំងដោយត្រង់ទៅនឹងការទាមទាររបស់ភាគីម្ខាង
- ការស៊ើបអង្កេត និងពត៌មានផ្សេងទៀតដែលភាគីស្នើឡើងមិនបង្ហាញភស្តុតាងណាមួយដែលគាំទ្រដល់ការទាមទាររបស់ភាគីដូចមានក្នុងពាក្យបណ្តឹង ។

ក្នុងករណីបណ្តឹងត្រូវបានច្រានចោល ភាគីអាចប្តឹងតវ៉ាទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ភាគីណាមួយដែលធ្វើការទាមទារដោយគ្មានមូលដ្ឋាន ឬ មិនមានលក្ខណៈច្បាប់ ត្រូវចេញសោហ៊ុយថ្លៃដំណើរការវិវាទដែលបានចំណាយមកដល់ពេលនោះ និង ត្រូវទទួលទោសព្រហ្មទណ្ឌបន្ថែមទៀតដោយអនុលោមតាមច្បាប់ភូមិបាល ២០០១ និង ច្បាប់ផ្សេងៗទៀត ។ ត្រូវរារាំងមិនអោយភាគីដែលដាក់ពាក្យបណ្តឹងមិនត្រឹមត្រូវ ប្តឹងទាមទារជាថ្មីម្តងទៀត ។

ភាគីណាដែលបង្ហាញភស្តុតាងក្លែងបន្លំ ត្រូវដកចេញពីដំណើរការវិវាទ ហើយភស្តុតាងត្រូវដកចេញពីកំណត់ហេតុផ្លូវការនៃវិវាទ និងត្រូវទទួលទោសព្រហ្មទណ្ឌបន្ថែមទៀតដូចមានចែងនៅក្នុងច្បាប់ភូមិបាល ២០០១ និងច្បាប់ផ្សេងៗទៀត ។ ភាគីណាដែលត្រូវបានរកឃើញថា បានធ្វើការក្លែងបន្លំភស្តុតាង ឬឯកសារអាចទទួលទោសព្រហ្មទណ្ឌដូចមានចែងនៅក្នុងច្បាប់ភូមិបាល ឆ្នាំ ២០០១ និង ច្បាប់ផ្សេងៗទៀត ។

## ៥. ការសម្រុះសម្រួលរបស់គណៈកម្មការ សុរិយោដីថ្នាក់ស្រុក ខណ្ឌ

**ប្រការ ២០ :-**

បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត មិនតិចជាង ៣០ ថ្ងៃបន្ទាប់ពីសេចក្តីជូនដំណឹងពីបណ្តឹងត្រូវបានបិទផ្សាយដូចមានចែងក្នុងប្រការ ៧នៃប្រកាសនេះប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវរៀបចំប្រជុំគណៈកម្មការសុរិយោដី

ថ្នាក់ស្រុក ខណ្ឌដើម្បីសំរេចលើដំណើរការសម្រុះសម្រួលវិវាទ ។ កិច្ចប្រជុំត្រូវធ្វើឡើងនៅលើដីវិវាទ ឬកន្លែងដែលនៅជិតដីវិវាទតាមដែលអាចធ្វើទៅបាន ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ និង/ឬ ចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិករាជហុករបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដើម្បីសម្រុះសម្រួលវិវាទ ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញភាគីវិវាទមកចូលរួមការប្រជុំរដ្ឋបាលយ៉ាងហោច ៥ ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃប្រជុំនេះ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់ដល់ភាគីទាំងអស់នូវសេចក្តីសង្ខេបអំពីរបៀបសម្រុះសម្រួល និងត្រូវពន្យល់អំពីពត៌មាននេះដល់ភាគីទាំងអស់ ។

នៅពេលប្រជុំរដ្ឋបាលនេះ ភាគីត្រូវជូនដំណឹងដល់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អំពីការស្នើសុំរបស់ខ្លួនឱ្យបញ្ជូនសំណុំរឿងវិវាទនេះទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវធ្វើការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍នានា និង ធ្វើការព្រមព្រៀងជាឯកច្ឆ័ន្ទលើសមាសភាពអ្នកសម្រុះសម្រួលដូចមានចែងក្នុង ប្រការ ២២ នៃប្រកាសនេះ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលវិវាទ ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទាំងឡាយ និង កំណត់ពេលវេលាសំរាប់ការសម្រុះសម្រួលវិវាទ ។

**ប្រការ ២១ :-**

ប្រសិនបើ មានសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិករូបនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ ។

ប្រសិនបើ មានវិវាទអំពីផលប្រយោជន៍ជាមួយប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ វិវាទនោះត្រូវដាក់ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ភាគីអាចប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរទំពោះការចូលរួមរបស់សមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក ។ សមាជិកដទៃទៀតនៃគណៈកម្មការត្រូវសំរេចថាតើ សមាជិករូបនោះមានវិវាទអំពីផលប្រយោជន៍ដែលរារាំងមិនឱ្យសមាជិករូបនោះចូលរួមនៅក្នុងការដោះស្រាយវិវាទ ឬទេ ។ វិវាទអំពីផលប្រយោជន៍ដែលចោទប្រកាន់ចំពោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវដោះស្រាយតាមនីតិវិធីដូចមានកំណត់ក្នុងប្រការ ១៨ នៃប្រកាសនេះ ។

**ប្រការ ២២ :-**

ភាគីវិវាទ អាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាជហុក និងសមាជិកអចិន្ត្រៃយ៍នៃគណៈ-កម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នៅក្នុងលក្ខខណ្ឌតែមួយគត់គឺភាគីទាំងអស់ព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរក្នុងការប្រើអ្នកសម្រុះសម្រួលជាក់លាក់នោះ ។

ក្នុងករណីភាគីវិវាទមិនអាចព្រមព្រៀងគ្នាលើសមាសភាពអ្នកសម្រុះសម្រួលជាក់លាក់ណាមួយមកពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌទេនោះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវចាត់តាំងអ្នកសម្រុះសម្រួលចេញពីសមាជិកអាជហុក និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក ៣ រូប ដែលមានម្នាក់ជាប្រធាន ត្រូវសម្រុះសម្រួលវិវាទ ។

សមាជិកទាំងឡាយនៃក្រុមអ្នកសម្រុះសម្រួល យ៉ាងហោចណាស់ត្រូវមានសមាជិកម្នាក់ដែលបានទទួលការបណ្ដុះបណ្ដាល ឬមានបទពិសោធន៍នៅក្នុងការសម្រុះសម្រួលវិវាទ និង មានសមាជិកម្នាក់ជាអ្នកដឹងអំពីស្ថានភាព និងស្ថានភាពការណ៍នៅក្នុង មូលដ្ឋាន ។

ប្រសិនបើ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ កំណត់ថាគ្មានសមាជិកណាម្នាក់នៃសមាជិកក្រុមអ្នកសម្រុះសម្រួលមានបទពិសោធន៍ ឬ ការបណ្ដុះបណ្ដាលនៅក្នុងដំណើរការសម្រុះសម្រួលទេនោះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អាចស្នើសុំឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ចាត់តាំងអ្នកសម្រុះសម្រួលដែលបានទទួលការបណ្ដុះបណ្ដាលអោយចូលរួមនៅក្នុងក្រុមអ្នកសម្រុះសម្រួល ។

**ប្រការ ២៣ :-**

ភាគីវិវាទអាចជ្រើសរើសបុគ្គលម្នាក់តាមជំរើសរបស់ខ្លួនផ្ទាល់ឱ្យជួយខ្លួននៅគ្រប់ថ្នាក់នៃដំណើរការសម្រុះសម្រួល ។ បុគ្គលរូបនេះហៅថាអ្នកជំនួយការភាគី ឬអ្នកជំនួយការមិនអាចតំណាងឱ្យភាគីបានទេ ប៉ុន្តែអាចផ្ដល់យោបល់ដល់ភាគីវិវាទបាន ។ អ្នកជំនួយការភាគី អាចបំភ្លឺយោបល់របស់ភាគី និងអាចចូលរួមនៅក្នុងកិច្ចប្រជុំទាំងឡាយជាមួយអ្នក

សម្រុះសម្រួល និងជាមួយភាគីបាន ប៉ុន្តែមិនអាចនិយាយជំនួសភាគីទៅកាន់អ្នកសម្រុះសម្រួល ឬ ភាគីផ្សេងទៀតបានទេ ឬ មិនអាចធ្វើសេចក្តីសំរេចក្នុងនាមភាគីបានឡើយ ។

ប្រសិនបើអ្នកជំនួយការភាគីនោះបំពានវិធាននៃដំណើរការវិវាទ ក្រុមអ្នកសម្រុះសម្រួលត្រូវផ្តល់ការក្រើនរំលឹក និងការព្រមានជាឯកជនម្តងដល់អ្នកជំនួយការនោះ ។ ប្រសិនបើអ្នកជំនួយការនោះបន្តបំពានទៀតក្រុមអ្នកសម្រុះសម្រួលត្រូវហាមឃាត់អ្នកជំនួយការនោះមិនឱ្យចូលរួមនៅក្នុងដំណើរការវិវាទតទៅទៀតឡើយ ។ ប្រសិនបើអ្នកជំនួយការត្រូវបានរារាំង ដំណើរការសម្រុះសម្រួលត្រូវផ្អាកមួយរយៈរហូតដល់ភាគីវិវាទជ្រើសរើសអ្នកជំនួយការថ្មីបាន ឬ ព្រមព្រៀងបន្តដំណើរការដោយពុំចាំបាច់មានអ្នកជំនួយការ ។ អ្នកសម្រុះសម្រួលត្រូវផ្តល់អោយភាគីម្ខាង១នូវឱកាសគ្រប់គ្រាន់ដើម្បីពិគ្រោះយោបល់ជាមួយអ្នកជំនួយការដែលត្រូវបានហាមឃាត់នៅខាងក្រៅកន្លែងធ្វើការសម្រុះសម្រួល ។

**ប្រការ ២៤ :-**

អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទាំងឡាយរួមគ្នា ឬ ដាច់ដោយឡែកពីគ្នាប្រសិនបើមានការស្នើសុំដើម្បីពិភាក្សាពីបញ្ហារបស់ភាគី ពន្យល់ករណីវិវាទដល់ភាគីវិវាទដោយផ្អែកលើភស្តុតាង និងពិគ្រោះអំពីលទ្ធភាពដំណោះ-ស្រាយនានាដែលអាចមានចំពោះវិវាទ ។ ការពិគ្រោះត្រូវធ្វើឡើងដោយរក្សាការសំងាត់ក្នុងចំណោមភាគីវិវាទអ្នកជំនួយការរបស់ភាគី និង អ្នកសម្រុះសម្រួលហើយមិនត្រូវយកការពិគ្រោះនេះទៅធ្វើជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទឡើយ ។

អ្នកសម្រុះសម្រួល អាចស្នើដំណោះស្រាយដោយផ្អែកលើការយល់ដឹងរបស់ខ្លួនអំពីបំណងរបស់ភាគីវិវាទលើភស្តុតាងដែលមាន និងផ្អែកលើច្បាប់ពាក់ព័ន្ធប៉ុន្តែអ្នកសម្រុះសម្រួលមិនត្រូវបង្ខំឱ្យអនុវត្តតាមសំណើរបស់ខ្លួន ឬ មិនត្រូវធ្វើសេចក្តីសំរេចលើ វិវាទនោះឡើយ ។ មានតែភាគីវិវាទទេដែលមានសិទ្ធិសំរេច ឬបដិសេធដំណោះស្រាយបាន ។

**ប្រការ ២៥ :-**

អ្នកសម្រុះសម្រួលត្រូវវិភាគភស្តុតាង ដែលប្រមូលបាននៅក្នុងពេលស៊ើបអង្កេតដើម្បីយល់អោយបានពេញលេញអំពីស្ថានភាពនៃវិវាទ ប៉ុន្តែអ្នកសម្រុះសម្រួលមិនត្រូវវាយតំលៃភស្តុតាងក្នុងសមត្ថភាពជាផ្លូវការណាមួយឡើយ ។

អ្នកសម្រុះសម្រួលអាចផ្តល់យោបល់ដល់ភាគីវិវាទ អំពីរបៀបបកស្រាយភស្តុតាងវិវាទ ឬ តំលៃនៃភស្តុតាងអាចត្រូវបានបកស្រាយយ៉ាងណា ប៉ុន្តែយោបល់ទាំងនេះពុំមានតំលៃខាងផ្លូវច្បាប់ និង មិនអាចក្លាយជាលំអានសំរាប់អនុវត្តនៅក្នុងដំណើរការសម្រុះសម្រួល ឬ ការវិនិច្ឆ័យណាមួយឡើយ ។

ការវាយតម្លៃភស្តុតាង អាចបញ្ចូលជាផ្នែកមួយនៃរបាយការណ៍សម្រុះសម្រួលដែលត្រូវបញ្ចូលទៅក្នុងកំណត់ហេតុផ្លូវការ នៃវិវាទ ។

**ប្រការ ២៦ :-**

ប្រសិនបើភាគីទាំងឡាយ អាចឈានដល់ការព្រមព្រៀងក្នុងពេលសម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អ្នកសម្រុះសម្រួលត្រូវបំពេញបែបបទបញ្ចប់វិវាទដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ៦ ដែលមានរៀបរាប់អំពីដំណើរការដំណោះស្រាយដោយបញ្ជាក់ច្បាស់លាស់ពីការព្រមព្រៀងដោះស្រាយនោះ ។ រាល់ឯកសារឬផែនទីនានាដែលអាចបំភ្លឺកិច្ចដំណោះស្រាយនោះត្រូវតម្កល់ជាមួយបែបបទបញ្ចប់វិវាទ ។

អ្នកសម្រុះសម្រួល ត្រូវអានដំណោះស្រាយព្រមព្រៀងអោយភាគីទាំងអស់ស្តាប់ ។ ភាគីវិវាទត្រូវចុះហត្ថលេខាឬផ្តិតមេដៃលើកិច្ចព្រមព្រៀងតែក្នុងករណីដែលភាគីនោះយល់ព្រមលើរាល់ចំណុចនៃកិច្ចព្រមព្រៀង ។ កិច្ចព្រមព្រៀងនឹងមានសុពលភាពក្នុងករណីដែលភាគីវិវាទទាំងអស់បានព្រមព្រៀង និងបានចុះហត្ថលេខា ឬ បានផ្តិតមេដៃ ។ ភាគីវិវាទត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើបែបបទបញ្ចប់រឿងក្តីរួចតម្កល់បែបបទនោះនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ ។ មន្ត្រីទទួលទម្រង់បែបបទបញ្ចប់រឿងក្តីត្រូវចុះហត្ថលេខា និង បោះត្រាផ្លូវការលើទម្រង់បែបបទនេះហើយត្រូវផ្តល់ដល់ភាគីវិវាទនីមួយៗនូវឯកសារថតចម្លងនៃបែបបទនេះ ។ ច្បាប់ថតចម្លងនៃបែបបទបញ្ចប់រឿងក្តីនេះគឺជាភស្តុតាងនៃការដាក់តម្កល់កិច្ចដំណោះស្រាយ ។

រាល់ឯកសារទាក់ទងទៅនឹងលទ្ធផលនៃការដោះស្រាយវិវាទរួមទាំងបែបបទបញ្ចប់រឿងក្តី សេចក្តីពណ៌នានៃកិច្ចដំណោះស្រាយ និង ផែនទី ឬ គំនូសតាងនានាដែលអាចបំភ្លឺកិច្ចដំណោះស្រាយ ត្រូវបិទផ្សាយជាសាធារណៈដែលមានរយៈពេលមិនតិចជាង ១៤ ថ្ងៃ ។ បុគ្គលណាក៏ដោយក៏អាចបញ្ចេញមតិលើឯកសារបញ្ចប់រឿងក្តីនេះក្នុងអំឡុងពេលប្រកាសផ្សាយជាសាធារណៈ ។

ក្រុមអ្នកសម្រុះសម្រួល ត្រូវរាយការណ៍អំពីកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ បន្ទាប់មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវចាប់ផ្តើមនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះ ។

**ប្រការ ២៧ :-**

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវបញ្ជាក់អំពីដំណោះស្រាយជាមួយភាគីវិវាទ និងត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះនៅពេលទទួលបានការបញ្ជាក់ថាដំណោះស្រាយបានសំរេចដោយស្ម័គ្រចិត្ត និង ថាភាគីវិវាទយល់ពីកិច្ចព្រមព្រៀង ។

**ប្រការ ២៨ :-**

ប្រសិនបើភាគីមិនអាចឈានដល់ដំណោះស្រាយ ក្រុមអ្នកសម្រុះសម្រួលត្រូវរៀបចំរបាយការណ៍ស្តីពីដំណើរការសម្រុះសម្រួលអនុលោមតាមបែបបទស្តង់ដារដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៧ ។ របាយការណ៍ត្រូវរួមបញ្ចូលពត៌មានជាមូលដ្ឋានស្តីពីភាគីវិវាទ សេចក្តីសង្ខេបជំហររបស់ភាគីវិវាទនិងសេចក្តីសង្ខេបអំពីដំណើរការសម្រុះសម្រួល។ របាយការណ៍នេះត្រូវក្លាយជាផ្នែកមួយនៃកំណត់ហេតុសាធារណៈផ្លូវការនៃវិវាទ និង ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

## ៦. ការសម្រុះសម្រួលរបស់គណៈកម្មការ សុរិយោដីថ្នាក់ខេត្ត ក្រុង

**ប្រការ ២៩ :-**

ករណីសម្រុះសម្រួលជំហានដំបូង រួមមានវិវាទដែលត្រូវបានបញ្ជូនទៅឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដើម្បីធ្វើការសម្រុះសម្រួលដោយផ្ទាល់ដោយអនុលោមតាមប្រការ១៨ និងប្រការ២១ នៃប្រកាសនេះ ។ ករណីសម្រុះ-សម្រួលជំហានដំបូង ត្រូវបានបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញនៃវិវាទទៅអោយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

**ប្រការ ៣០ :-**

ករណីសម្រុះសម្រួលជំហានទី២ រួមមានវិវាទដែលដោះស្រាយមិនបានសំរេចនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ ករណីសម្រុះសម្រួលជំហានទី ២ត្រូវបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញ និងរបាយការណ៍សម្រុះ-សម្រួលទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

**ប្រការ ៣១ :-**

ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹងវិវាទសំរាប់ការសម្រុះសម្រួលជំហានដំបូង ឬ ការសម្រុះសម្រួលជំហានទី២ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវរៀបចំកិច្ចប្រជុំរដ្ឋបាលរវាងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងភាគីវិវាទ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង អាចអញ្ជើញតំណាងរបស់អាជ្ញាធរដែនដី ស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញខេត្តក្រុងពាក់ព័ន្ធនានាអោយចូលរួមជាសមាជិកអាដហុកដើម្បីសម្រុះសម្រួលវិវាទ ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំរដ្ឋបាលដំបូង ភាគីវិវាទត្រូវលើកសំណើ និង ការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍ ប្រសិនបើមាន ។ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលសំរាប់វិវាទនោះ ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីវិវាទ និងកំណត់ពេលវេលាសំរាប់អោយភាគីបង្ហាញភស្តុតាងបន្ថែមនានា និង ពេលវេលាសំរាប់សម្រុះសម្រួលវិវាទ ។

**ប្រការ ៣២ :-**

ប្រសិនបើសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងមានផលប្រយោជន៍ក្នុងវិវាទសមាជិករូបនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះហើយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ភាគី អាចដាក់ពាក្យបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងណាម្នាក់រួមទាំងប្រធានគណៈកម្មការដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក ។ សមាជិកដទៃទៀតនៃគណៈកម្មការ ត្រូវសំរេចថាតើសមាជិកដែលត្រូវជំទាស់អំពីវិវាទផលប្រយោជន៍នោះត្រូវរារាំងមិនឱ្យសាមីខ្លួនចូលរួមក្នុង ការដោះស្រាយវិវាទឬទេ ។

**ប្រការ ៣៣ :-**

ភាគីទាំងឡាយ អាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាដហុក និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង នៅក្នុងលក្ខខណ្ឌតែមួយគឺ ភាគីវិវាទទាំងអស់ព្រមព្រៀងជាលាយលក្ខណ៍អក្សរចំពោះការប្រើប្រាស់អ្នកសម្រុះសម្រួលនោះ ។ ក្នុងករណីភាគីវិវាទទាំងអស់មិនព្រមព្រៀងលើសមាសភាពអ្នកសម្រុះសម្រួលណាមួយដែលមកពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង នោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវចាត់តាំងក្រុមអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាដហុក និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក ៣រូប ដែលមានម្នាក់ជាប្រធានត្រូវសម្រុះសម្រួលវិវាទ ។ ក្រុមអ្នកសម្រុះសម្រួល យ៉ាងហោចណាស់ត្រូវរួមបញ្ចូលសមាជិកមួយរូបជាអ្នកបានទទួលការបណ្តុះបណ្តាល ឬ មានបទពិសោធន៍ក្នុងការសម្រុះសម្រួលវិវាទ និង សមាជិកមួយរូបជាអ្នកដឹងពីស្ថានភាព និង សភាពការណ៍នៅក្នុងមូលដ្ឋាន ។

**ប្រការ ៣៤ :-**

អ្នកសម្រុះសម្រួលត្រូវធ្វើការសម្រុះសម្រួលនៅលើទីតាំងដី ឬ នៅជិតដីវិវាទ លើកលែងតែមានហេតុផលបញ្ជាក់ថាមានការគំរាមកំហែងដល់សន្តិសុខរបស់មន្ត្រីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ ក្នុងករណីអសន្តិសុខដំណើរការសម្រុះសម្រួល វិវាទត្រូវធ្វើឡើងនៅទីកន្លែងដែលមានសន្តិសុខដែលនៅជិតដីវិវាទបំផុត ។

នីតិវិធីរដ្ឋបាលសំរាប់សម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ ២៤ នៃប្រកាសនេះ ។

**ប្រការ ៣៥ :-**

នីតិវិធីរដ្ឋបាលនៃដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយសំរាប់កិច្ចដំណោះស្រាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុង ប្រការ២៦ នៃប្រកាសនេះ ។

អ្នកសម្រុះសម្រួល ត្រូវបញ្ជូនកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ដើម្បីចុះបញ្ជីក្បាលដី ។

**ប្រការ ៣៦ :-**

នីតិវិធីរដ្ឋបាលសំរាប់បញ្ជាក់អំពីកិច្ចដំណោះស្រាយដែលសំរេចបាននៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ ២៧ នៃប្រកាសនេះ ។

**ប្រការ ៣៧ :-**

នីតិវិធីរដ្ឋបាលសំរាប់ការធ្វើរបាយការណ៍សម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ២៨ នៃ ប្រកាសនេះ ។

## ៧. ដំណើរការដោះស្រាយវិវាទរបស់ គណៈកម្មការសុរិយោដីថ្នាក់ជាតិ

**ប្រការ ៣៨ :-**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិសំរេចវិវាទទាំងឡាយដែលស្ថិតនៅក្រៅតំបន់វិនិច្ឆ័យ ហើយដែលមិនអាចដោះស្រាយបានដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់វិវាទដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យដែលមិនអាចដោះស្រាយបានដោយគណៈកម្មការរដ្ឋបាល ។/.

លើកលែងតែក្នុងករណីបន្ទាន់ដូចមានពណ៌នាក្នុងប្រការ៣៩នៃប្រកាសនេះ គណៈកម្មការសុរិយោដីថ្នាក់ជាតិមិនត្រូវពិនិត្យករណីទាំងឡាយក្នុងឋានៈជាក្រុមអ្នកសម្រុះសម្រួលជំហានដំបូងចំពោះករណីវិវាទណាមួយឡើយ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬគណៈកម្មការរដ្ឋបាល ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិនូវករណីវិវាទអមជាមួយកំណត់ហេតុផ្លូវការទាំងមូល និងរបាយការណ៍សម្រុះសម្រួលដែលសង្ខេបដំណើរការវិវាទដែលបានធ្វើនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ នៅគណៈកម្មការរដ្ឋបាលតាមករណីជាក់ស្តែង ។

**ប្រការ ៣៩ :-**

ក្នុងករណីវិវាទដែលតម្រូវឱ្យមានការសំរេច ឬ ដំណើរការដោះស្រាយជាបន្ទាន់ ដូចជាករណី មានការគំរាមកំហែង ឬការភ័យខ្លាចសមហេតុផលកើតឡើងពីការបង្កអគ្គីភ័យ ការប្រើកំលាំង ឬ ការបំភិតបំភ័យ ភាគីវិវាទអាចស្នើទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិអោយចាត់វិធានការបណ្តោះអាសន្នដើម្បីការពារផលប្រយោជន៍របស់ភាគីនៅពេលដែលវិវាទកំពុងធ្វើការដោះស្រាយ ។ ក្នុងស្ថានភាពនេះ ភាគីអាចប្តឹងដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ ជាតិឱ្យចេញសេចក្តីសំរេចបណ្តោះអាសន្ន ដើម្បីធ្វើអោយស្ថានការណ៍មានស្ថេរភាពរហូតដល់មានការស៊ើបអង្កេត និង សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ សេចក្តីសំរេចណ្តោះអាសន្នត្រូវមានខ្លឹមសារជាការរក្សាស្ថានភាពដដែល ។

**ប្រការ ៤០ :-**

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវកោះប្រជុំគណៈកម្មការសុរិយោដីថ្នាក់ជាតិ តាមតម្រូវការដើម្បីដោះស្រាយវិវាទ ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញតំណាងក្រសួង និង ស្ថាប័នពាក់ព័ន្ធអោយចូលរួមជាសមាជិកអាដហុកដើម្បីដោះស្រាយវិវាទ ។ ប្រធានគប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

**ប្រការ ៤១ :-**

បន្ទាប់ពីត្រួតពិនិត្យមើលកំណត់ហេតុផ្លូវការនៃវិវាទ ឬ នៅពេលផ្សេងទៀតក្នុងអំឡុងពេលធ្វើការពិនិត្យវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចសំរេចធ្វើការសម្រុះសម្រួលវិវាទបន្ថែមទៀត ។

នៅក្នុងស្ថានភាពនេះនីតិវិធីរដ្ឋបាលដើម្បីសម្រុះសម្រួលនៅថ្នាក់ជាតិត្រូវអនុវត្តដូចនីតិវិធីទាំងឡាយសំរាប់គណៈ-កម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដូចមានចែងលំអិតក្នុងប្រការ ២៤ នៃប្រកាសនេះ ។

ប្រសិនបើការសម្រុះសម្រួលមិនបានសំរេច ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវកំណត់កាលបរិច្ឆេទសំរាប់ការធ្វើសវនាការដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

ភាគីអាចស្នើសុំគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យបញ្ជូនក្រុមអ្នកវិនិច្ឆ័យចល័តទៅកាន់ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងករណីដែលគ្មានការព្រមព្រៀងគ្នារវាងភាគី ទីកន្លែងធ្វើសវនាការត្រូវស្ថិតនៅជិតដីវិវាទបំផុត ។ នៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ គូវិវាទត្រូវកំណត់ពេលវេលាដើម្បីចុះទៅពិនិត្យមើលទីតាំងដីវិវាទ ឬ ព្រមព្រៀងលើកលែងការស៊ើបអង្កេតបន្ថែមទៀតបាន ។

**ប្រការ ៤២ :-**

ប្រសិនបើ សមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទ ហើយប្រសិនបើចាំបាច់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ភាគីអាច ដាក់ពាក្យបណ្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិករួមទាំងប្រធានគណៈកម្ម-ការសុរិយោដីថ្នាក់ជាតិដោយផ្អែកលើវិវាទអំពីផលប្រយោជន៍របស់សមាជិកនោះ ។ សមាជិកដទៃទៀតនៃ គណៈកម្មការត្រូវសំរេចថា តើសមាជិកដែលត្រូវជំទាស់អំពីវិវាទអំពីផលប្រយោជន៍នោះត្រូវរារាំងមិនអោយចូលរួមក្នុងការដោះស្រាយវិវាទ ឬ ទេ ។

**ប្រការ ៤៣ :-**

រាល់កិច្ចប្រជុំ ឬសវនាការដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិចាត់វិធានការផ្លូវការទាក់ទងទៅនឹងវិវាទត្រូវបើកចំហជាសាធារណៈ ។

សេចក្ដីជូនដំណឹងជាមុនអំពីរាល់កិច្ចប្រជុំ ឬ សវនាការដែលជាការចាត់វិធានការផ្លូវការត្រូវជូនដល់សាធារណជន និង ប្រព័ន្ធសារពត៌មាន ។ លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវរក្សាទុកកំណត់ហេតុនៃដំណើរការរឿងវិវាទទាំងអស់របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយបុគ្គលណាក៏មានសិទ្ធិមើលកំណត់ហេតុទាំងនោះទោះបីបុគ្គលនោះមាន ឬគ្មានផលប្រយោជន៍នៅក្នុងវិវាទនោះក្ដី ។

**ប្រការ ៤៤ :-**

លើកលែង តែការប្រជុំសំរាប់ការសម្រុះសម្រួលដែលអាចធ្វើឡើងជាមួយភាគីវិវាទដោយឡែកពីគ្នា គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវអញ្ជើញភាគីដែលមានផលប្រយោជន៍ទាំងអស់ឱ្យចូលរួមរាល់កិច្ចប្រជុំ និងសវនាការទាក់ទងទៅនឹងវិវាទរបស់ពួកគេ ។ សេចក្ដីអញ្ជើញ ត្រូវបញ្ជូនទៅអោយភាគី យ៉ាងហោច ១៥ ថ្ងៃនៃថ្ងៃធ្វើការមុនពេលបើកកិច្ចប្រជុំ ឬ សវនាការ ។

**ប្រការ ៤៥ :-**

ភាគី អាចជ្រើសរើសបុគ្គលម្នាក់តាមជំរើសរបស់ខ្លួនផ្ទាល់ អោយតំណាងខ្លួននៅក្នុងរាល់ដំណើរការ នៃរឿងវិវាទរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បុគ្គលនេះហៅថាអ្នកការពារក្តី អាចផ្តល់ការណែនាំ ឬអាចតំណាងភាគីបាន។ អ្នកការពារក្តីអាចបញ្ជាក់ពីចម្លើយរបស់ភាគី និងអាចចូលរួមកិច្ចប្រជុំជាមួយគណៈកម្មការសុរិយោដីថ្នាក់ជាតិហើយតាមការយល់ព្រមរបស់ភាគីអាចនិយាយ និងអាចធ្វើសេចក្តីសំរេចក្នុងនាមភាគីបាន ។ ទោះបីជាយ៉ាងណាក្តីបើគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាក់លាក់របស់ភាគីទេនោះ អ្នកការពារក្តីមិនអាចដោះស្រាយវិវាទក្នុងនាមភាគីបានឡើយ ។

ប្រសិនបើ អ្នកការពារក្តីបំពានវិធាននៃដំណើរការរឿងវិវាទ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវផ្តល់ការក្រើនរំលឹក និងការព្រមានជាឯកជនម្តងដល់អ្នកការពារក្តី ។ ប្រសិនបើ អ្នកការពារក្តីនៅតែបន្តបំពានទៀតគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវហាមឃាត់អ្នកការពារក្តីនោះមិនឱ្យចូលរួមក្នុងដំណើរដោះស្រាយវិវាទទៀតឡើយ ។ ប្រសិនបើអ្នកការពារក្តីត្រូវបានហាមឃាត់មិនឱ្យចូលរួម ដំណើរការរឿងវិវាទនោះត្រូវផ្អាក រហូតដល់ភាគីជ្រើសរើសអ្នកការពារក្តីថ្មីបានឬយល់ព្រមឱ្យបន្តដំណើរការដោយមិនមានអ្នកការពារក្តី។ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីដើម្បីពិគ្រោះយោបល់ជាមួយអ្នកការពារក្តីដែលត្រូវបានហាមឃាត់អោយនៅក្រៅកន្លែងដោះស្រាយ ។

**ប្រការ ៤៦ :-**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចធ្វើសវនាការវិវាទជាក្រុមវិនិច្ឆ័យ ឬ អាចតែងតាំងសមាជិកតែម្នាក់ ឬមន្ត្រីសវនាការតែមួយរូបឱ្យធ្វើសវនាការបាន ។

រាល់សវនាការ សក្ខីកម្មផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរអាចទទួលយកបាន ។

គណៈកម្មការសុរិយោដីថ្នាក់ ជាតិ មិនត្រូវបានតម្រូវអោយគោរពតាមវិធានភស្តុតាង ឬនីតិវិធីផ្លូវការទេ ប៉ុន្តែត្រូវធានាឱ្យភាគីទាំងអស់មានឱកាសបង្ហាញសក្ខីកម្ម និង ភស្តុតាងរបស់ខ្លួនដោយយុត្តិធម៌ និង សមធម៌ ។

ភាគីនីមួយៗមានសិទ្ធិបង្ហាញសាក្សី និងបដិសេធភស្តុតាង ឬសាក្សីដែលផ្តល់ដោយភាគីផ្សេងទៀត ។ បុគ្គលដែលផ្តល់សក្ខីកម្មអាចត្រូវបានតម្រូវអោយឆ្លើយនឹងសំនួរបញ្ជាក់អំពីសក្ខីកម្មនោះ ។

**ប្រការ ៤៧ :-**

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវស្តាប់ភស្តុតាងវិវាទ និង ត្រួតពិនិត្យឯកសារផ្លូវការនៃវិវាទដែលបានប្រមូលនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ ដោយគណៈកម្មការរដ្ឋបាល ហើយត្រូវចេញសេចក្តីសំរេចដែលមានប្រសិទ្ធភាពអនុវត្តដោយផ្អែកលើរបាយការណ៍នេះ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចេញសេចក្ដីសំរេចនៅពេលធ្វើការសរុបសន្និដ្ឋានការពិភាក្សារបស់ខ្លួនហើយត្រូវធ្វើកំណត់សំគាល់សេចក្ដីសន្និដ្ឋានខាងផ្លូវច្បាប់ និង មូលដ្ឋានអង្គហេតុនៃសេចក្ដីសំរេចរបស់ខ្លួន ។ សេចក្ដីសំរេចស្ថាពរត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និង ចុះហត្ថលេខាដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

សេចក្ដីសំរេចជាលាយលក្ខណ៍អក្សររបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើអោយភាគីទាំងឡាយតាមរយៈសំបុត្រប្រៃសណីយ៍ និងត្រូវបើកចំហសំរាប់ការពិនិត្យមើលជាសាធារណៈដល់បុគ្គលណាក៏ដោយទោះបីមាន ឬគ្មានផលប្រយោជន៍នៅក្នុងរឿងវិវាទនោះក្ដី ។

សេចក្ដីសំរេចជាលាយលក្ខណ៍អក្សរ ត្រូវអមជាមួយសេចក្ដីជូនដំណឹងដែលជំរាបភាគីវិវាទអំពីសិទ្ធិរបស់ពួកគេក្នុងការប្ដឹងតវ៉ាទៅតុលាការឱ្យពិនិត្យមើលឡើងវិញផ្នែកច្បាប់ ចំពោះសេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយត្រូវផ្ដល់ពត៌មានអំពីរបៀបប្ដឹងទៅតុលាការផង ។

**ប្រការ ៤៨ :-**

សេចក្ដីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិក្លាយជាសេចក្ដីសំរេចស្ថាពរនៅក្រោយ រយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្ដីសំរេចនោះត្រូវបានបញ្ជូនទៅដល់ភាគីវិវាទទាំងអស់ លើកលែងតែករណីមានការប្ដឹងទៅតុលាការ ឬមានការស្នើសុំ ឱ្យធ្វើការពិនិត្យឡើងវិញដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ អនុលោមតាមប្រការ ៤៥ នៃប្រកាសនេះ ។

ប្រសិនបើគ្មានការប្ដឹងតវ៉ាទៅតុលាការ ឬ គ្មានការស្នើសុំអោយធ្វើសវនាការឡើងវិញត្រូវបានធ្វើឡើងតាមពេលវេលាត្រឹមត្រូវទេលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវបញ្ជូនសេចក្ដីសំរេចនោះទៅការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ។ បន្ទាប់មក ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ត្រូវចាប់ផ្ដើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលត្រូវបានសំរេចនោះ ។

**ប្រការ ៤៩ :-**

ការធ្វើសវនាការឡើងវិញពុំអាចធ្វើបានទេ លើកលែងតែមានសម្លេងយល់ព្រមពីសមាជិក ៣ រូប នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ នៅពេលដែលមានភស្ដុតាងថ្មីធំដុំត្រូវបានដាក់ជូនគណៈកម្មការ ។

សំណើសុំធ្វើសវនាការឡើងវិញ ត្រូវដាក់ជូនជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្ដីសំរេចជាលាយលក្ខណ៍អក្សរត្រូវបានបញ្ជូនទៅដល់ភាគី ហើយត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនោះដោយត្រូវអមដោយពត៌មាននិងឯកសារតាងចាំបាច់នានា ។

ការធ្វើសវនាការឡើងវិញ ត្រូវអនុលោមតាមសេចក្ដីជូនដំណឹង និង លក្ខខណ្ឌតម្រូវផ្នែកនីតិវិធីដូចសវនាការដើមដែរ ។

ប្រសិនបើមានការបដិសេធចំពោះសំណើសុំអោយមានសវនាការឡើងវិញ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធនោះដល់ភាគីវិវាទ ។ នៅក្នុងករណីនេះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្លាយជាស្ថាពរក្រោយបញ្ចប់រយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងពីការបដិសេធត្រូវបានបញ្ជូនទៅដល់ភាគីវិវាទលើកលែងតែភាគីម្ខាងនៃគូវិវាទជូនដំណឹងអំពីការប្តឹងជំទាស់ទៅតុលាការតាមពេលវេលាត្រឹមត្រូវ ។

**ប្រការ ៥០ :-**

ភាគីណាក៏ដោយអាចប្តឹងទៅតុលាការដោយរួមគ្នា ឬជាបុគ្គលអំពីសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បណ្តឹងជំទាស់ត្រូវដាក់ជូនទៅតុលាការក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានបញ្ជូនដល់ភាគីវិវាទ ។

ភាគីណាមួយដែលធ្វើបណ្តឹងទៅតុលាការ ត្រូវដាក់តម្កល់ឯកសារថតចម្លងមួយច្បាប់នៃបណ្តឹងជំទាស់នៅលេខាធិការដ្ឋាន នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

លេខាធិការដ្ឋាន ត្រូវធ្វើសេចក្តីបញ្ជាក់ជាបន្ទាន់នូវរបាយការណ៍ផ្លូវការដើម្បីបញ្ជូនទៅតុលាការ ។

## ៨. បទប្បញ្ញត្តិរដ្ឋបាល

**ប្រការ ៥១ :-**

ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ស្តីពីបណ្តឹងដែលបានទទួល និង ចំណាត់ការដែលបានធ្វើដោយគណៈកម្មការចំពោះបណ្តឹងនីមួយៗ ដែលគណៈកម្មការបានធ្វើ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ គណៈកម្មការសុរិយោដីថ្នាក់ខេត្តក្រុង ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ រាជរដ្ឋាភិបាល ។

របាយការណ៍របស់គណៈកម្មការសុរិយោដី ត្រូវបើកចំហ និង អនុញ្ញាតឱ្យសាធារណជនមើលដោយសេរីក្នុងពេលម៉ោងធ្វើការធម្មតា ។

**ប្រការ ៥២ :-**

គណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវរក្សាទុកកំណត់ហេតុផ្លូវការនៃវិវាទនីមួយៗដែលបានប្តឹងនៅគណៈកម្មការនោះ ។

កំណត់ហេតុផ្លូវការ ត្រូវរួមបញ្ចូលរាល់ឯកសារទាំងអស់ សេចក្ដីអះអាងគស្លុតាងផ្សេងៗ និងរបាយការណ៍ផ្សេងៗ ទាក់ទងទៅនឹងវិវាទ ។

ឯកសារផ្លូវការត្រូវបើកចំហជាសាធារណៈ និង អនុញ្ញាតឱ្យសាធារណជនចូលមើលដោយសេរីក្នុងពេលម៉ោងធ្វើការធម្មតា។

បុគ្គលទាំងឡាយដែលចង់ពិនិត្យមើលឯកសារ ត្រូវទៅមើលនៅការិយាល័យគណៈកម្មការសុរិយោដីនោះ និងត្រូវចុះហត្ថលេខាលើសៀវភៅភ្ញៀវ ។

នៅកន្លែងដែលមានសម្ភារៈបរិក្ខារថតចម្លង បុគ្គលទាំងឡាយអាចថតចម្លងឯកសារបាន ។

**ប្រការ ៥៣ :.**

នាយកខុទ្ទកាល័យ ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និង ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០០២

**រដ្ឋមន្ត្រី**

អ៊ឹម ឈុនលឹម

<u>កន្លែងទទួល</u> :

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៥៣
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ២

ឆ្នាំទី ២ លេខ ២០ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ រាជកិច្ច ទំព័រ ១៣៧៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០២

## ស ំ រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ កំណត់នីតិវិធីនៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំនូវអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងតំបន់ដែលមិនទាន់បានចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ។

## ជំពូកទី ២

## ភារកិច្ច និង ភារកិច្ច

**មាត្រា ២ .-**

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចណែនាំ សម្របសម្រួល និងពិនិត្យតាមដានការអនុវត្តអនុក្រឹត្យនេះ ។ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវកំណត់ស្តង់ដារបច្ចេកទេសសំរាប់ការកំណត់ព្រំដី ការកសាងប្លង់សុរិយោដី និងការកសាងឯកសារផ្សេងៗ ព្រមទាំងកំណត់គំរូឯកសារ ដែលត្រូវប្រើក្នុងនីតិវិធី ដូចមានចែងក្នុងអនុក្រឹត្យនេះ។

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវទទួលខុសត្រូវក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ រាល់ក្បាលដី ដែលស្នើសុំចុះបញ្ជីក្រោមអនុក្រឹត្យនេះក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ប្រសិនបើរដ្ឋបាលសុរិយោដីស្រុក ខណ្ឌណាមួយ មិនអាចបំពេញតាមល័ក្ខខណ្ឌសំរាប់ការចុះបញ្ជីក្រោមអនុក្រឹត្យនេះ ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន ដោយសារតែសមត្ថភាពបច្ចេកទេស រដ្ឋបាលសុរិយោដីស្រុក ខណ្ឌនោះ អាចស្នើសុំអោយរដ្ឋបាលសុរិយោដីខេត្ត ក្រុង ជួយដល់ការអនុវត្តនូវការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ។

មាត្រា ៣ .-

មន្ត្រីទទួលបន្ទុកការងារកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ មានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុ នៅពេលធ្វើការអង្កេតវាស់វែង និងអាចអញ្ជើញជនពាក់ព័ន្ធឱ្យផ្តល់ពតិមានផ្ទាល់មាត់ ឯកសារ ឬ/និងភស្តុតាងផ្សេងៗទាក់ទងនឹងព្រំដី ឬសិទ្ធិលើក្បាលដី ។

មាត្រា ៤ .-

ក្នុងករណីចាំបាច់ រដ្ឋបាលសុរិយោដីអាចស្នើសុំទៅអាជ្ញាធរដែនដី ឬកងកំលាំងប្រដាប់អាវុធ ឱ្យជួយជ្រោមជ្រែងក្នុងការអនុវត្តការងារវាស់វែង ។

មាត្រា ៥ .-

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី មានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ដោយផ្តល់ពតិមានផ្ទាល់មាត់ ឯកសារ ឬ/និងភស្តុតាង ដែលទាក់ទងនឹងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ តាមសំណូមពររបស់មន្ត្រីទទួលបន្ទុក ។

ក្នុងពេលចុះកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ក្នុងករណីអវត្តមានអ្នកដាក់ពាក្យ ឬតំណាងស្របច្បាប់ ការកំណត់ព្រំក្បាលដីត្រូវធ្វើដោយផ្អែកតាមឯកសារដែលមាន ឬ/និងភស្តុតាងដែលមានលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ ដែលទាក់ទងនឹងព្រំដី ។

ជនណាដែលបានបំភាន់មន្ត្រីសុរិយោដីក្នុងការបំពេញបេសកកម្ម ឬបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដី ត្រូវទទួលការផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២៥២ នៃច្បាប់ភូមិបាល ។

មាត្រា ៦ .-

ជនដែលមានការពាក់ព័ន្ធ មានកាតព្វកិច្ចចូលរួមសហការក្នុងការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ដោយផ្តល់ពតិមានផ្ទាល់មាត់ ឯកសារ ឬ/និងភស្តុតាងផ្សេងៗ តាមសំណូមពររបស់មន្ត្រីទទួលបន្ទុក ។

ជនគ្រប់រូបមានសិទ្ធិចូលរួមពិនិត្យនិងផ្តល់យោបល់ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ។

## ជំពូកទី ៣

## អំពីនីតិវិធីនៃការចុះបញ្ជីដី

**មាត្រា ៧ .-**

សាមីអ្នកកាន់កាប់ដីដែលស្នើសុំចុះបញ្ជីដី ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីតាមគំរូដែលបានកំណត់ មករដ្ឋបាលសុរិយោដីស្រុក ខណ្ឌ តាមរយៈមេឃុំ ចៅសង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ ។

ពាក្យស្នើសុំត្រូវមាន :

- ឈ្មោះ និងស្នាមមេដៃរបស់អ្នកដាក់ពាក្យ
- ការពិពណ៌នាលំអិតអំពីក្បាលដីដែលស្នើសុំចុះបញ្ជី និងទីតាំងរបស់ក្បាលដីនោះ
- ការពិពណ៌នាអំពីសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី
- ឯកសារ ឬ/និងភស្តុតាងផ្សេងៗ ទាក់ទងនឹងក្បាលដី ឬសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី ។

**មាត្រា ៨ .-**

ពាក្យស្នើសុំត្រូវបានពិនិត្យដោយរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ផ្អែកតាមឯកសារដែលមាន និងទិន្នន័យផ្សេងៗដែលពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជី ។

ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវកត់ត្រាចូលក្នុងសៀវភៅទទួលពាក្យ និងកំណត់កាលបរិច្ឆេទនៃការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ។

ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈមិនសមស្រប រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវចារលើពាក្យ ដោយបញ្ជាក់ពីមូលហេតុដែលមិនអាចអនុវត្តនីតិវិធីនៃការចុះបញ្ជីបាន ។ អ្នកដាក់ពាក្យមានសិទ្ធិប្តឹងតវ៉ាទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។

ក្នុងករណីពិនិត្យឃើញថា មានវិវាទពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជីនោះ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវបញ្ជូនវិវាទនោះទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ស្រុក ខណ្ឌ តាមនីតិវិធី ដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

**មាត្រា ៩ .-**

អភិបាលស្រុក ខណ្ឌ ត្រូវចេញសេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី ទៅអ្នកដាក់ពាក្យស្នើសុំ និងត្រូវបិទផ្សាយជាសាធារណៈ ក្នុងរយៈពេល ១៤(ដប់បួន) ថ្ងៃយ៉ាងតិចមុនកាលបរិច្ឆេទ នៃការកំណត់ព្រំដី នៅសាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ និងនៅទីកន្លែងដែលងាយមើលឃើញក្នុងភូមិដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ ។

**មាត្រា ១០ .-**

មន្ត្រីទទួលបន្ទុកកំណត់ព្រំដី និងវាស់វែង ត្រូវកំណត់ព្រំក្បាលដីដែលស្នើសុំចុះបញ្ជី តាមពេលវេលាដែលបានជូនដំណឹងដោយយោងតាមសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការណែនាំរបស់រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ។

នៅពេលធ្វើការកំណត់ព្រំក្បាលដី មន្ត្រីទទួលបន្ទុកត្រូវពិនិត្យឯកសារដែលមាន ភស្តុតាង និងពតិមានជាលាយលក្ខណ៍អក្សរ និងពតិមានផ្ទាល់មាត់ផ្សេងៗ ដែលទាក់ទងនឹងព្រំប្រទល់ក្បាលដី ដែលស្នើសុំចុះបញ្ជី ហើយត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម :

ក-ក្នុងករណីអ្នកដាក់ពាក្យ និងម្ចាស់ដីជាប់ព្រំ មានវត្តមាន ហើយព្រមព្រៀងគ្នាអំពីព្រំប្រទល់ និងគ្មានភស្តុតាងផ្ទុយ ការកំណត់ព្រំដីត្រូវធ្វើដោយផ្អែកតាមការព្រមព្រៀង ។

ខ-ក្នុងករណីម្ចាស់ដីជាប់ព្រំ មិនមានវត្តមាន ការកំណត់ព្រំដីត្រូវធ្វើដោយផ្អែកតាមឯកសារដែលមាន និងភស្តុតាងដែលជាលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ និងភស្តុតាងផ្ទាល់មាត់ ដែលទាក់ទងនឹងព្រំដីនោះ ។

គ-ក្នុងករណីក្បាលដីដែលស្នើសុំចុះបញ្ជីស្ថិតនៅជាប់នឹងដីសាធារណៈ ឬជាប់នឹងក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ការកំណត់ព្រំដីត្រូវធ្វើដោយយោងតាមចំណុច( ក) ឬ( ខ)ខាងលើ ។

វិវាទអំពីព្រំដីដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ស្រុក ខណ្ឌ តាមនីតិវិធី ដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការ សុរិយោដី ។

ការវាស់វែង ត្រូវធ្វើក្រោយពីបានកំណត់ព្រំក្បាលដីរួច ។

**មាត្រា ១១ .-**

មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវអង្កេតលើឯកសារដែលមាន ភស្តុតាង និងពតិមានជាលាយល័ក្ខណ៍អក្សរ និងពតិមានផ្ទាល់មាត់ទាក់ទងនឹងសិទ្ធិលើក្បាលដី ដែលស្នើសុំចុះបញ្ជី ។

ចំពោះដីភោគៈ ការវិនិច្ឆ័យត្រូវផ្អែកលើគោលការណ៍ដូចខាងក្រោម :

ក-ដីដែលស្នើសុំចុះបញ្ជី ត្រូវតែបានកាន់កាប់មុនថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១

ខ-ដីដែលស្នើសុំចុះបញ្ជី ត្រូវបានកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ :

-ក្នុងករណីកាន់កាប់យ៉ាងតិចប្រាំឆ្នាំ ហើយចំណុចព្រំក្បាលដី មាននិយាមការច្បាស់លាស់ អាចត្រូវបានស្នើផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីនោះ

- ក្នុងករណីកាន់កាប់យ៉ាងតិចប្រាំឆ្នាំ ប៉ុន្តែចំណុចព្រំក្បាលដី មិនទាន់មាននិយាមការច្បាស់លាស់ អាចត្រូវបានស្នើផ្តល់សិទ្ធិជាភោគៈបន្តលើក្បាលដីនោះ

- ក្នុងករណីកាន់កាប់តិចជាងប្រាំឆ្នាំ អាចត្រូវបានស្នើផ្តល់សិទ្ធិជាភោគៈបន្តលើក្បាលដីនោះ ។

អចលនវត្ថុរបស់រដ្ឋ ត្រូវបានចុះបញ្ជីជាទ្រព្យសម្បត្តិសាធារណៈ ឬជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ស្របតាមបទប្បញ្ញត្តិនៃជំពូកទី ២ នៃច្បាប់ភូមិបាល ។

## មាត្រា ១២ .-

ផ្អែកតាមការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌត្រូវរៀបចំឯកសារ នៃការវិនិច្ឆ័យ រួមមាន :

-ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី

-ផែនទីក្បាលដី និងតំនូសបង្ហាញទីតាំងដី

-បញ្ជីឈ្មោះម្ចាស់ក្បាលដីដែលស្នើសុំចុះបញ្ជី ។

ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ត្រូវបង្ហាញអំពីអត្តសញ្ញាណនៃក្បាលដី កម្មសិទ្ធិករ ឬភោគីកាលបរិច្ឆេទនៃការកាន់កាប់ដី កាលបរិច្ឆេទនៃការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ រាល់សិទ្ធិ និងបន្ទុកដែលមានលើក្បាលដីដូចមានចែងក្នុងច្បាប់ភូមិបាល ។

ផែនទីក្បាលដីដែលស្នើសុំចុះបញ្ជី ត្រូវបង្ហាញអំពីអត្តសញ្ញាណនៃក្បាលដី រួមមាន លេខក្បាលដី រូបរាងក្បាលដី លេខក្បាលដី ឬ/និងឈ្មោះម្ចាស់ក្បាលដីជាប់ព្រំ ។

បញ្ជីឈ្មោះម្ចាស់ដីនៃក្បាលដីដែលស្នើសុំចុះបញ្ជី បង្ហាញអំពីឈ្មោះ សាវតា ប្រភេទទ្រព្យរបស់កម្មសិទ្ធិករ ឬៈភាគីនៃក្បាលដី ប្រភព និងកាលបរិច្ឆេទនៃការកាន់កាប់ ទំហំ និងរូបភាពប្រើប្រាស់ដី។

## មាត្រា ១៣ .-

បន្ទាប់ពីការពិនិត្យភាពច្បាស់លាស់ខាងបច្ចេកទេស រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាលើទម្រង់បែបបទ នៃការប្រមូលទិន្នន័យក្បាលដី ។

ឯកសារនៃការវិនិច្ឆ័យដែលត្រូវផ្សព្វផ្សាយរួមមាន ផែនទីក្បាលដី តំនូសបង្ហាញទីតាំងដី និងបញ្ជីឈ្មោះម្ចាស់ដី ។ ការផ្សព្វផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ត្រូវធ្វើឡើងក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ នៅសាលាស្រុក ខណ្ឌដែលមានសមត្ថកិច្ច ។ សេចក្តីថតចម្លងនៃឯកសារទាំងនេះក៏ត្រូវបិទផ្សាយផងដែរ នៅទីស្នាក់ការឃុំ សង្កាត់ ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ ។

អភិបាលស្រុក ខណ្ឌ ត្រូវជូនដំណឹងអំពីការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យនេះដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី ។ សេចក្តីជូនដំណឹងត្រូវធ្វើឡើងយ៉ាងតិច ៧(ប្រាំពីរ)ថ្ងៃ មុនថ្ងៃបើកការផ្សព្វផ្សាយជាសាធារណៈ ហើយត្រូវបិទផ្សាយនៅកន្លែងដែលងាយមើលឃើញ នៅក្នុងភូមិ នៅសាលាឃុំ សង្កាត់ ទទិងនៅសាលាស្រុក ខណ្ឌ ។

**មាត្រា ១៤ .-**

ក្នុងរយៈពេលនៃការផ្សព្វផ្សាយ ជនដែលមានផលប្រយោជន៍ទាក់ទងនឹងក្បាលដីស្នើសុំចុះបញ្ជី អាចជូនដំណឹងអំពីការជំទាស់របស់ខ្លួនទៅរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្នុងករណីពិនិត្យ ឃើញថាឯកសារនៃការវិនិច្ឆ័យ ដែលបានបិទផ្សាយជាសាធារណៈ មានលក្ខណៈមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ ។ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវស៊ើបអង្កេតលើការជំទាស់នោះ ដោយផ្អែកតាមឯកសារ និងពត៌មានទាំងអស់ ដែលប្រមូលបានក្នុងពេលអនុវត្តនីតិវិធី ។

ក្នុងករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់មានលក្ខណៈសមហេតុផល រដ្ឋបាលសុរិយោដីស្រុក ខណ្ឌអាចធ្វើការកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងដែលមិនប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់នៃជនណាមួយ ។

ការកែតម្រូវផ្សេងទៀតក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបានដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ ។

ក្នុងករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់មានលក្ខណៈមិនសមហេតុផល ការជំទាស់ត្រូវបានដាក់ឱ្យធ្វើការសម្រុះសម្រួល និងដោះស្រាយតាមនីតិវិធី ដែលមានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មការសុរិយោដី ។

**មាត្រា ១៥ .-**

ក្រោយពីផុតកំណត់រយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងបញ្ចប់ការដោះស្រាយទំនាស់តាមនីតិវិធីដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវបញ្ចូលក្បាលដីទៅក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ ។

ផែនទីមានលក្ខណៈដាច់ដោយដុំគឺជាប្លង់សុរិយោដីដែលបង្ហាញអំពីទីតាំង លេខ និងព្រំប្រទល់នៃក្បាលដីទាំងឡាយដែលបានចុះបញ្ជីរួច និងក្បាលដីដែលស្នើសុំចុះបញ្ជី បន្ទាប់ពីបានបិទផ្សាយជាសាធារណៈ និងបានបញ្ចប់ការសម្រុះសម្រួល និងការដោះស្រាយទំនាស់ ។

**មាត្រា ១៦ .-**

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌត្រូវផ្ញើសំណុំឯកសារទៅរដ្ឋបាលសុរិយោដីខេត្ត ក្រុង ដូចមានខាងក្រោម :

- ពាក្យស្នើសុំចុះបញ្ជីដី
- ឯកសារនៃការវិនិច្ឆ័យ
- សេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី
- ការដកស្រង់ផែនទីមានលក្ខណៈដាច់ដោយដុំ
- សេចក្តីជូនដំណឹងពីការបិទផ្សាយជាសាធារណៈ

- របាយការណ៍ស្ដីពីលទ្ធផលនៃការវិនិច្ឆ័យ
- ពាក្យបណ្ដឹងជំទាស់តវ៉ាដែលពុំអាចដោះស្រាយបាន ប្រសិនបើមាន
- លិខិតស្នើសុំកែតម្រូវ ប្រសិនបើមាន
- កំណត់ហេតុសម្រុះសម្រួលវិវាទដែលបានដោះស្រាយរួច ប្រសិនបើមាន ។

ក្នុងករណីដែលពិនិត្យឃើញថាឯកសារទាំងនោះគ្រប់គ្រាន់ និងត្រឹមត្រូវហើយ រដ្ឋបាលសុរិយោដីខេត្ត ក្រុង ត្រូវចុះហត្ថលេខា រួចបញ្ជូនទៅរដ្ឋបាលសុរិយោដីថ្នាក់កណ្ដាល ។

**មាត្រា ១៧ .-**

ក្បាលដីត្រូវបានចុះបញ្ជី នៅពេលដែលអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ឬរដ្ឋបាលសុរិយោដីខេត្ត ក្រុង ដែលបានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានកត់ត្រារួចហើយក្នុងសៀវភៅគោលបញ្ជីដី ។

**មាត្រា ១៨ .-**

បន្ទាប់ពីក្បាលដីត្រូវបានចុះបញ្ជីរួច រដ្ឋបាលសុរិយោដីត្រូវចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុឱ្យកម្មសិទ្ធិករនៃក្បាលដីដែលបានចុះបញ្ជី ឬបណ្ណ័សំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឱ្យភោគីដែលបានចុះបញ្ជី ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់សិទ្ធិអោយខេត្ត ក្រុងណា ដែលមានគ្រប់លក្ខណ:សម្បត្តិ ដើម្បីចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ។

**មាត្រា ១៩ .-**

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវបញ្ជូនតារាងសម្រង់អចលនវត្ថុទៅរដ្ឋបាលសុរិយោដីខេត្ត ក្រុងដែលមិនទាន់បានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចុះក្នុងសៀវភៅគោលបញ្ជីដីឱ្យបានស្របគ្នា ហើយបញ្ជូនតារាងនេះបន្តទៅរដ្ឋបាលសុរិយោដីស្រុក ខណ្ឌដើម្បីចុះក្នុងសៀវភៅគោលបញ្ជីដីឱ្យបានស្របគ្នាដែរ ។

រដ្ឋបាលសុរិយោដីខេត្ត ក្រុង ដែលបានទទួលប្រតិភូកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្ញើតារាងសម្រង់អចលនវត្ថុទៅរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ និងផ្ញើមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដើម្បីចុះក្នុងសៀវភៅគោលបញ្ជីដីឱ្យបានស្របគ្នា ។

ការណែនាំអំពីរបៀបរបបនៃការកាន់កាប់ឯកសារសុរិយោដី និងឯកសារពាក់ព័ន្ធផ្សេងៗ ត្រូវកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ២០ .-**

សោហ៊ុយសេវាផ្សេងៗដែលទាក់ទងទៅនឹងការបំពេញភារកិច្ចក្នុងការអនុវត្តអនុក្រឹត្យនេះត្រូវកំណត់ដោយប្រកាសរួម អនុលោមតាមមាត្រា ២៣០ នៃច្បាប់ភូមិបាល ។/

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ២១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអភិបាលខេត្ត ក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា ២២
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ៣

ឆ្នាំ ទី ៦ លេខ ៥៣ សប្តាហ៍ ទី ៣ ថ្ងៃ ទី ១៥ ខែ កក្កដា ឆ្នាំ ២០០៦ រាជកិច្ច ទំព័រ ៥០៤៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/ ០២០៦/ ០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- យោងតាមសំណើប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

**សម្រេច**

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់អំពីបេសកកម្ម សិទ្ធិអំណាច មុខងារ ភារកិច្ច និង រចនាសម្ព័ន្ធ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

## ជំពូកទី ២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានតួនាទីជាអង្គភាពប្រតិបត្តិ និង ជាសេនាធិការផ្ទាល់នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដែលត្រូវដឹកនាំ និង គ្រប់គ្រងដោយអគ្គលេខាធិការមួយរូប និង អមដោយអគ្គលេខាធិការរង ព្រមទាំងសមាជិកមួយចំនួនជាជំនួយការ ។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានបេសកកម្មជួយអាជ្ញាធរក្នុងការដោះស្រាយ និង សម្របសម្រួលចំពោះវិវាទដីធ្លី និង មានភារកិច្ចដូចកំណត់ក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៥៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ ទន្ទឹមនឹងនេះ យោងតាមការសម្រេចរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសិទ្ធិចេញលិខិតណែនាំឱ្យផ្អាកជាបណ្តោះអាសន្នទីតាំងទំនាស់ មិនឱ្យធ្វើសកម្មភាពផ្សេងៗ ក្រោយពីទទួលពាក្យបណ្តឹង ឬពាក្យសុំអន្តរាគមន៍ពីគូវិវាទ ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ត្រូវធ្វើការប្រជុំការងារយ៉ាងតិចមួយខែម្តង តាមការអញ្ជើញ និង ការណែនាំរបស់អគ្គលេខាធិការ ហើយក្នុងករណីចាំបាច់អាចធ្វើការកោះប្រជុំភ្លាម ។

**មាត្រា ៥.-**

អគ្គលេខាធិការ ត្រូវលើកសំណើជូនប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដើម្បីពិនិត្យ និង សម្រេចតែងតាំង តម្លើងឋានៈ ផ្ទេរភារកិច្ច ឬដកចេញពីតំណែង នូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

**មាត្រា ៦.-**

អគ្គលេខាធិការ មានជំនួយការពីររូប ដែលមានឋានៈស្មើប្រធាននាយកដ្ឋាន ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពេលបំពេញភារកិច្ច និង បេសកកម្មរបស់ខ្លួន ។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានរចនាសម្ព័ន្ធដូចតទៅ :

១- នាយកដ្ឋានទប់ស្កាត់ បង្ការ និង អប់រំ

២- នាយកដ្ឋានស៊ើបអង្កេត និង អធិការកិច្ច

៣- នាយកដ្ឋានទទួល និង ដោះស្រាយបណ្តឹង

៤- នាយកដ្ឋានបូកសរុប ព័ត៌មានវិទ្យា និង ទំនាក់ទំនងសាធារណៈ

៥- នាយកដ្ឋានរដ្ឋបាល និង បុគ្គលិក

**មាត្រា ៩.-**

នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំ និង គ្រប់គ្រងដោយប្រធានមួយរូប និង មានអនុប្រធានមួយចំនួនជាជំនួយការ ។ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អាចស្នើសុំបង្កើតនាយកដ្ឋានផ្សេងទៀតតាមតម្រូវការចាំបាច់ ។

**មាត្រា ១០.-**

**នាយកដ្ឋានទប់ស្កាត់ បង្ការ និង អប់រំ មានតួនាទី និង ភារកិច្ចដូចតទៅ:**

១- លើកផែនការបណ្តុះបណ្តាល និង ផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និង ប្រជាពលរដ្ឋទូទៅឱ្យយល់ដឹងអំពីបញ្ហា និង ផលវិបាកដែលកើតមានឡើងពីវិវាទដីធ្លី ។

២- រៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ភូមិភាគ ជាតិ និង អន្តរជាតិ និង បង្កើតកម្មវិធីផ្សេងៗ ដើម្បីផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាល និង គោលការណ៍របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ស្តីពីការអប់រំ ការបង្ការ ការទប់ស្កាត់ទំនាស់ដីធ្លី សំដៅឱ្យសាធារណជនយល់ដឹងពីផលវិបាកនៃទំនាស់ដីធ្លី និង ឈានទៅកាត់បន្ថយបានជាអតិបរមានូវបញ្ហាទំនាស់ដីធ្លី ។

៣- ជំរុញ និង លើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋានសាធារណៈទាំងអស់ រួមមានសង្គមស៊ីវិល និង អង្គការក្រៅរដ្ឋាភិបាលនានា ឱ្យចូលរួមផ្តល់ព័ត៌មាន និង អនុសាសន៍នានា សំដៅបង្ការ ទប់ស្កាត់នូវរាល់បញ្ហាទំនាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ។

៤- សហការជាមួយស្ថាប័នជាតិ និង អន្តរជាតិ ដើម្បីស្វែងរកការឧបត្ថម្ភពីដៃគូនានា ក្នុងគោលដៅបង្កើនល្បឿននៃការដោះស្រាយទំនាស់ដីធ្លី ជាពិសេសការអប់រំ បង្ការ ទប់ស្កាត់នូវរាល់បញ្ហាទំនាស់ដីធ្លីតាមគ្រប់រូបភាព ។

៥- ស្នើសុំ និង ទទួលយកគោលការណ៍ពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ក្នុងការចាត់វិធានការ និង អនុវត្តភារកិច្ចនីមួយៗ ដើម្បីបង្ការ ទប់ស្កាត់ និង អប់រំ អំពីបញ្ហាទំនាស់ដីធ្លីគ្រប់រូបភាព ។

៦- រៀបចំផលិតឯកសារអប់រំ និង ល្ខោនវីដេអូផ្សេងៗ ក្នុងគោលដៅអប់រំសាធារណជន តាមរយៈការចុះអប់រំផ្ទាល់ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អំពីផលវិបាក នៃបញ្ហាដែលកើតមានឡើងពីវិវាទដីធ្លី ។

៧- សម្របសម្រួល និង សហការជាមួយស្ថាប័ននានាដទៃទៀតដើម្បីប្រមូល និង ផ្លាស់ប្តូរព័ត៌មានគ្នាសំដៅបង្ការ និង ទប់ស្កាត់ឱ្យបាននូវបញ្ហាទំនាស់ដីធ្លី និង សំដៅជំរុញការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព និង តម្លាភាពខ្ពស់ ។

៨- រៀបចំជាកម្មវិធីទស្សនកិច្ចសិក្សា ដើម្បីដកស្រង់បទពិសោធន៍ទាំងក្នុង និង ក្រៅប្រទេស ដែលពាក់ព័ន្ធទៅនឹងការរៀបចំ និង ការជំរុញអនុវត្តការងារដោះស្រាយទំនាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ។

**មាត្រា ១១.-**

**នាយកដ្ឋានស៊ើបអង្កេត និង អធិការកិច្ច មានតួនាទី និងភារកិច្ចដូចតទៅ:**

**ក- អំពីការងារស៊ើបអង្កេត**

១-តាក់តែង និង រៀបចំនីតិវិធី និង បែបបទរាយការណ៍ស្តីពីការផ្តល់ព័ត៌មាននូវរាល់ទំនាស់ដីធ្លី និង បង្កើតឡើងនូវយន្តការស៊ើបអង្កេតមួយប្រកបដោយលក្ខណៈរលូន មានតម្លាភាព និង ប្រសិទ្ធភាព។

២-ទទួលអនុវត្តបទបញ្ជាទាំងឡាយរបស់អគ្គលេខាធិការ នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ពាក់ព័ន្ធទៅនឹងដំណើរការស្រាវជ្រាវ និង ស៊ើបអង្កេតករណីទំនាស់ដីធ្លីនីមួយៗ។

៣-ស្នើសុំគោលការណ៍ចុះស្រាវជ្រាវ និង ស៊ើបអង្កេតដល់ទីកន្លែងកើតហេតុ ដើម្បីចងក្រងឯកសារស៊ើបអង្កេត និង ប្រមូលភស្តុតាងពាក់ពន្ធ័ទៅនឹងទំនាស់ដីធ្លី ដោយសហការជាមួយស្ថាប័នជំនាញពាក់ពន្ធ័ ព្រមទាំងអាជ្ញាធរដែនដី និង ធ្វើរបាយការណ៍ រួមទាំងធ្វើការសន្និដ្ឋានជូនថ្នាក់ដឹកនាំតាមឋានានុក្រម ពិនិត្យ និង សម្រេច។

៤-រៀបចំ និង បង្កើតឡើងនូវបណ្ណាញស្រាវជ្រាវដែលមានលក្ខណៈជាប្រព័ន្ធ គ្រប់ជ្រុងជ្រោយ និង មានសមត្ថភាពសម្រាប់បំរើឱ្យការងារឃ្លាំមើល តាមដាន និង ប្រមូលព័ត៌មាន ។

៥-សិក្សាស្រាវជ្រាវ ប្រមូល និង ស្វែងរកព័ត៌មានពីបណ្តាញស្រាវជ្រាវរបស់ខ្លួនដែលពាក់ព័ន្ធទៅនឹងបញ្ហាទំនាស់ដីធ្លី ជាពិសេសព័ត៌មានអំពីការចោទប្រកាន់ ការឃុំខ្លួន និង អំពីពាក្យបណ្តឹងនានា ដែលពាក់ព័ន្ធនឹងទំនាស់ដីធ្លី។

៦-រៀបចំ និង បង្កើតឡើងនូវបែបបទ នីតិវិធី និង គោលការណ៍សំរាប់ធ្វើការវិភាគ និង វាយតំលៃព័ត៌មាន ដែលប្រមូលបានពីគ្រប់មជ្ឈដ្ឋានទាំងអស់ និង ធានាឱ្យបាននូវសុក្រឹតភាព និង សុចរិតភាពលើរបាយការណ៍ផ្លូវការ ដែលបានមកពីការស៊ើបអង្កេត។

៧-ចងក្រង និង បង្កើតឡើងជាប្រពន្ធ័គ្រប់គ្រងទិន្នន័យស្រាវជ្រាវ ឬព័ត៌មានដែលពាក់ពន្ធ័ដទៃទៀតសម្រាប់យកទៅប្រើប្រាស់ជាភស្តុតាងក្នុងការងារស៊ើបអង្កេត និង ក្នុងការចោទប្រកាន់អំពីការរំលោភ និង ទន្ទ្រានដីធ្លី ។

៨-សិក្សាស្រាវជ្រាវចងក្រងច្បាប់ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច និង លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ពន្ធ័នឹងបញ្ហាដីធ្លី ។

**ខ- អំពីការងារអធិការកិច្ច**

១-ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ បទបញ្ជា សេចក្តីសម្រេច និង លិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងបញ្ហាដីធ្លី របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និង ស្ថាប័នអនុវត្តច្បាប់ពាក់ព័ន្ធ ។

២-ត្រួតពិនិត្យការដោះស្រាយវិវាទដីធ្លីរបស់ស្ថាប័នពាក់ព័ន្ធនឹងការដោះស្រាយវិវាទដីធ្លី ។

៣-ធ្វើរបាយការណ៍អំពីលទ្ធផលនៃការងារអធិការកិច្ច ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

**មាត្រា ១២.-**

**នាយកដ្ឋានទទួល និង ដោះស្រាយបណ្តឹង មានតួនាទី និង ភារកិច្ចដូចតទៅ:**

១-ទទួល និង ចុះលេខពាក្យបណ្តឹងចេញចូលតាមខេត្ត-ក្រុង និង រៀបចំកសាងសំណុំរឿង ។

២-បញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ ។

៣-កោះអញ្ជើញដើមបណ្តឹង និង/ឬ ចុងចម្លើយពាក់ព័ន្ធឱ្យមកបំពេញឯកសារបន្ថែម ប្រសិនយល់ថាឯកសារមិនគ្រប់គ្រាន់ និង ធ្វើកំណត់ហេតុសួរយកចម្លើយជាបឋម ។

៤-ធ្វើចំណាត់ថ្នាក់ កំណត់អាទិភាព និង ប្រភេទវិវាទតាមវិស័យ ។

៥-ប្រមូលទិន្នន័យ និង ឯកសារបន្ថែម ដោយធ្វើទំនាក់ទំនងជាមួយភាគីជំលោះ សាក្សី រដ្ឋអំណាចមូលដ្ឋាន ក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ និង អន្តរជាតិ សំរាប់ធ្វើការវិភាគអោយបានសុក្រឹត ។

៦-សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ពន្ធ័ ចុះពិនិត្យវាស់វែងប្លង់ និង ត្រីវិវាទដល់ទីកន្លែង ដើម្បីផ្ទៀងផ្ទាត់ទៅតាមខ្លឹមសារនៃសំណុំរឿងវិវាទ ។

៧-រៀបចំសំណុំឯកសារវាយតំលៃ លើលទ្ធផលចុះវាស់វែង និង បញ្ជូនលទ្ធផលដំបូងខាងផ្នែកបច្ចេកទេស ដើម្បីសុំគោលការណ៍ និង សេចក្តីសំរេចពីអគ្គលេខាធិការ នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

៨-ធ្វើកំណត់បង្ហាញដោយសង្ខេបខ្លឹមសារបណ្តឹង លើកអង្គហេតុ និង អង្គច្បាប់ពាក់ពន្ធ័ និង ផ្តល់យោបល់ជាបឋម ជូនថ្នាក់ដឹកនាំតាមឋានានុក្រម ពិនិត្យ និង សម្រេច ។

៩-ធ្វើសេចក្តីសម្រេចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដែលមានសុពលភាពអាចអនុវត្តបានទៅមន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និង សុរិយោដី ដើម្បីចាត់ចែងធ្វើការចុះបញ្ជីក្បាលដីតាមនីតិវិធី ។

**មាត្រា ១៣.-**

**នាយកដ្ឋានបូកសរុប ព័ត៌មានវិទ្យា និង ទំនាក់ទំនងសាធារណៈ មានតួនាទី និង ភារកិច្ចដូចតទៅ:**

១- សហការជាមួយនាយកដ្ឋានរដ្ឋបាល និង បុគ្គលិក ដើម្បីរៀបចំរបាយការណ៍បូកសរុបការងារគ្រប់នាយកដ្ឋាន និង របាយការណ៍សកម្មភាពការងារផ្សេងៗទៀតរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជាពិសេសកំណត់បង្ហាញ និង របាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

២- កំណត់លក្ខណៈបច្ចេកទេសកុំព្យូទ័រ បង្កើត និង អនុវត្តនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ។

៣- គ្រប់គ្រង ការពារ និង ថែទាំបណ្តាញព័ត៌មានវិទ្យា ។

៤- បណ្តុះបណ្តាលរបៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាដល់មន្ត្រី និង បុគ្គលិក ។

៥- ប្រមូលផ្តុំព័ត៌មាន តាមប្រព័ន្ធឃោសនាជាតិ និង អន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងទំនាស់ដីធ្លី ។

៦- សហការទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ ដើម្បីផ្សព្វផ្សាយ រៀបចំ កៀងគរជំនួយក្នុងទិសដៅបំរើគោលនយោបាយរបស់អាជ្ញាធរជាតិ ។

៧- ធ្វើរបាយការណ៍លំអិតអំពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំ ។

៨- ធ្វើការចងក្រងព័ត៌មាន និង ធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធឃោសនាជាតិ និង អន្តរជាតិ រាល់ពេលប្រជុំសវនាការដោះស្រាយវិវាទ និង សកម្មភាពដោះស្រាយវិវាទទាំងឡាយរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

៩- សហការធ្វើសៀវភៅផ្ទត់បញ្ចាំងរូបភាពផ្សព្វផ្សាយអំពីការអប់រំ ទប់ស្កាត់ កុំអោយមានទំនាស់ដីធ្លីតាមសហគមន៍ ។

**មាត្រា ១៤.-**

**នាយកដ្ឋានរដ្ឋបាល និង បុគ្គលិក មានតួនាទី និង ភារកិច្ចដូចតទៅ:**

១- គ្រប់គ្រងការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន ។

២- កសាង និង រៀបចំលិខិតបទដ្ឋាននានារបស់អគ្គលេខាធិការដ្ឋាន និង ចរាចរលិខិតទៅគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ ។

៣- កសាង និង រៀបចំគម្រោងថវិកាប្រចាំឆ្នាំ ។

៤- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សម្ភារៈ និង ធ្វើបញ្ជីសារពើភណ្ឌ ។

៥- រៀបចំ និង សម្រួលកិច្ចប្រជុំរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និង អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

៦- សហការជាមួយនាយកដ្ឋានបូកសរុប ព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ ដើម្បីធ្វើកំណត់ហេតុអង្គប្រជុំ របាយការណ៍បូកសរុបការងារគ្រប់នាយកដ្ឋាន និង របាយការណ៍សកម្មភាពការងារផ្សេងៗទៀតរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជាពិសេស កំណត់បង្ហាញ និង របាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

៧- រៀបចំផែនការគ្រប់គ្រងបុគ្គលិក និង ធនធានមនុស្ស ជាពិសេសរៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីធ្វើយ៉ាងណាឱ្យបុគ្គលិកដែលបំរើការងារមានសមត្ថភាព និង ជំនាញគ្រប់គ្រាន់ ដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាព ។

**មាត្រា ១៥.-**

នាយកដ្ឋាននីមួយៗត្រូវសហការគ្នា ឱ្យដំណើរការងាររបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និង ទទួលបានជោគជ័យ ។ នាយកដ្ឋាននីមួយៗ អាចស្នើសុំបង្កើតការិយាល័យមួយចំនួនតាមការចាំបាច់ ដើម្បីជាសេនាធិការ ។

## ជំពូកទី ៣
## មន្ត្រី បុគ្គលិក

**មាត្រា ១៦.-**

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ប្រើប្រាស់បុគ្គលិក នៃមុខងារសាធារណៈ ឬ អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ។ លក្ខខណ្ឌនៃលាភការរបស់ភ្នាក់ងារជាប់កិច្ចសន្យា និង ប្រាក់បំណាច់ពិសេសសម្រាប់បើកជូនភ្នាក់ងារមុខងារសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់អគ្គលេខាធិការ ។

**មាត្រា ១៧.-**

សមាជិក និង បុគ្គលិកទាំងអស់របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសិទ្ធិទទួលបាននូវប្រាក់បំណាច់ផ្សេងៗ ដែលបានផ្តល់មកពីអង្គការផ្តល់ជំនួយក្នុងស្រុក ឬអង្គការផ្តល់ជំនួយអន្តរជាតិនានា ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ចាប់ពីក្រោមថ្នាក់ប្រធាននាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់អគ្គលេខាធិការ នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ប្រធានស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ១៩
- ឯកសារ-កាលប្បវត្តិ